**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Driot et des Sciences Economiques**

**Royal University of Law and Economics**


## សារណាបញ្ចប់ការសិក្សា

# ការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់តាម
# បែបវិមជ្ឈការ

ស្រាវជ្រាវពីថ្ងៃទី ២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១


| | |
|---|---|
| ស្រាវជ្រាវដោយ | សាស្ត្រាចារ្យណែនាំ |
| និស្សិតឈ្មោះ: **សំណាង ស្រីពេជ្រ** | បណ្ឌិត **សឿន សោភ័ណ** |
| **ហ៊ុយ សុខដាលីន** | |


| | |
|---|---|
| ថ្នាក់បរិញ្ញាបត្រ រដ្ឋបាលសាធារណៈ | ឆ្នាំចូលសិក្សា ២០១៧ |
| ជំនាន់ទី១៤ (អាហារូបករណ៍) | ឆ្នាំសរសេរសារណា ២០២១ |

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ **សំណាង ស្រីពេជ្រ** និង នាងខ្ញុំឈ្មោះ **ហ៊ុយ សុខដាលីន** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ជំនាញរដ្ឋបាលសាធារណៈ ក្រុម P4C5 ជំនាន់ទី ១៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចឆ្នាំសិក្សា ២០២០-២០២១ ។

## សូមសម្តែងនូវការគោរពដឹងគុណដ៏ខ្ពង់ខ្ពស់ជាអនេកប្បការចំពោះ

លោកឪពុក អ្នកម្តាយ ដែលលោកទាំងពីរមានគុណយ៉ាងធំធេងពុំអាចកាត់ថ្លៃបានចំពោះកូនៗ លោកទាំងពីរបានចិញ្ចឹមបីបាច់កូនតាំងពីតូចក្រូចឆ្មា ផ្តល់ជម្រក ចំណីអាហារ សម្លៀកបំពាក់ ការសិក្សាអប់រំ ជាពិសេសក្តីស្រលាញ់ ភាពកក់ក្តៅ និងដំបូន្មានប្រៀនប្រដៅប្រកបដោយព្រហ្មវិហារធម៌ ដាស់តឿនរំលឹកកូនៗដែលជាប្រទីបនាំផ្លូវកូនមកដល់សព្វថ្ងៃនេះ។ លោកទាំងពីរមិនដែលខ្លាចពាក្យថានឿយហត់ទាំងកម្លាំងកាយចិត្ត ខិតខំប្រឹងទាំងយប់ ទាំងថ្ងៃ ជម្រុញអោយកូនទទួលបាននូវការសិក្សាអប់រំ ជាងនេះទៅទៀតលោកទាំងទ្វេបានខិតខំប្រៀនប្រដៅអប់រំលើកទឹកចិត្ត ដល់រូបកូនអោយកូនខិតខំប្រឹងប្រែងក្នុងការរៀនសូត្រកន្លងមកនេះ ដើម្បីអោយកូនចេះតស៊ូ ជម្នះនូវការលំបាកក្នុងជីវិត អាចក្លាយជាទំពាំងដ៏រឹងមាំរួមចំណែកអភិវឌ្ឍសង្គមជាតិ និងសង្គមគ្រួសារនាពេលអនាគត។ គុណបំណាច់លោកទាំងពីរ ជាគុណបំណាច់ដ៏ខ្ពង់ខ្ពស់បំផុតមិនមានអ្វីប្រៀបផ្ទឹមបាន និងជាកម្លាំងចិត្តដ៏ខ្លាំងមុះមុតរបស់កូនៗ។

ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោក-លោកស្រី សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ ដែលបានចំណាយកម្លាំងកាយចិត្ត លះបង់នូវពេលវេលាដ៏មានតម្លៃគ្រប់គ្រង ដឹកនាំ បណ្តុះបណ្តាល បង្ហាត់បង្រៀនដល់យើងខ្ញុំ ក៏ដូចជានិសិត្សគ្រប់រូបៗទទួលបាននូវចំណេះដឹងក្លាយជា យុវជនដែលមានសមត្ថភាពរឹងមាំបន្តដំណើរឆ្ពោះទៅមុខបន្តទៀត។

ជាពិសេសសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់លោកសាស្ត្រាចារ្យបណ្ឌិត **សឿន សោភ័ណ** ដែលលោកបានខិតខំយកចិត្តទុកដាក់ចែករំលែកនូវចំណេះដឹងជាច្រើនដល់យើងខ្ញុំយ៉ាងយកចិត្តទុកដាក់ និងតែងតែផ្តល់មតិយោបល់រាល់ចំងល់របស់នាងខ្ញុំ ទោះជាសាស្ត្រាចារ្យមានភាពមមាញឹក ក្នុងការបំពេញការងារយ៉ាងណាក្តីក៏លោកនៅតែខិតខំពន្យល់ណែនាំ និងលើកទឹកចិត្តដល់យើងខ្ញុំក្នុងការចងក្រងសៀវភៅនេះឡើង។

ចំពោះមិត្តភ័ក្តទាំងអស់គ្នា ដែលបានចូលរួមផ្តល់យោបល់ និងលើកទឹកចិត្តដល់នាងខ្ញុំឱ្យធ្វើកិច្ចការស្រាវជ្រាវនេះរហូតដល់បញ្ចប់ដោយជោគជ័យ។

# អារម្ភកថា

ប្រទេសកម្ពុជាបាន នឹងកំពុងយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើវិស័យរដ្ឋបាល ដើម្បីធ្វើយ៉ាងណាឲ្យដំណើរការនៃការគ្រប់គ្រង មានភាពល្អប្រសើរ និងប្រកបដោយការអភិវឌ្ឍន៍បានឆាប់រហ័ស ។ រាជរដ្ឋាភិបាលបានចេញនូវគោលនយោបាយជាច្រើន ដើម្បីពង្រឹងនូវវិស័យរដ្ឋបាលសាធារណៈនៅកម្ពុជាទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដោយមានការបែងចែកថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិក្នុងគោលបំណងឲ្យមានភាពងាយស្រួលនៅក្នុងការគ្រប់គ្រង និងចាត់ចែងដំណើរការការងារគ្រប់វិស័យទូទាំងប្រទេសឲ្យមានភាពរលូន និងមានប្រសិទ្ធភាពខ្ពស់ ។ ក្នុងនោះរដ្ឋបាលឃុំ សង្កាត់ ជារដ្ឋបាលថ្នាក់ក្រោមជាតិដែលត្រូវបានបង្កើតឡើងដោយការបោះឆ្នោតពីសំណាក់ប្រជាពលរដ្ឋតាមឃុំ សង្កាត់នីមួយរបស់ខ្លួន ដោយប្រើប្រព័ន្ធវិមជ្ឈការក្នុងការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។ រាជរដ្ឋាភិបាលបានធ្វើកំណែទម្រង់វិមជ្ឈការជាបន្តបន្ទាប់ក្នុងគោលបំណង ដើម្បីពង្រឹងលទ្ធិប្រជាធិបតេយ្យ និងលើកកម្ពស់គុណភាពនៃការផ្តល់សេវាសាធារណៈជូនដល់ប្រជាពលរដ្ឋ ជាពិសេសដើម្បីខិតឱ្យជិតប្រជាពលរដ្ឋតាមឃុំ សង្កាត់នីមួយៗតាមរយៈការគ្រប់គ្រងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ធ្វើយ៉ាងណាយល់ឱ្យកាន់តែច្បាស់ពីតម្រូវការ និងបញ្ហាជួបប្រទះរបស់ប្រជាពលរដ្ឋ ដើម្បីស្វែងរកដំណោះស្រាយ ក៏ដូចជាផែនការផ្សេងៗក្នុងការផ្តល់ផលប្រយោជន៍ជូនប្រជាពលរដ្ឋក្នុងមូលដ្ឋានជាធំ ។ ហេតុដូច្នេះហើយយើងខ្ញុំបានជ្រើសរើសប្រធានបទមួយស្តីពី "**ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការ**" ដើម្បីធ្វើការបង្ហាញអំពីដំណើរការនៃការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់នៅកម្ពុជា និងគោលបំណងជាគោលដៅនៃការប្រើប្រព័ន្ធវិមជ្ឈការនេះក្នុងការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។

ក្នុងនាមអ្នកស្រាវជ្រាវប្រធានបទនេះ នាងខ្ញុំមានគោលបំណង ក្នុងការស្វែងយល់ឱ្យកាន់តែច្បាស់អំពីប្រព័ន្ធរដ្ឋបាលឃុំ សង្កាត់នៅកម្ពុជាតាមរយៈការស្រាវជាវពីឯកសារពាក់ព័ន្ធផ្សេងៗ ដែលទាក់ទងនឹងប្រធានបទនេះ ក៏ដូចជាចែករំលែកដល់អ្នកសិក្សា ដែលមានបំណងស្រាវជ្រាវស្វែងយល់ពីប្រធានបទនេះផងដែរ។ ទោះបីជាយ៉ាងណាក្តី នាងខ្ញុំជឿជាក់ថាការចងក្រងនូវសៀវភៅសារណានេះឡើងពិតជាមាននូវចំណុចខ្វះខាត និងកំហុសឆ្គងទាំងផ្នែកខ្លឹមសារ និងអក្ខរាវិរុទ្ធ ។ នាងខ្ញុំគោរព និងរីករាយទទួលយកនូវការរិះគន់ក្នុងន័យស្ថាបនាពីសំណាក់ លោកគ្រូ-អ្នកគ្រូសាស្ត្រាចារ្យ និងមិត្តអ្នកអានគ្រប់រូប ដើម្បីឱ្យអត្ថបទមួយនេះកាន់តែមានភាពល្អប្រសើរ ។

នាងខ្ញុំទាំងពីរអ្នកពិតជាមានសេចក្តីសោមនស្សរីករាយជាពន់ពេក ដែលមានឱកាសក្នុងការចងក្រងនៅសារណាមួយនេះឡើងក្រោមការជួយជ្រោមជ្រែងពីលោកសាស្ត្រាចារ្យ និងមិត្តនិស្សិតគ្រប់ជំនាន់ ។ ជាចុងក្រោយនាងខ្ញុំសូមប្រសិទ្ធិពរ និងជូនពរដល់លោកគ្រូ-អ្នកគ្រូសាស្ត្រាចារ្យ និងមិត្តអ្នកអានទាំងអស់ជួបតែសេចក្តីសុខគ្រប់ប្រការ និងទទួលនូវការគោរពរាប់អានពីនាងខ្ញុំ ។

# មាតិកា

**សេចក្តីផ្តើម** **ទំព័រ**


**១. លំនាំបញ្ហា**............................................................ ១

**២. ចំណោទបញ្ហា**............................................................ ២

**៣. វិសាលភាពនៃការស្រាវជ្រាវ**............................................................ ២

**៤. គោលបំណងនៃការស្រាវជ្រាវ**............................................................ ២

**៥. សារៈសំខាន់នៃការស្រាវជ្រាវ**............................................................ ២

**៦. វិធីសាស្ត្រក្នុងការស្រាវជ្រាវ**............................................................ ៣

**៧. រចនាសម្ព័ន្ធក្នុងការស្រាវជ្រាវ**............................................................ ៣


## ជំពូកទី ១

## ទិដ្ឋភាពទូទៅក្នុងការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់


**១.១ សញ្ញាណទូទៅក្នុងការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់**............................................................ ៦

១.១.១ និយមន័យរដ្ឋបាល............................................................ ៦

១.១.២ និយមន័យឃុំ សង្កាត់............................................................ ៦

១.១.៣. និយមន័យវិមជ្ឈការ និងវិសហមជ្ឈការ............................................................ ៦

១.១.៤ ទិសដៅវិមជ្ឈការ............................................................ ៧

ក. ការផ្តល់ឱកាសឲ្យប្រជាពលរដ្ឋចូលរួម ............................................................ ៧

ខ. ការលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ អភិបាលកិច្ចល្អ និងគុណភាពនៃជីវភាពរស់នៅ ............................................................ ៨

គ. ការធានាដល់ការអភិវឌ្ឍប្រកបដោយចីរភាព រួមទាំងការផ្តល់សេវាជាមូលដ្ឋាន............................................................ ៩

**១.២ ការរៀបចំរដ្ឋបាលឃុំ សង្កាត់**............................................................ ១០

១.២.១ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់............................................................ ១០

១.២.២.លក្ខខណ្ឌក្នុងការឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់............................................................ ១២

១.២.៣ តួនាទី និងមុខងារឃុំ-សង្កាត់ ........ ១៤
ក. តំណាងឱ្យរាស្ត្រប្រជា ........ ១៤
ខ. តំណាងឱ្យរដ្ឋ ........ ១៤
១.២.៤ អាណត្តិឃុំសង្កាត់ ........ ១៥
**១.៣ រចនាសម្ព័ន្ធរដ្ឋបាលឃុំ-សង្កាត់** ........ ១៥
១.៣.១ ក្រុមប្រឹក្សាឃុំ-សង្កាត់ ........ ១៥
១.៣.២ មេឃុំ/ចៅសង្កាត់ ........ ១៦
១.៣.៣ ជំទប់/ចៅសង្កាត់រង ........ ១៧
១.៣.៤ ស្មៀនឃុំ ........ ១៨
១.៣.៥. គណៈកម្មាធិការ ........ ១៩
១.៣.៦. មេភូមិ ........ ១៩
ក. និយមន័យ ........ ១៩
ខ. តួនាទី និងភារកិច្ច ........ ២០
គ. លក្ខខណ្ឌនានានៃការបាត់បង់មុខតំណែងរបស់មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ ........ ២០
**ជំពូកទី ២**
**គោលការណ៍គ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការ**
**២.១ ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់** ........ ២២
២.១.១. លិខិតបទដ្ឋានគតិយុត្តឃុំ-សង្កាត់ ........ ២២
២.១.២. លិខិតរដ្ឋបាលឃុំ-សង្កាត់ ........ ២២
២.១.៣. ការគ្រប់គ្រងសម្ភារបរិក្ខារឃុំ-សង្កាត់ ........ ២៥
២.១.៤. ការគ្រប់គ្រងឯកសារឃុំ-សង្កាត់ ........ ២៥
ក. ផលប្រយោជន៍នៃការគ្រប់គ្រងឯកសារ ........ ២៥

ខ. ប្រភេទឯកសារ............................................................................................................................ ២៥

២.១.៥. កិច្ចប្រជុំក្រុមប្រឹក្សាឃុំ-សង្កាត់ ............................................................................................ ២៦

ក. ការត្រៀមរៀបចំកិច្ចប្រជុំ.............................................................................................................. ២៧

ខ. ការប្រព្រឹត្តទៅនៃកិច្ចប្រជុំ.............................................................................................................. ២៧

គ. កិច្ចការនានាក្រោយពេលប្រជុំ........................................................................................................ ២៨

**២.២ ការគ្រប់គ្រងហិរញ្ញវត្ថុឃុំ-សង្កាត់**............................................................................................... ២៩

២.២.១. ប្រភពចំណូលឃុំ សង្កាត់............................................................................................................ ២៩

២.២.២. ថវិកាឃុំ-សង្កាត់........................................................................................................................ ៣០

២.២.៣. ការគ្រប់គ្រង និងការអនុវត្តថវិកាឃុំ-សង្កាត់............................................................................. ៣១

២.២.៤. ប្រព័ន្ធទូទាត់ និងគណនេយ្យឃុំសង្កាត់...................................................................................... ៣១

ក. គោលការណ៍ទូទៅ.......................................................................................................................... ៣១

ខ. ប្រព័ន្ធទូទាត់................................................................................................................................ ៣២

គ. ប្រព័ន្ធគណនេយ្យ ......................................................................................................................... ៣២

២.២.៥. របាយការណ៍ហិរញ្ញវត្ថុឃុំ សង្កាត់ ........................................................................................... ៣២

២.២.៦. កិច្ចលទ្ធកម្មឃុំ សង្កាត់ ............................................................................................................ ៣២

២.២.៧. ការទូទាត់ ................................................................................................................................. ៣៣

**២.៣. ផែនការអភិវឌ្ឍឃុំ-សង្កាត់**.......................................................................................................... ៣៣

២.៣.១. ការរៀបចំ និងដំណើរការនៃផែនការអភិវឌ្ឍន៍ឃុំ-សង្កាត់ ........................................................... ៣៣

២.៣.២. វដ្តនៃផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ .......................................................................................... ៣៥

២.៣.៣. កម្មវិធីវិនិយោគរបស់ឃុំ .......................................................................................................... ៣៦

ក. ក្របខ័ណ្ឌវិនិយោគ........................................................................................................................ ៣៦

ខ. វដ្តនៃកម្មវិធីវិនិយោគឃុំ សង្កាត់ ................................................................................................... ៣៦

២.៣.៤. តួនាទី និងភារកិច្ចរបស់អ្នកពាក់ព័ន្ធ ........ ៣៨
ក. ក្រុមប្រឹក្សាឃុំ សង្កាត់ ........ ៣៨
ខ. មេឃុំចៅ សង្កាត់ ........ ៣៨
គ. គណៈកម្មាធិការកសាងផែនការ និងថវិកាឃុំសង្កាត់(គ.ផ.ថ) ........ ៣៨
ឃ. អភិបាលរាជធានី ខេត្ត........ ៣៨
ង. អង្គភាពរដ្ឋបាលមូលដ្ឋានរាជធានី ខេត្ត ........ ៣៩
ច. មន្ទីរ និងអង្គភាពជំនាញរាជធានី ខេត្តនានា ........ ៣៩
ឆ. អង្គការសង្គមស៊ីវិល ........ ៣៩
២.៣.៥. ការចូលរួមរបស់ប្រជាពលរដ្ឋ ........ ៣៩
២.៣.៦. ការត្រួតពិនិត្យ និងវាយតម្លៃ........ ៤០
**២.៤. ការគ្រប់គ្រងបុគ្គលិក** ........ ៤០
២.៤.១. ការរៀបចំបញ្ជីគ្រប់គ្រងបុគ្គលិកឃុំ សង្កាត់ និងការបរិយាយពីមុខងារលម្អិត ........ ៤១
២.៤.២. គោលការណ៍ផ្តល់ការងារ ........ ៤១
២.៤.៣. ការវាយតម្លៃការអនុវត្តការងាររបស់បុគ្គលិក ........ ៤១
**២.៥. ទំនាក់ទំនងរដ្ឋបាលរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់** ........ ៤២
**២.៦. វិធានការវិន័យ និងការបញ្ឈប់មុខដំណែងចំពោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់** ........ ៤៣

## ជំពូកទី ៣

## របកគំហើញលើការស្រាវជ្រាវ

**៣.១ សមិទ្ធផលនៃការអនុវត្តគោលនយោបាយគ្រប់គ្រងរដ្ឋបាលតាមបែបវិមជ្ឈការ** . ៤៥
៣.១.១ ការធ្វើប្រតិភូកម្មមុខងារជាភ្នាក់ងារទៅឃុំ សង្កាត់ ........ ៤៥
៣.១.២ ហិរញ្ញវត្ថុឃុំ សង្កាត់ ........ ៤៥

៣.១.៣ ការកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍក្នុងមូលដ្ឋាន ........................................................ ៥៦

៣.១.៤.ការគាំទ្រនិងការតាមដានត្រួតពិនិត្យការអនុវត្តថវិកា ឬមូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិ............. ៥៦

**៣.២ បញ្ហាប្រឈម** ........................................................................................ ៥៧

៣.២.១ ការផ្តល់សេវាសាធារណៈ ........................................................................ ៥៧

៣.២.២ ធនធានមនុស្ស និងការអភិវឌ្ឍសមត្ថភាព.................................................... ៥៨

៣.២.៣. ការចូលរួមរបស់ប្រជាពលរដ្ឋ ...................................................................... ៥៨

**៣.៣ ដំណោះស្រាយ** ........................................................................................ ៥៩

៣.៣.១ ពង្រឹងគុណភាពការផ្តល់សេវាសាធារណៈ ...................................................... ៥៩

៣.៣.២ ពង្រឹងការគ្រប់គ្រងធនធានមនុស្ស និងការអភិវឌ្ឍសមត្ថភាព.................................. ៥៩

៣.៣.៣. ពង្រឹងការចូលរួមរបស់ប្រជាពលរដ្ឋ ............................................................. ៥០

**សេចក្តីសន្និដ្ឋាន**.............................................................................................. ៥២

**អនុសាសន៍**..................................................................................................... ៥៤

**ឯកសារពិគ្រោះ**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា

ប្រទេសកម្ពុជាជាប្រទេសមួយដែលត្រូវបានគេស្គាល់ថាជា ប្រទេសដែលមានប្រវត្តិសាស្ត្រដ៏យូរអង្វែង ប្រកបដោយមោទនភាពជាទីចាប់ចិត្តផ្ចិតអារម្មណ៍យ៉ាងក្រៃលែង។ ទន្ទឹមគ្នានឹងនេះ កម្ពុជាបានជួបប្រទះនូវវិបត្តិសង្គ្រាមពីសំណាក់ប្រទេសជិតខាង ក៏ដូចជាសង្គ្រាមផ្ទៃក្នុងអស់រយៈកាលយ៉ាងយូរផងដែរ។ ក្រោយពីសង្គ្រាមត្រូវបានបញ្ចប់ប្រទេសកម្ពុជាបានទទួលរងនូវការបំផ្លាញយ៉ាងច្រើនដូចជា ហេដ្ឋារចនាសម្ព័ន្ធ ផ្នែកសេដ្ឋកិច្ច និងជាពិសេសនោះគឺ ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលដែលជាចំណែកមួយយ៉ាងសំខាន់ក្នុងការអភិវឌ្ឍប្រទេសជាតិ។ ដើម្បីគ្រប់គ្រង និងធ្វើការដឹកនាំប្រទេសជាតិឲ្យមានភាពល្អប្រសើរនោះ រាជរដ្ឋាភិបាលបានខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្លាក្នុងការស្តារប្រព័ន្ធគ្រប់គ្រងរដ្ឋបាលរបស់ប្រទេសយើងឲ្យមានតម្លាភាព ស្ថេរភាព និងប្រសិទ្ធភាព ជូនប្រជាពលរដ្ឋគ្រប់ស្រទាប់ថ្នាក់ និងធ្វើយ៉ាងណាសំដៅឆ្លើយតបឲ្យទាន់ពេលវេលានៃតម្រូវការរបស់ប្រជាពលរដ្ឋ ក្នុងគោលបំណងកាត់បន្ថយភាពក្រីក្រ លើកកម្ពស់កម្រិតជីវភាពរស់នៅ សុខមាលភាពរបស់ប្រជាពលរដ្ឋ ជាពិសេសដើម្បីធ្វើការជំរុញ និងពន្លឿនកំណើនសេដ្ឋកិច្ចឲ្យមានសន្ទុះទៅថ្ងៃខាងមុខ។

ជាក់ស្តែង ដើម្បីបង្កភាពងាយស្រួលនិងស្វែងយល់ពីតម្រូវការរបស់ប្រជាពលរដ្ឋបានទាន់ពេលវេលា រាជរដ្ឋាភិបាលបានរៀបចំដាក់ចេញឲ្យអនុវត្តប្រព័ន្ធរដ្ឋបាលថ្មីមួយ តាមបែបវិមជ្ឈការ ដែលជាការផ្ទេរនូវសិទ្ធិអំណាចមួយចំនួនពីរដ្ឋបាលថ្នាក់ជាតិឲ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធ្វើការគ្រប់គ្រងនិងផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋនៅមូលដ្ឋានឃុំ សង្កាត់នីមួយៗ។ បើយើងពិនិត្យមើលទៅលើសមិទ្ធផលចំពោះការអនុវត្តរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការកន្លងមកនេះយើងឃើញថាប្រជាពលរដ្ឋអាចទទួលបាននូវអត្ថប្រយោជន៍ និងការឆ្លើយតបយ៉ាងមានប្រសិទ្ធភាព។ វាបានជំរុញឲ្យប្រជាពលរដ្ឋចូលរួមក្នុងសកម្មភាពសង្គមជាច្រើន ចូលរួមធ្វើការបញ្ចេញមតិយោបល់ក៏ដូចជាក្នុងការសម្រេចចិត្តលើគម្រោងមួយចំនួនផងដែរ។

ជាការពិតណាស់ ក្រុមប្រឹក្សាឃុំ សង្កាត់គឺជាអាជ្ញាធរវិមជ្ឈការដែលត្រូវបានទទួលស្គាល់ថាជាតំណាងរបស់រដ្ឋដែលមានទីតាំងនៅតាមមូលដ្ឋាននានាទូទាំងប្រទេស។ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធានាឲ្យសហគមន៍ ឬមូលដ្ឋានរបស់ខ្លួនគ្រប់គ្រងនោះបានចូលរួមនៅក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត។ ចាប់តាំងពីឆ្នាំ ២០០១ មកឃុំ សង្កាត់បានក្លាយខ្លួនជាភ្នាក់ងារវិមជ្ឈការដោយស្ថិតក្រោមការគ្រប់គ្រងដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។ ឃុំ សង្កាត់មានស្វ័យភាពរដ្ឋបាល និងខាងហិរញ្ញវត្ថុប៉ុន្តែស្ថិតក្រោមការត្រួតពិនិត្យរដ្ឋបាលដោយអាជ្ញាធររដ្ឋ។

ដូច្នេះ ប្រធានបទនេះនឹងផ្តល់នូវខ្លឹមសារ និងផលប្រយោជន៍ជាច្រើនដល់អ្នកសិក្សា ជាពិសេស គឺប្រជាពលរដ្ឋ ក៏ដូចជាមន្ត្រីរាជការថ្នាក់មូលដ្ឋាន ហើយថែមទាំងអាចចូលរួមជាចំណែកនៃឯកសារសម្រាប់សិក្សាស្រាវជ្រាវដល់និស្សិតជំនាន់ក្រោយៗទៀត។

## ២. ចំណោទបញ្ហា

ដូចដែលយើងបានដឹងមកហើយថា ការងារគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិឃុំ សង្កាត់ គឺជាតួនាទីរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការរៀបចំធ្វើយ៉ាងណាឲ្យប្រជាពលរដ្ឋមានភាពងាយស្រួល ដើម្បីទទួលបាននូវរដ្ឋបាលមួយដែលនៅជិតជាមួយប្រជាពលរដ្ឋជាងគេបង្អស់ ដែលអាចស្វែងយល់ពីតម្រូវការ និងផ្តល់ឲ្យប្រជាពលរដ្ឋវិញទាន់ពេលវេលាហើយឆ្លើយតបបានយ៉ាងត្រឹមត្រូវ។ ប៉ុន្តែជាក់ស្តែង វានៅមានបញ្ហាប្រឈមមួយចំនួនដែលត្រូវការការកែលម្អបន្ថែម អាស្រ័យហេតុនេះហើយទើបក្នុងការសិក្សាស្រាវជ្រាវលើប្រធានបទ ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការបានបង្ហាញនូវបញ្ហាចោទដូចខាងក្រោម៖

១.តើដំណើរការនៃការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់តាមបែបវិមជ្ឈការប្រព្រឹត្តិទៅដូចម្តេច?

២. តើការគ្រប់គ្រងរដ្ឋបាលតាមបែបវិមជ្ឈការជួបប្រទះនូវបញ្ហាប្រឈមអ្វីខ្លះ? និងមានដំណោះស្រាយយ៉ាងដូចម្តេច?

## ៣. វិសាលភាពនៃការស្រាវជ្រាវ

ការសិក្សាលើប្រធានបទនេះ មានវិសាលភាពផ្តោតទៅលើសមិទ្ធផល នៃការអនុវត្តគោលនយោបាយគ្រប់គ្រងរដ្ឋបាលតាមបែបវិមជ្ឈការកន្លងមកដូចជា ការធ្វើប្រតិភូកម្មមុខងារនៃភ្នាក់ងារទៅឃុំ សង្កាត់ ភាពជោគជ័យលើហិរញ្ញវត្ថុឃុំ សង្កាត់ ការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍន៍ក្នុងមូលដ្ឋាន និងការគាំទ្រតាមដានត្រួតពិនិត្យលើការអនុវត្តថវិកា ឬមូលនិធិរដ្ឋបាលឃុំ សង្កាត់ និងបញ្ហាជួបប្រទះ ព្រមទាំងដំណោះស្រាយឆ្លើយតបទៅនឹងបញ្ហាទាំងនោះដែរ ។

## ៤. គោលបំណងនៃការស្រាវជ្រាវ

គោលបំណងសំខាន់នូវក្នុងការស្រាវជ្រាវលើប្រធានបទមួយនេះមកធ្វើការស្រាវជ្រាវគឺ៖

ទី១ ដើម្បីសិក្សាអំពីដំណើរការនៅក្នុងការគ្រប់គ្រងឃុំ សង្កាត់តាមបែបវិមជ្ឈការ អំពីការគ្រប់គ្រងប្រព័ន្ធរដ្ឋបាល ការគ្រប់គ្រងហិរញ្ញវត្ថុ ការអនុវត្តផែនការឃុំ សង្កាត់ និងការតាមដានចំពោះការអនុវត្តជាក់ស្តែង ។

ទី២ ដើម្បីសិក្សាអោយឃើញអំពីបញ្ហាជួបប្រទះ និងដំណោះស្រាយ ក៏ដូចជាផលប្រយោជន៍ដែលប្រជាពលរដ្ឋក្នុងឃុំ សង្កាត់បានទទួលកន្លងមក ។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាទៅលើប្រធានបទការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់បែបវិមជ្ឈការនេះ វាពិតជាមានសារៈសំខាន់ណាស់ ជាពិសេសសម្រាប់ពួកយើងដែលជានិស្សិតសិក្សាផ្នែករដ្ឋបាលសាធារណៈផ្ទាល់។ វាជាការស្វែងយល់បន្ថែមឲ្យមានភាពស៊ីជម្រៅមួយ ដែលធ្វើឲ្យយើងអាចយល់ដឹងលើសពីអ្វីដែលពួកយើងធ្លាប់បានសិក្សានៅក្នុងថ្នាក់រៀន ហើយថែមទាំងអាចឲ្យពួកយើងបានស្រាវជ្រាវបន្ថែម បង្កើនការគិត និងមានឱកាសបានបញ្ចេញមតិយោបល់ ក៏ដូចជាបានធ្វើការផ្លាស់ប្តូរគំនិតគ្នាទៅវិញទៅមកលើប្រធានបទនេះឲ្យកាន់តែមានភាព

ច្បាស់លាស់។ ជាទូទៅប្រធានបទដែលពួកយើងយកមកធ្វើការស្រាវជ្រាវ យើងគិតពិចារណាទៅលើសារៈសំខាន់មួយចំនួនគឺ៖

- សារៈសំខាន់ចំពោះសង្គម៖ មានអត្ថន័យយ៉ាងសំខាន់បំផុតសំរាប់ប្រជាពលរដ្ឋ គឺឲ្យពួកគាត់បានយល់ដឹង ក៏ដូចជាអាចចូលរួមជាសកម្មភាពក្នុងការសម្រេចចិត្ត ឬផ្តល់ជាមតិយោបល់ក្នុងន័យអភិវឌ្ឍទៅដល់ភូមិ ឃុំ ឬសហគមន៍ដែលគាត់រស់នៅផ្ទាល់។ ម្យ៉ាងទៀតសម្លេងគាត់ ឬមតិយោបល់ទាំងនោះអាចលឺទៅដល់អាជ្ញាធរមូលដ្ឋានធ្វើការគិតពិចារណា ដើម្បីធ្វើយ៉ាងណាឲ្យមានភាពងាយស្រួល និងឆ្លើយតបទៅកាន់តម្រូវការរបស់ប្រជាពលរដ្ឋ។
- ចំពោះសេដ្ឋកិច្ច៖ កាលណាការផ្តល់សេវាសាធារណៈមានភាពប្រសើរឡើង និងស្ថិតនៅកាន់តែជិតពួកគេទៀតនោះ វាអាចបង្កើននូវភាពងាយស្រួលដែលបណ្តាលឲ្យពួកគេចំណេញនូវថវិការ និងពេលវេលាក្នុងការប្រកបរបរផ្សេងៗ ដែលជាចំណែកក្នុងការអភិវឌ្ឍប្រទេសឲ្យមានភាពរីកចម្រើន។
- ចំពោះនិស្សិត៖ គឺធ្វើឲ្យយើងខ្ញុំបានស្វែងយល់ដឹងកាន់តែច្បាស់ និងស៊ីជម្រៅពីខ្លឹមសារនៃប្រធានបទនេះដែលពាក់ព័ន្ធនឹងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលក្នុងប្រទេសកម្ពុជាយើង។

## ៦. វិធីសាស្ត្រក្នុងការស្រាវជ្រាវ

វិធីសាស្ត្រក្នុងការស្រាវជ្រាវប្រធានបទមួយនេះ គឺមានលក្ខណៈវិទ្យាសាស្ត្រដោយធ្វើការប្រមូលព័ត៌មានមកធ្វើការចងក្រងសារណានេះដោយ ៖

*ការប្រមូលព័ត៌មាន*

ការស្វែងរកឯកសារដែលមានស្រាប់មកវិភាគតាមរយៈ បទដ្ឋានគតិយុត្តនានាក្នុងបណ្ណាល័យ និងតាមប្រព័ន្ធអេឡិចត្រូនិកដូចជា ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ឆ្នាំ២០០១ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អនុក្រឹត្យលេខ២២ស្តីពីការផ្ទេរមជ្ឈការអំណាច តួនាទី និងភារកិច្ចទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ ប្រកាសស្តីពីតួនាទី ភារកិច្ច និងសិទ្ធិរបស់ស្មៀនឃុំ សង្កាត់ ជាដើម និងលិខិតបទដ្ឋានគតិយុត្តសៀវភៅណែនាំផ្សេងៗដែលទាក់ទងនឹងការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការ ។

*វិធីសាស្ត្រសរសេរ*

ព័ត៌មាន និងទិន្នន័យដែលប្រមូលបានត្រូវបានរៀបចំ ចងក្រង និងសរសេរបែបពិពណ៌នា ដោយបង្ហាញអំពីដំណើរការគ្រប់គ្រងឃុំ សង្កាត់តាមបែបវិមជ្ឈការ ។

## ៧. រចនាសម្ព័ន្ធក្នុងការស្រាវជ្រាវ

ការសិក្សាលើប្រធានបទខាងលើត្រូវបានរៀបចំនូវរចនាសម្ព័ន្ធនៃការស្រាវជ្រាវដូចខាងក្រោម៖

- សេចក្តីផ្តើម

- ជំពូកទី១: ជំពូកនេះបង្ហាញអំពី និយមន័យរដ្ឋបាល ឃុំសង្កាត់ វិមជ្ឈការ និងវិសហមជ្ឈការ គោលការណ៍នៃការគ្រប់គ្រងវិមជ្ឈការ និងវិសហមជ្ឈការ ទិសដៅវិមជ្ឈការ ការរៀបចំរដ្ឋបាលឃុំ សង្កាត់ និងការបោះឆ្នោត និងរចនាសម្ព័ន្ធរដ្ឋបាលឃុំ សង្កាត់។

- ជំពូកទី២: ជំពូកនេះបង្ហាញអំពី ប្រព័ន្ធគ្រប់គ្រងរដ្ឋបាល លិខិតរដ្ឋបាល ការគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់ ដែលស្ដីអំពី ប្រភពចំណូលឃុំ សង្កាត់ ថវិកាឃុំ សង្កាត់ ប្រព័ន្ធទូទាត់ និងគណនេយ្យឃុំសង្កាត់ របាយការណ៍ លទ្ធកម្ម ការទូទាត់និងគ្រប់គ្រងថវិកាឃុំ សង្កាត់ ។ នៅក្នុងជំពូក២នេះនឹងមានការបង្ហាញបន្ថែមអំពី ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ការងារបុគ្គលិក ទំនាក់ទំនងរដ្ឋបាលរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ វិធានការវិន័យ និងការបញ្ឈប់មុខតំណែងចំពោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់។

- ជំពូកទី៣: ជំពូកនេះបង្ហាញអំពីសមិទ្ធផលនៃការអនុវត្តគោលនយោបាយគ្រប់គ្រងរដ្ឋបាលតាមបែបវិមជ្ឈការ បង្ហាញអំពីបញ្ហាជួបប្រទះ និងដំណោះស្រាយ។

- សេចក្ដីសន្និដ្ឋាន

- អនុសាសន៍

- ឯកសារពិគ្រោះ

- ឧបសម្ព័ន្ធ

# ជំពូកទី ១
# ទិដ្ឋភាពទូទៅក្នុងការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

# ជំពូកទី ១

# ទិដ្ឋភាពទូទៅក្នុងការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

## ១.១ សញ្ញាណទូទៅក្នុងការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

### ១.១.១ និយមន័យរដ្ឋបាល

ពាក្យ "រដ្ឋបាល" ត្រូវបានគេអោយនិយមន័យផ្សេងៗគ្នាទៅតាមការប្រើប្រាស់ និងទស្សនៈផ្សេងៗ ដែលយើងអាចស្វែងយល់បាន។ ក្នុងនោះយើងឃើញរួមមានដូចជា៖

តាមន័យអក្សរសាស្ត្រ ពាក្យរដ្ឋបាលបានមកពីពាក្យ រដ្ឋ + បាល ។ ពាក្យ "រដ្ឋ" មានន័យថាជា ប្រទេស ដែន បុរី នគរ។ ពាក្យ "បាល" គឺជាការគ្រប់គ្រង ថែរក្សា។ដូចនេះ រដ្ឋបាលគឺការគ្រប់គ្រង ថែរក្សាក្នុងប្រទេស ក្នុងបុរី។[1]

តាមន័យវិទ្យាសាស្ត្ររដ្ឋបាល ត្រូវបានគេឱ្យនិយមន័យថា ជាអង្គការមួយខុសប្លែកពី អង្គការដទៃទៀត ព្រោះវាមានគោលដៅបម្រើដល់ប្រយោជន៍សាធារណៈជាធំ និងដើម្បីឱ្យគោលដៅ នេះមានប្រសិទ្ធិភាព។ រដ្ឋបាលទទួលបានបុព្វសិទ្ធនៃអំណាចសាធារណៈ និងអំណាចផម្មានរូបដែល តម្រូវឱ្យពលរដ្ឋគោរពតាមសេចក្តីសម្រេចរដ្ឋបាល។[2]

### ១.១.២ និយមន័យឃុំ សង្កាត់

ឃុំ សង្កាត់ ជានិតិបុគ្គល ដែលត្រូវជាបំណែងចែករដ្ឋបាលថ្នាក់ទី៣ បន្ទាប់ពីក្រុង ស្រុក ខណ្ឌ ដែលជាបំណែងចែករដ្ឋបាលថ្នាក់ទី២។ ឃុំ សង្កាត់មួយមានភូមិដែលយ៉ាងហោចណាស់ មានចំនួនពី ៣ភូមិ ឬរហូតដល់ទៅ ៣០ភូមិ អាស្រ័យលើស្ថានភាពប្រជាជនរស់នៅ។

ឃុំ សង្កាត់នីមួយៗ ត្រូវមានក្រុមប្រឹក្សាមួយហៅថាក្រុមប្រឹក្សាឃុំ សង្កាត់ ។ ក្រុមប្រឹក្សាឃុំ សង្កាត់ ជាអង្គការដែលតំណាងប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់ខ្លួន និងមានបេសកកម្មបំរើផលប្រយោជន៍ ទូទៅក្នុងឃុំ សង្កាត់របស់ខ្លួន ។[3]

### ១.១.៣. និយមន័យវិមជ្ឈការ និងវិសហមជ្ឈការ

**វិមជ្ឈការ** គឺជារចនាសម្ព័ន្ធរដ្ឋបាលមួយដែលត្រូវបានរៀបចំឡើងជានីតិបុគ្គលសាធារណៈ។ នីតិបុគ្គលនេះ គឺអាចជាសមូហភាពដែនដីដែលគេហៅថាការរៀបចំរចនាសម្ព័ន្ធរដ្ឋបាលបែបវិមជ្ឈការដែនដី និងអាចជា

[1] វចនានុក្រមខ្មែរសម្តេចព្រះសង្ឃរាជជួន ណាត ភាគទី១ ភាគទី២

[2] រៀបរៀងដោយឯកឧត្តមសំ សារ៉ាក់ *សៀវភៅនីតិរដ្ឋបាល និងការងារលិខិតរដ្ឋបាល*

[3] មាត្រា១ អនុក្រឹត្យលេខ ២២ ស្តីពីការផ្ទេរវិមជ្ឈការអំណាចតួនាទីនិងភារកិច្ចទៅឲ្យក្រុមប្រឹក្សាឃុំសង្កាត់

អង្គការស្វយ័តនៃការគ្រប់គ្រងសេវាសាធារណៈប្រកបដោយឯកទេសកម្មដែលគេហៅថា ការរៀបចំរចនាសម្ព័ន្ធរដ្ឋបាលបែបវិមជ្ឈការបច្ចេកទេស ឬសេវា។ វិមជ្ឈការគឺ រដ្ឋាភិបាលប្រគល់អោយក្រុមប្រឹក្សានូវភាពជាម្ចាស់លើមុខងារ សិទ្ធិអំណាច និងធនធាន ដើម្បីឆ្លើយតបសេចក្តីត្រូវការរបស់មូលដ្ឋាន ។ ក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពចំពោះពលរដ្ឋមូលដ្ឋានលើបញ្ហាទាំងនោះ ។

**វិសហមជ្ឈការ** គឺជាបច្ចេកទេសគ្រប់គ្រងរដ្ឋបាលមួយដែលអាជ្ញាធររដ្ឋបាលកណ្តាល បានរំលែកកិច្ចការមួយចំនួនទៅឲ្យអាជ្ញាធររដ្ឋបាលថ្នាក់ក្រោមធ្វើការសម្រេចដោយខ្លួនឯងផ្ទាល់តាមការកំណត់ ហើយសេចក្តីសម្រេចនានានោះតាងនាមឲ្យអាជ្ញាធររដ្ឋបាលកណ្តាល។ រាជរដ្ឋាភិបាល ក្រសួង ឬស្ថាប័នរបស់រាជរដ្ឋាភិបាលផ្ទេរប្រតិភូកម្មមុខងារ និងធនធានឲ្យអង្គភាពនៅថ្នាក់ក្រោមរបស់ខ្លួន ឬឲ្យក្រុមប្រឹក្សានៅថ្នាក់ណាមួយ ដើម្បីអនុវត្តក្នុងនាមរាជរដ្ឋាភិបាល ក្រសួង ឬស្ថាប័នរបស់រដ្ឋាភិបាល ហើយអង្គភាពឬក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល ក្រសួង ឬស្ថាប័នរបស់រាជរដ្ឋាភិបាលដោយអនុលោមទៅតាមលក្ខខណ្ឌនៃប្រតិភូកម្ម ។

### ១.១.៤ ទិសដៅវិមជ្ឈការ

ការគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់តាមបែបវិមជ្ឈការមានទិសដៅនៅក្នុងការផ្តល់ឱកាសដល់ប្រជាពលរដ្ឋឲ្យចូលរួមកាន់តែទូលំទូលាយនៅក្នុងការធ្វើសេចក្តីសមាជិកដែលមានផលប៉ះពាល់ទៅលើជីវភាពរស់នៅនិងអនាគតរបស់ខ្លួន ដែលប្រជាពលរដ្ឋអាចចូលរួមនៅក្នុងការបញ្ចេញមតិយោបល់ទៅលើការសម្រេចនានាដែលជះឥទ្ធិពលទៅលើជីវភាពរស់នៅប្រចាំថ្ងៃរបស់ខ្លួន។ ម្យ៉ាងវិញទៀតទិសដៅវិមជ្ឈការនេះគឺធ្វើការលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ អភិបាលកិច្ចល្អ និងគុណភាពនៃជីវភាពរស់នៅថែមទាំងធានាការអភិវឌ្ឍប្រកបដោយចីរភាពរួមទាំងការផ្តល់សេវាជាមូលដ្ឋានផងដែរ។ ចំណុចសំខាន់ៗខាងលើនេះគឺជាទិសដៅចំបងនៃការគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់តាមបែបវិមជ្ឈការ ។

#### ក. ការផ្តល់ឱកាសឲ្យប្រជាពលរដ្ឋចូលរួម

តាមរយៈប្រព័ន្ធអភិបាលកិច្ចមូលដ្ឋាននៅថ្នាក់ឃុំ ប្រជាពលរដ្ឋគ្រប់រូបមិនថាស្ត្រី បុរស ចាស់ ក្មេង ជនងាយរងគ្រោះ សុទ្ធតែមានសិទ្ធិចូលរួមយ៉ាងសកម្មនៅក្នុងសកម្មភាពរបស់ឃុំ សង្កាត់នឹងដំណើរការនៃការអភិវឌ្ឍន៍មូលដ្ឋានដូចជាការបញ្ចេញមតិ និងការចូលរួមចំណែកតាមរយៈមធ្យោបាយផ្សេងៗ ។ ប្រជាពលរដ្ឋ

[4] ហៀង សាង_*សៀវភៅនីតិរដ្ឋបាលទូទៅ* (បោះពុម្ពលើកទី៤ ឆ្នាំ២០១៧ះរោងពុម្ពស៊ី ហេង) ទំព័រ ១៦៦

[5] ហៀង សាង_*សៀវភៅនីតិរដ្ឋបាលទូទៅ* (បោះពុម្ពលើកទី៤ ឆ្នាំ២០១៧ះរោងពុម្ពស៊ី ហេង) ទំព័រ ១៥៤

មានសិទ្ធិលើកឡើងពីសេចក្តីត្រូវការ និងផលប្រយោជន៍របស់ខ្លួនតាមរយៈនីតិវិធី និងយន្តការដែលបានកំណត់ក្នុងលិខិតបទដ្ឋាន និងសេចក្តីណែនាំនានា ។ ការចូលរួមទាំងនោះក៏រួមមានដូចជា ការចូលរួមបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដែលប្រជាជនគិតថាអាចធ្វើជាតំណាងឲ្យនូវប្រយោជន៍របស់ពួកគាត់បានប្រសើរបំផុត ហើយប្រជាជនមានការទុកចិត្តជ្រើសរើសនូវក្រុមប្រឹក្សាឃុំ សង្កាត់នេះធ្វើជាតំណាងរបស់ខ្លួននៅក្នុងឃុំ សង្កាត់របស់ខ្លួន ។ វាជាសិទ្ធិពេញលេញដែលប្រជាពលរដ្ឋទទួលបានក្នុងការជ្រើសរើសអ្នកដឹកនាំនៅក្នុងឃុំ សង្កាត់របស់ខ្លួនដោយស្របទៅតាមលក្ខខណ្ឌនៃការបោះឆ្នោត ។ ប្រជាពលរដ្ឋក្នុងឃុំ សង្កាត់ក៏អាចធ្វើការបង្កើតទំនាក់ទំនងជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ចំពោះការងារដែលពាក់ព័ន្ធ និងការអភិវឌ្ឍន៍ឃុំ សង្កាត់របស់ខ្លួន ដោយការលើកឡើងអំពីបញ្ហា និងផលប្រយោជន៍របស់ពួកគាត់ជាមួយនឹងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីទទួលបានការចាត់ចែងពីក្រុមប្រឹក្សាឃុំដូចជាមេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង ស្មៀនឃុំជាដើម ។ ក្នុងនោះផងដែរប្រជាពលរដ្ឋអាចធ្វើការតាមដានទៅលើការអនុវត្តនូវសេចក្តីសម្រេចផ្សេងៗរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការផ្តល់សេវាជូនប្រជាពលរដ្ឋ ការអនុវត្តនូវគម្រោងអភិវឌ្ឍន៍ផ្សេងៗ ក៏ដូចជាការអនុវត្តសកម្មភាពនានានៅក្នុងមូលដ្ឋានរបស់ខ្លួន ដែលប្រជាពលរដ្ឋមានសិទ្ធិនៅក្នុងការទទួលដឹងនូវព័ត៌មានទាំងឡាយពីក្រុមប្រឹក្សាឃុំ សង្កាត់ ឬតាមរយៈការស្នើសុំទៅកាន់ឃុំ សង្កាត់ ដើម្បីទទួលបាននូវព័ត៌មានផ្សេងៗដែលខ្លួនចង់ដឹង។[6]

ដូច្នេះហើយការលើកកម្ពស់នៅក្នុងការចូលរួមរបស់ប្រជាពលរដ្ឋ គឺជាកត្តាដ៏សំខាន់សម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់ ពីព្រោះការចូលរួមនេះអាចជួយឲ្យក្រុមប្រឹក្សាឃុំ សង្កាត់បានស្វែងយល់កាន់តែច្បាស់អំពីតម្រូវការក៏ដូចជាផលប្រយោជន៍របស់ប្រជាពលរដ្ឋរបស់ខ្លួន ។ លើសពីនេះទៅទៀតអាចដឹងអំពីសុខទុក្ខ និងបញ្ហាផ្សេងៗដែលប្រជាពលរដ្ឋត្រូវការដំណោះស្រាយពីអាជ្ញាធរមូលដ្ឋាន ។ ប្រសិនបើប្រជាពលរដ្ឋបានចូលរួមប្រជាពលរដ្ឋមានអារម្មណ៍ថានឹងមានការទទួលខុសត្រូវចំពោះការអភិវឌ្ឍន៍នៅក្នុងមូលដ្ឋានរបស់ខ្លួនផងដែរ ។

**ខ. ការលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ អភិបាលកិច្ចល្អ និងគុណភាពនៃជីវភាពរស់នៅ**

ទិសដៅមួយនៅក្នុងទិសដៅវិមជ្ឈការការគ្រប់គ្រងឃុំ សង្កាត់គឺ ជំរុញឲ្យមានអភិបាលកិច្ចល្អនៅក្នុងមូលដ្ឋាន ។ អភិបាលកិច្ចល្អ គឺជាការអនុវត្តការងារឲ្យបានសមស្របទៅនឹងទិដ្ឋភាពសំខាន់ៗ ដែលមានដូចខាងក្រោម ៖

[6] ក្រសួងមហាផ្ទៃ, *ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការ* ឆ្នាំ២០១៧

- ក្រុមប្រឹក្សាឃុំសង្កាត់ត្រូវបំពេញការងារអនុលោមតាមច្បាប់និងលិខិតបទដ្ឋាននានា ដែលមានន័យថា ក្រុមប្រឹក្សាឃុំ សង្កាត់គឺទទួលខុសត្រូវនៅក្នុងការអនុវត្តការងាររបស់ខ្លួន ដែលគោរពតាមច្បាប់បទដ្ឋានគតិយុត្តិនានាដែលមានចែង និងកំណត់ពីសិទ្ធិផ្សេងៗនៅក្នុងការអនុវត្តការងាររបស់ខ្លួន ។

- ក្រុមប្រឹក្សាឃុំសង្កាត់ត្រូវបោះឆ្នោតដោយប្រជាពលរដ្ឋរបស់ខ្លួនតាមបែបប្រជាធិបតេយ្យ ដែលមានន័យថាប្រជាពលរដ្ឋបានជ្រើសរើសនូវតំណាងរបស់ខ្លួនក្នុងការបម្រើទៅដល់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន ។ ដូចនេះអ្វីដែលក្រុមប្រឹក្សាឃុំ សង្កាត់បានសម្រេចនឹងអនុវត្តគឺជាការទទួលខុសត្រូវលេងចំពោះប្រជាពលរដ្ឋរបស់ខ្លួន ។ ការសម្រេចនិងការអនុវត្តទាំងនោះត្រូវឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ និងមានការផ្តល់ព័ត៌មានពីការប្រើប្រាស់ធនធានដែលខ្លួនមាន ហើយធានាថាការប្រើធនធានទាំងនោះពិតជាបានប្រើប្រាស់ ដើម្បីឲ្យផលប្រយោជន៍របស់ប្រជាពលរដ្ឋប្រកបដោយ និងគណនេយ្យភាព ។

- ក្រុមប្រឹក្សាឃុំសង្កាត់ត្រូវមានតម្លាភាពក្នុងការងារទាំងអស់ដែលខ្លួនបានបំពេញ ។ ក្រុមប្រឹក្សាឃុំសង្កាត់ត្រូវជម្រាបជូនសាធារណៈជនពីកិច្ចការនានាដែលខ្លួនបានពិភាក្សា ឬពីសេចក្តីសម្រេចដែលខ្លួនបានធ្វើ ដូចជាការផ្សព្វផ្សាយដល់សាធារណជន និងការទទួលមតិយោបល់របស់សាធារណជន អំពីការកសាងផែនការ និងការរៀបចំថវិកាឃុំ សង្កាត់ ការផ្សព្វផ្សាយជាសាធារណៈអំពីសេចប្តីសម្រេចរបស់ក្រុមប្រឹក្សា ឃុំសង្កាត់តាមរយៈការបិទផ្សាយលើក្តារខៀនព័ត៌មានឃុំ សង្កាត់ ឬតាមមធ្យោបាយផ្សេងទៀតនូវមូលដ្ឋាន ។

- ការចូលរួមរបស់ប្រជាពលរដ្ឋគឺជាសមាសធាតុទាំងសំខាន់មួយទៀតនៅក្នុងអភិបាលកិច្ចល្អ ។

**គ. ការធានាដល់ការអភិវឌ្ឍប្រកបដោយចីរភាព រួមទាំងការផ្តល់សេវាជាមូលដ្ឋាន**

ក្រុមប្រឹក្សាឃុំ សង្កាត់ស្ថិតនៅកៀកប្រជាពលរដ្ឋ ហើយអាចដឹងច្បាស់អំពីសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ ។ ក្រុមប្រឹក្សាឃុំសង្កាត់អាចរៀបចំផែនការនិងកម្មវិធីដើម្បីលើកកម្ពស់និងកែលំអជីវភាពរស់នៅរបស់ប្រជាពលរដ្ឋដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។ ដូច្នេះក្រុមប្រឹក្សាឃុំសង្កាត់អាចប្រើប្រាស់ធនធានរបស់ឃុំសង្កាត់អ្នកមានប្រសិទ្ធភាពក្នុងការឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋរបស់ខ្លួន ។

ប្រជាពលរដ្ឋអាចពិនិត្យមើលការប្រើប្រាស់ធនធានរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ថាតើការប្រើប្រាស់ធនធានទាំងនោះពិតជាបម្រើឲ្យផលប្រយោជន៍របស់ខ្លួនដែរឬទេ ។ ប្រសិនបើប្រជាពលរដ្ឋបានចូលរួមនៅក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍កម្មវិធីវិនិយោគនិងការអនុវត្តគម្រោងនានានៅមូលដ្ឋានរបស់ខ្លួននោះ នឹងធ្វើឲ្យពួកគាត់កាន់តែទទួលខុសត្រូវច្រើនថែមទៀតនៅក្នុងការនៅវត្តអណ្តែតនោះ ។[7]

[7] ក្រសួងមហាផ្ទៃ, *ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការ* ឆ្នាំ២០១៧

## ១.២ ការរៀបចំរដ្ឋបាលឃុំ សង្កាត់

### ១.២.១ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបាន រដ្ឋសភាអនុម័តកាលពីថ្ងៃ ទី១៨ ខែមករា ឆ្នាំ២០០១ នាសម័យប្រជុំពេញអង្គលើកទី៥ នីតិកាលទី២ ហើយដែលព្រឹទ្ធសភា បានអនុម័តយល់ស្របតាមលើទំរង់ និង គតិច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី១៤ ខែកុម្ភៈឆ្នាំ២០០១ នាសម័យប្រជុំពេញអង្គលើកទី៤ នីតិកាលទី១ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញតាមសេចក្តីសំរេចលេខ ០៤២,០០៤,២០០១ កបធ.ច ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០០១។

ឃុំ សង្កាត់នីមួយៗត្រូវមានក្រុមប្រឹក្សាមួយដែលត្រូវបានបោះឆ្នោតជ្រើសរើសឡើង ដោយប្រជាពលរដ្ឋនៃឃុំសង្កាត់របស់ខ្លួនតាមការបោះឆ្នោតជាទូទៅ ជាសកល ដោយសេរី ត្រឹមត្រូវ និង យុត្តិធម៌ ដោយស្មើភាព ដោយ ចំពោះដោយសំងាត់ស្របទៅតាមនីតិវិធីដូចមានចែងក្នុងច្បាប់ពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ត្រូវធ្វើឡើងរៀងរាល់ ៥ ឆ្នាំម្តង ហើយ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ត្រូវរៀបចំធ្វើឡើងនៅថ្ងៃជាមួយគ្នា ។ កាលបរិច្ឆេទនៃការបោះឆ្នោតត្រូវកំណត់ដោយនាយករដ្ឋមន្ត្រី តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។ ការបោះឆ្នោតត្រូវធ្វើនៅថ្ងៃអាទិត្យតែមួយថ្ងៃ។ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ សង្កាត់ អាណត្តិទី៤ ឆ្នាំ២០១៧ ប្រព្រឹត្តទៅថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៧ ។

ការរៀបចំចាត់ចែងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ធ្វើឡើងដោយគណៈកម្មាធិការជាតិរៀបចំ ការបោះឆ្នោត (គ.ជ.ប)ដែលបង្កើតឡើងតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំ ណាងរាស្ត្រ។ គណៈកម្មាធិការជាតិ រៀបចំការបោះឆ្នោត ត្រូវតែងតាំងគណកម្មការខេត្ត ក្រុងរៀបចំ ការបោះឆ្នោត និងគណកម្មការឃុំ-សង្កាត់រៀបចំការ បោះឆ្នោត។ គណកម្មការឃុំសង្កាត់រៀបចំការ បោះឆ្នោតត្រូវមានការិយាល័យ ចុះឈ្មោះអ្នកបោះឆ្នោត និង ការិយាល័យបោះឆ្នោត។ រីឯសមាស ភាពការិយាល័យចុះឈ្មោះអ្នកបោះឆ្នោត និងការិយាល័យបោះឆ្នោតត្រូវតែងតាំងឡើងដោយ គណកម្មាធិការជាតិរៀបចំការបោះឆ្នោត។ សមាជិក និង មន្ត្រីគ្រប់រូបនៃគណៈកម្មាធិការជាតិរៀបចំ ការបោះឆ្នោត គណកម្មការខេត្តរៀបចំការបោះឆ្នោត គណកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ការិយាល័យចុះឈ្មោះអ្នកបោះឆ្នោត និង ការិយាល័យបោះឆ្នោតត្រូវប្រកាន់ជំហរឯករាជ្យមិន លំអៀង និង ស្មោះត្រង់ក្នុងការអនុវត្ត អំនាច មុខងារ ភារកិច្ចរបស់ខ្លួន[៨]។ ដំណើរការប្រព្រឹត្តទៅនៃមានដូចតទៅ[៩] ៖

[៨] មាត្រា១-៩ នៃច្បាប់ស្តីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់

✓ មុនពេលរៀបចំបោះឆ្នោត

មុនពេលការបោះឆ្នោតត្រូវបានប្រព្រឹត្តទៅ ការរៀបចំដំណើរការនៃការបោះឆ្នោតជាសមត្ថកិច្ចរបស់គណៈកម្មា ធិការជាតិរៀបចំការបោះឆ្នោតដែលមានអំណាច និងមុខងារដូចជា

- ➢ រៀបចំ ចាត់ចែងការងារផ្សេងៗសំរាប់ចុះឈ្មោះបោះឆ្នោត ធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះអ្នកបោះឆ្នោត រៀបចំបញ្ជីឈ្មោះអ្នកបោះឆ្នោត និង ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ សង្កាត់
- ➢ ចាត់វិធានការចាំបាច់ ដើម្បីធានាអោយការចុះឈ្មោះ អ្នកបោះឆ្នោត ការធ្វើបច្ចុប្បន្នភាព បញ្ជីឈ្មោះអ្នកបោះឆ្នោត ការរៀបចំបញ្ជីឈ្មោះអ្នកបោះឆ្នោត និង ការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និង យុត្តិធម៌
- ➢ កំនត់ និង រៀបចំបង្កើតការិយាល័យចុះឈ្មោះអ្នកបោះឆ្នោត
- ➢ រៀបចំ និង ផ្តល់សុពលភាពលើបញ្ជីឈ្មោះអ្នកបោះឆ្នោត
- ➢ ពិនិត្យរៀបចំបញ្ជីឈ្មោះអ្នកបោះឆ្នោតជារៀងរាល់ឆ្នាំ
- ➢ បណ្តុះបណ្តាលមន្ត្រីបោះឆ្នោត និង ណែនាំដល់បេក្ខជន ភ្នាក់ងារនៃគណបក្សនយោបាយ និងអ្នកសង្កេតការណ៍អំពីនីតិវិធីផ្សេងៗ សំរាប់ការធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះអ្នកបោះឆ្នោត ការចុះឈ្មោះអ្នកបោះឆ្នោត ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និង បទប្បញ្ញត្តិទាំងឡាយនៃច្បាប់នេះ
- ➢ ធានាអោយសាធារណៈជនទូទៅ មានការយល់ដឹងអំពីគោលបំនងនៃការបោះឆ្នោត
- ➢ រៀបចំនីតិវិធីនៃការធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះអ្នកបោះឆ្នោត ការចុះឈ្មោះអ្នកបោះឆ្នោត ការបោះឆ្នោត និង ការរាប់សន្លឹកឆ្នោត ប្រកបដោយតំលាភាព និង ដោយមានការចូលរួមពីអ្នកសង្កេតការណ៍ និង ភ្នាក់ងារនៃគណបក្សនយោបាយ
- ➢ ធានាអោយមានទំនាក់ទំនងទៀងទាត់រវាង គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតជាមួយបេក្ខជនភ្នាក់ងារនៃគណបក្សនយោបាយ និង អ្នកសង្កេតការណ៍
- ➢ អនុវត្តតាមការកំនត់ និង នីតិវិធីផ្សេងៗដែលទាក់ទងដល់ការត្រួតពិនិត្យ ការគ្រប់គ្រងហិរញ្ញវត្ថុដែលរៀបចំដោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

✓ កំឡុងពេលបោះឆ្នោត ៖ ការបោះឆ្នោតនឹងចាប់ផ្តើមនៅម៉ោង ៧ព្រឹក រហូតដល់ ៤ល្ងាច

- ➢ គ្រប់គ្រងនីតិវិធី នៅក្នុងការិយាល័យបោះឆ្នោត

---

[9] មាត្រា១០ នៃច្បាប់ស្តីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់

- ធានាអោយជនគ្រប់រូបមានសិទ្ធិចូលរួមប្រកបដោយសុវត្ថិភាព និង គ្មានការភ័យខ្លាច រឺ ការបំភិតបំភ័យក្នុងដំនើរការធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះអ្នកបោះឆ្នោត ចុះឈ្មោះអ្នកបោះឆ្នោត និង ការបោះឆ្នោត
- ការពារសុវត្ថិភាពក្នុងដំនើរការពិនិត្យបញ្ជីឈ្មោះអ្នកបោះឆ្នោត ដំនើរការចុះឈ្មោះអ្នកបោះឆ្នោត ដំនើរការបោះឆ្នោត ដំនើរការរាប់សន្លឹកឆ្នោត និង ការពារសុវត្ថិភាព សម្ភារឧករណ៍ គ្រឿងសង្ហារឹមសំរាប់ដំនើរការបោះឆ្នោតទាំងមូល

✓ ក្រោយពេលបញ្ចប់ការបោះឆ្នោត

- រាប់សន្លឹកឆ្នោតតាមមណ្ឌលនីមួយៗ ដោយមានការចូលរួមពីតំណាងគណបក្សទាំងអស់ ភ្នាក់ងារ គ.ជ.ប និងអ្នកអង្កេតការ
- សំរេចលើបន្តឹងតវ៉ាទាក់ទងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ លើកលែងតែបន្តឹងតវ៉ាទាក់ទងនឹងសមត្ថកិច្ចតុលាការ
- ធ្វើសេចក្តីរាយការណ៍ជូនរដ្ឋសភា និងព្រឹទ្ធសភា ស្តីពីការគ្រប់គ្រងការប្រព្រឹត្តទៅ និងលទ្ធផលនៃការបោះឆ្នោត ក្នុងកំលុងពេលកៅសិប (៩០) ថ្ងៃ បន្ទាប់ពីថ្ងៃបោះឆ្នោត ។ អំនាច មុខងារ និង ភារកិច្ច ដូចមានចែងក្នុងមាត្រា ៧ ៨ ៩ និង មាត្រា ១០ នៃច្បាប់នេះត្រូវបន្ថែមទៅលើអំនាច មុខងារ និង ភារកិច្ចដែលបានតំរូវ រឺ បានប្រគល់អោយគណកម្មាធិការជាតិរៀបចំការបោះឆ្នោតតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។

### ១.២.២.លក្ខខណ្ឌក្នុងការឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

ការឈរឈ្មោះឱ្យគេបោះឆ្នោតជាក្រុមប្រឹក្សាឃុំ-សង្កាត់ ប្រជាពលរដ្ឋដែលមានបំណងក្លាយជាបេក្ខជនឈរ ឈ្មោះអាចឈរឈ្មោះបាន។ [10]ដើម្បីក្លាយជាបេក្ខជនឈរឈ្មោះបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់ ត្រូវគោរពនូវលក្ខខណ្ឌដូចជា

- មានសញ្ជាតិខ្មែរពីកំណើត
- ចេះអាន និង សរសេរអក្សរខ្មែរ
- បានចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតក្នុងឃុំ សង្កាតដែលខ្លួនមានបំនងឈរឈ្មោះបោះឆ្នោត

[10] មាត្រា១៩ នៃច្បាប់ស្តីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់

- មានអាយុយ៉ាងតិច ២៥ឆ្នាំ គិតមកទល់ថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។

ប៉ុន្តែ[11]ការឈរឈ្មោះជាបេក្ខជនត្រូវបានហាមឃាត់ក្នុងលក្ខខណ្ឌ

- សមាជិករដ្ឋសភា ព្រឹទ្ធសភា សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ សមាជិករាជរដ្ឋាភិបាល និង ចៅក្រម
- ប្រតិភូរាជរដ្ឋាភិបាល អភិបាល រឺ អភិបាលរងខេត្ត ក្រុង អភិបាល អភិបាលរងស្រុក ខ័ណ្ឌ
- សមាជិកគណកម្មាធិការជាតិរៀបចំការបោះឆ្នោត គណកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោត គណកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត មន្ត្រីការិយាល័យចុះឈ្មោះអ្នកបោះឆ្នោត មន្ត្រីការិយាល័យបោះឆ្នោត បុគ្គលិកបំរើការងារក្នុងគណកម្មាធិការជាតិរៀបចំការបោះឆ្នោត និង គណកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ ថ្នាក់
- មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ កងយោធពលខេមរភូមិន្ទ រឺ នគរបាលជាតិក្នុងមុខតំនែង
- ព្រះសង្ឃ រឺ បព្វជិតសាសនានៃសាសនាណាមួយ
- ស្មៀនឃុំ សង្កាត់ណាមួយ ។

ជនគ្រប់រូបដែលមានបំនងឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបញ្ចូលឈ្មោះរបស់ខ្លួន ទៅ ក្នុងបញ្ជីបេក្ខជននៃគណបក្សនយោបាយ។ បញ្ជីបេក្ខជននីមួយៗត្រូវរៀបចំដោយគណបក្សនយោបាយដែលបាន ចុះបញ្ជីត្រឹមត្រូវតាមល័ក្ខខ័ណ្ឌដូចមាន ចែងក្នុងច្បាប់ស្តីពីគណបក្សនយោបាយ ។ បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗត្រូវមានឈ្មោះបេក្ខជនតាមលំដាប់លេខរៀង ។ បេក្ខជនម្នាក់ៗត្រូវមានឈ្មោះក្នុងបញ្ជីបេក្ខជននៃគណបក្សនយោបាយតែមួយប៉ុណ្ណោះ ។

[12]ពាក្យសុំបញ្ជីបេក្ខជនត្រូវភ្ជាប់មកជាមួយនូវ :

- សេចក្តីចំលងលិខិតបញ្ជាក់ការចុះបញ្ជីគណបក្សនយោបាយនៅក្រសួងមហាផ្ទៃមួយច្បាប់
- អាសយដ្ឋាននៃទីស្នាក់ការកណ្តាលគណបក្សនយោបាយ អាសយដ្ឋានទីស្នាក់ការគណបក្សនយោបាយក្នុងឃុំ សង្កាត់ និងឈ្មោះអ្នកតំនាងប្រចាំទីស្នាក់ការគណបក្សនយោបាយក្នុងឃុំ សង្កាត់ ដែលបានដាក់ ស្នើបញ្ជីបេក្ខជន
- បញ្ជីរាយនាមបេក្ខជន ដែលមានចំនួនបេក្ខជនយ៉ាងហោចណាស់ស្មើនឹងពីរដងនៃចំនួនសមាជិក ក្រុមប្រឹក្សាក្នុងឃុំ សង្កាត់

[11] មាត្រា២០ នៃច្បាប់ស្តីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់

[12] មាត្រា១០១ នៃច្បាប់ស្តីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់

- នាមត្រកូល នាមខ្លួន អាសយដ្ឋាន និង លេខប័ណ្ណបោះឆ្នោត រឺ វិញ្ញាបនប័ត្រជំនួសប័ណ្ណបោះ ឆ្នោតរបស់បេក្ខជនគ្រប់រូបនៅក្នុងបញ្ជីបេក្ខជន
- ជីវប្រវត្តិសង្ខេបដែលបំពេញផ្ទាល់ដៃរបស់បេក្ខជនម្នាក់ៗ និង រូបថតបេក្ខជនម្នាក់ចំនួន៣សន្លឹក ទំហំ ៤*៦ ថតចំពីមុខ តាមគំរូដែលកំនត់ដោយគណកម្មាធិការជាតិរៀបចំការបោះឆ្នោត
- ឈ្មោះគណបក្សជាអក្សរពេញ ជាអក្សរកាត់ និង សញ្ញាសំគាល់គណបក្សនយោបាយ ។

ម៉្យាងទៀតដើម្បីឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់គណបក្សនយោបាយត្រូវដាក់ពាក្យសុំចុះ បញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត តាមការកំនត់របស់គណកម្មាធិការជាតិរៀបចំការបោះឆ្នោត ទៅគណកម្មការ ឃុំ សង្កាតរៀបចំការបោះឆ្នោតយ៉ាងតិច កៅសិប (៩០)ថ្ងៃ មុនថ្ងៃបោះឆ្នោត ។ ពាក្យសុំត្រូវចុះហត្ថលេខាដោយប្រធាន គណបក្សនយោបាយ រឺ តំណាងដែលបានទទួលការផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរពីប្រធានគណបក្សនយោបាយនោះ ។

### ១.២.៣ តួនាទី និងមុខងារឃុំ-សង្កាត់

[13]ក្នុងការបំពេញភារកិច្ច មេឃុំ/សង្កាត់ត្រូវផ្អែកលើមូលដ្ឋានច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធព្រមទាំងត្រូវ មានអព្យាក្រឹតភាពនៅក្នុងសកម្មភាពការងាររបស់ខ្លួន។

#### ក. តំណាងឱ្យរាស្ត្រប្រជា

- ការពារផលប្រយោជន៍រាស្ត្រប្រជាដែលរស់នៅក្នុងឃុំ/សង្កាត់
- ការពារ និងគោពសិទ្ធិសេរីភាពរបស់រាស្ត្រប្រជាក្នុងឃុំ/សង្កាត់
- ការណែនាំប្រជាពលរដ្ឋក្នុងការតវ៉ា ឬធ្វើសំណើរទៅអជ្ញាធរដែលពាក់ព័ន្ធ ឬធ្វើបណ្តឹងទៅតុលាការ ដើម្បីការពារផលប្រយោជន៍របស់រាស្ត្រប្រជានៅក្នុងឃុំ/សង្កាត់
- បំផុសឱ្យប្រជាជនឱ្យជួយបំពេញកាតព្វកិច្ច ដែលជាផលប្រយោជន៍រួមរបស់ឃុំ/សង្កាត់។ ឧទាហរណ៍ ៖ ជួសជុលផ្លូវ ដាំដើមឈើជាដើម។ល។
- ផ្តល់មតិទៅអជ្ញាធរថ្នាក់លើពីបញ្ហាដែលពាក់ព័ន្ធផលប្រយោជន៍រាស្ត្រប្រជា។

#### ខ. តំណាងឱ្យរដ្ឋ

- ជាអ្នកទទួលខុសត្រូវចំពោះការដឹកនាំរដ្ឋបាលឃុំ/សង្កាត់ និង នយោបាយនៅក្នុងឃុំ/សង្កាត់
- គ្រប់គ្រង និង ធ្វើស្ថិតិរាស្ត្រប្រជា
- គ្រប់គ្រងរាយនាមប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោត និង ស្ថិតិជនបរទេស

[13] ហៀង សាង_*សៀវភៅនីតិរដ្ឋបាលទូទៅ* (បោះពុម្ពលើកទី៤ ឆ្នាំ២០១៧៖រោងពុម្ពស៊ី ហេង) ទំព័រ ១៤៥

- ដឹកនាំនគរបាលប៉ុស្តិ៍រដ្ឋបាល

- ជាមន្ត្រីអត្រានុកូលដ្ឋាន "ក៣"

- សហការ និង ជួយមន្ត្រីពន្ធដារដែលមានបេសកកម្មប្រមូលពន្ធដារ នៅក្នុងឃុំ/សង្កាត់របស់ខ្លួន

- សហការជាមួយឃុំ/សង្កាត់ ដែលមាននៅជិតព្រំប្រទល់គ្នា នៅក្នុងការរក្សាសណ្តាប់ធ្នាប់សាធារណៈ និងការបង្ការ ឬ/និង បង្ក្រាបបទល្មើសនានា។

### ១.២.៤ អាណត្តិឃុំសង្កាត់

ក្រុមប្រឹក្សាឃុំ/សង្កាត់ នៅកម្ពុជាមានអាណត្តិការងារចំនួន ៥ឆ្នាំ។

## ១.៣ រចនាសម្ព័ន្ធរដ្ឋបាលឃុំ-សង្កាត់

ប្រទេសកម្ពុជាបានរៀបចំចងក្រងឡើងវិញនូវប្រព័ន្ធរដ្ឋបាលដូចមានចែងក្នុងរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ ។ តាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ឆ្នាំ ២០០២ នៅប្រទេសកម្ពុជាបានរៀបចំការបោះឆ្នោតរបស់ខ្លួនស្របតាមប្រជាធិបតេយ្យដោយធានាសេរីភាពភាពត្រឹមត្រូវនិងយុត្តិធម៌ក្នុងការបោះឆ្នោតជ្រើសរើសតំណាងក្រុមប្រឹក្សាឃុំសង្កាត់។ រចនាសម្ព័ន្ធក្នុងរដ្ឋបាលឃុំសង្កាត់មានដូចតទៅ ៖

### ១.៣.១ ក្រុមប្រឹក្សាឃុំ-សង្កាត់

រដ្ឋបាលឃុំ សង្កាត់ ត្រូវដឹកនាំគ្រប់គ្រងដោយក្រុមប្រឹក្សាឃុំ សង្កាត់។ ក្រុមប្រឹក្សាឃុំ-សង្កាត់ត្រូវជ្រើសរើសឡើង តាមការបោះឆ្នោតដោយប្រជាពលរដ្ឋនៃឃុំ សង្កាត់របស់ខ្លួនស្របទៅតាមនីតិវិធីដែលកំនត់ដោយច្បាប់ស្តីពីការ បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់។ ក្រុមប្រឹក្សាឃុំ សង្កាត់មានសមាជិកពី៥ ទៅ ១១រូបផ្អែកតាមប្រជា សាស្ត្រ និងភូមិសាស្ត្ររបស់ខ្លួន។ ចំនួនជាក់ស្តែងនៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗត្រូវកំនត់ដោយអនុក្រឹត្យតាមសំនើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ ចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានកំនត់រួចហើយអាចធ្វើ ការផ្លាស់ប្តូរបានដោយអនុក្រឹត្យតាមសំនើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃអាស្រ័យដោយការផ្លាស់ប្តូរនៃ ប្រជាសាស្ត្រ និងភូមិសាស្ត្រ។ សមាជិកបន្ថែមនៃក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវជ្រើសរើសតាមនីតិវិធីដូចសមាជិកដ៏ទៃទៀតដែរ។

ឧទាហរណ៍ ៖ ក្នុងឃុំសង្កាត់មួយអាចមានសមាជិកនៃក្រុមប្រឹក្សា ៥ / ៧/ ៩/ ១១រូប។

ក្រុមប្រឹក្សាឃុំ សង្កាត់ជាអង្គការដែលតំណាងឱ្យប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់ ឬឃុំ សង្កាត់របស់ខ្លួន និងជា ភ្នាក់ងារតំណាងអោយរដ្ឋតាមការប្រគល់អំណាចអំពីរដ្ឋ។ ដូចនេះក្រុមប្រឹក្សាមានតួនាទីអនុវត្តនៅគោលនយោបាយអភិបាលកិច្ចល្អដោយចាត់ចែងប្រើប្រាស់ធនធាននានា ដែលប្រកបដោយចីរភាពដើម្បីបម្រើផលប្រយោជន៍របស់ប្រជាពលរដ្ឋ និង គោរពផលប្រយោជន៍ជាតិស្របទៅតាមគោលនយោបាយរបស់រដ្ឋ។ ក្រុម

ប្រឹក្សាដើរតួនាទីយ៉ាងសំខាន់ ជាអ្នកបំពេញផលប្រយោជន៍ប្រជាពលរដ្ឋក្នុងនាមជាអ្នកតំណាងឱ្យប្រជារាស្ត្រ ដូចដែលមានចែងដូចជាការការពារផលប្រយោជន៍ សិទ្ធិសេរីភាពជូនពលរដ្ឋ ចាត់ចែងដោះស្រាយបញ្ហាជូនប្រជាជនក្នុងតំបន់ ការរួបរួមដើម្បីអភិវឌ្ឍឃុំ សង្កាត់ និងបម្រើដល់ប្រយោជន៍ជាតិក្នុងនាមជាអ្នកតំណាងរដ្ឋក្នុងការទទួលខុសត្រូវក្នុងការដឹកនាំឃុំ សង្កាត់អោយមានតម្លាភាព និងចិរភាពតាមសិទ្ធិអំណាចដែលរដ្ឋបានផ្តល់អោយ។

### **១.៣.២ មេឃុំ/ចៅសង្កាត់**

រដ្ឋបាលឃុំ សង្កាត់ ត្រូវដឹកនាំគ្រប់គ្រងដោយក្រុមប្រឹក្សាឃុំ សង្កាត់ ។ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវមានប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ជាមេឃុំ ឬចៅសង្កាត់ ។ ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ឬមេឃុំត្រូវបានជ្រើសរើសចេញពីបេក្ខជនលេខរៀងលើគេបង្អស់នៃបញ្ជីបេក្ខជន ដែលទទួលបានសម្លេងឆ្នោតច្រើនជាងគេបង្អស់ ។

ក្នុងកិច្ចការរដ្ឋបាលមេឃុំ ចៅសង្កាត់មានភារកិច្ចចូលរួមកិច្ចប្រជុំរបស់ក្រុមប្រឹក្សា និង គណៈកម្មាធិការជំនួយការនានារបស់ឃុំ សង្កាត់ ហើយធ្វើការលើកមតិយោបលដែលជួយបង្កើនការអភិវឌ្ឍន៍ កសាងធនធានរបស់ឃុំ សង្កាត់ និងអំពីការរៀបចំ អនុម័ត និងត្រួតពិនិត្យផែនការអភិវឌ្ឍ និងចិរកាថវិកាឃុំ សង្កាត់។ ក្រៅពីនេះ ការស្វែងជំនួយ ផ្សេងៗពីរដ្ឋាភិបាល អង្គការជាតិ អន្តរជាតិ ផ្នែកឯកជន ឬសម្បុរសជននានាក៏ជាការលើកមតិយោបលពីមេឃុំ ចៅសង្កាត់ផងដែរ។ រាល់សកម្មភាពនានាក្នុងការអនុវត្តន៍គោលនយោបាយត្រូវតែមានរបាយការណ៍ជូនក្រុមប្រឹក្សា ដើម្បីធានាការអនុវត្តមានភាពត្រឹមត្រូវ។

ក្រៅពីតួនាទីជាប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ដែលទទួលខុសត្រូវលើការគ្រប់គ្រងកិច្ចការរដ្ឋបាលផ្សេងៗក្នុងឃុំ សង្កាត់ [14]មេឃុំ ចៅសង្កាត់ក៏ជាមន្ត្រីអត្រានុកូលដ្ឋានក្នុងដែនដីឃុំ ឬសង្កាត់ដែលខ្លួនគ្រប់គ្រង។ នៅពេលដែលមានឃុំ សង្កាត់អវត្តមាន ត្រូវផ្ទេរសិទ្ធិជាលាយល័ក្ខណ៍អក្សរអោយជំទប់ ឬ ចៅសង្កាត់រង តាមឋានានុក្រម និងរាយការណ៍ជូនអភិបាលស្រុក ឬខណ្ឌតាមផ្លូវការ។ ក្នុងករណីមេឃុំ ឬចៅសង្កាត់ អវត្តមានដោយស្លាប់ ឬដោយបញ្ឈប់ពីមុខដំណែង ក្នុងចន្លោះពេលដែលមិនមានការរៀបចំមេឃុំ ឬចៅសង្កាត់ថ្មី សិទ្ធិជាមន្ត្រីអត្រានុកូលដ្ឋានត្រូវប្រគល់ជូនទៅជំទប់ ឬចៅសង្កាត់រងតាមឋានានុក្រម។

មេឃុំ ចៅសង្កាត់មានសិទ្ធិចាត់តាំងគណកម្មាធិការនានាដើម្បីផ្តល់យោបល់និងជួយកិច្ចការនានាតាមការចាំបាច់ ។ គណកម្មាធិការខាងលើនេះអាចយកសមាជិកណាម្នាក់ក្នុងក្រុមប្រឹក្សាឃុំសង្កាត់អោយធ្វើជាប្រធានក៏បាន ឬអាចយកប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតណាម្នាក់ក្នុងឃុំ សង្កាត់របស់ខ្លួនក្រៅពី

[14] មាត្រា៨ នៃអនុក្រឹត្យលេខ១០៣ ស្តីពីអត្រានុកូលដ្ឋាន

សមាជិក ក្រុមប្រឹក្សាអោយធ្វើជាប្រធានក៏បាន ។ មេឃុំ ឬចៅសង្កាត់ក៏ជាអ្នកមានតួនាទីក្នុងការជំរុញឱ្យមានការប្រជុំយ៉ាងតិច ម្តងក្នុងមួយខែនិងជាអ្នកធានាការអនុវត្តបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់។[15]

[16]មេឃុំ ចៅសង្កាត់ មានអ្នកជំនួយការដូចខាងក្រោម :

ចំពោះមេឃុំ អ្នកជំនួយការមានពីររូប :

- ជំទប់ទី១ មួយរូប
- ជំទប់ទី២ មួយរូប

ចំពោះចៅសង្កាត់ អ្នកជំនួយការមានពីររូប

- ចៅសង្កាត់រងទី១ មួយរូប
- ចៅសង្កាត់រងទី២ មួយរូប ។

### ១.៣.៣ ជំទប់/ចៅសង្កាត់រង

រដ្ឋបាលឃុំ សង្កាត់ត្រូវមានជំនួយការដែលជា

- ជំទប់ទី១/ចៅសង្កាត់រងទី១ មួយរូប
- ជំទប់ទី២/ចៅសង្កាត់រងទី២ មួយរូប ។

[17]ជំទប់ទី១/ចៅសង្កាត់រងទី១ ទទួលបន្ទុក និងជួយមេឃុំ ចៅសង្កាត់លើកិច្ចការខាងសេដ្ឋកិច្ច និងហរិញ្ញវត្ថុ ។ រីឯជំទប់ទី២/ចៅសង្កាត់រងទី២ ត្រូវទទួលបន្ទុកលើកិច្ចការរដ្ឋបាល សង្គមកិច្ច សេវាសាធារណៈ និងសណ្តាប់ធ្នាប់សាធារណៈ។ មេឃុំចៅសង្កាត់អាចប្រគល់កិច្ចការបន្ថែមទៀតដល់ជំទប់ ឬចៅសង្កាត់រងរបស់ខ្លួនតាមការចាំបាច់។ ប្រសិនបើក្នុងករណីមេឃុំ ឬចៅសង្កាត់អវត្តមានត្រូវធ្វើការផ្ទេរសិទ្ធិជាលាយល័ក្ខអក្សរទៅជំទប់ ឬចៅសង្កាត់រងតាមឋានានុក្រមដើម្បីធ្វើជាមេឃុំ ឬចៅសង្កាត់ស្តីទីក្នុងរយៈពេលដែលមេឃុំ ចៅសង្កាត់អវត្តមាន។

ជំទប់ ឬចៅសង្កាត់រងមិនអាចចុះហត្ថលេខាលើឯកសារ លិខិតស្នាមនានា ដោយមិនមានការប្រគល់សិទ្ធិ អំណាចពីមេឃុំ ចៅសង្កាត់ ឬក្រុមប្រឹក្សាឃុំ សង្កាត់ឡើយ។

---

[15] មាត្រា១០ នៃច្បាប់ស្តីពីការគ្រប់គ្រងឃុំ សង្កាត់

[16] មាត្រា២៦ នៃច្បាប់ស្តីពីការគ្រប់គ្រងឃុំ សង្កាត់

[17] មាត្រា២១ នៃច្បាប់ស្តីពីការផ្ទេរិមជ្ឈការអំណាច តួនាទី និងភារកិច្ចទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់

### ១.៣.៤ ស្មៀនឃុំ

នៅក្នុងឃុំ សង្កាត់ត្រូវតែមានស្មៀន ដែលស្មៀនឃុំ សង្កាត់ ជាមន្រ្តីស្ថិតក្នុងក្របខណ្ឌលេខាធិការរដ្ឋបាលនៃក្រសួងមហាផ្ទៃ ។

[18]ស្មៀនឃុំ សង្កាត់ត្រូវបានតែងតាំងឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃនិងមានភារកិច្ចជួយការងារឃុំ សង្កាត់ និងធានានិរន្តភាពកិច្ចការរដ្ឋបាលក្នុងឃុំ សង្កាត់។ [19]ស្មៀនឃុំ សង្កាត់ត្រូវធ្វើជាសេនាធិការដល់ក្រុម ប្រឹក្សាឃុំ សង្កាត់របស់ខ្លួនក្នុងការកត់ត្រា និង ការថែរក្សា ការពារចលនវត្ថុ និងអចលនវត្ថុដែលជាទ្រព្យសម្បត្តិសាធារណៈ និងទ្រព្យសម្បត្តិឯកជនរបស់ឃុំ សង្កាត់ ឬជាទ្រព្យសម្បត្តិដែលឃុំ សង្កាត់បានជួល (ដីធ្លី អាគារ បឹង ទំនប់ ឬព្រៃក ជាដើម) ។ ស្មៀនឃុំ សង្កាត់ត្រូវគ្រប់គ្រងត្រា តែមប្រ៍ និងសំណុំឯកសារនានា និងទ្រព្យសម្បត្តិរបស់ឃុំ សង្កាត់ដែលមានដូចជា គ្រឿងសង្ហារឹមការិយាល័យ ម៉ាស៊ីន និងសម្ភារៈការិយាល័យផ្សេងទៀតរបស់ឃុំ សង្កាត់ ។

ស្មៀនឃុំ សង្កាត់មានតួនាទីក្នុងការទទួល និងពិនិត្យលិខិត ព្រមទាំងឯកសារគ្រប់ប្រភេទ ដែលបានផ្ញើមកឃុំ សង្កាត់ ហើយត្រូវបែងចែកលិខិត ឬឯកសារទាំងនោះអោយបានត្រឹមត្រូវដល់ការិយាល័យឃុំ សង្កាត់ ព្រមទាំងពិភាក្សាជាមួយមេឃុំ ចៅសង្កាត់ ។ ស្មៀនឃុំ សង្កាត់ត្រូវទទួល និងកត់ត្រាសេចក្តីសម្រេចរបស់មេឃុំ ចៅសង្កាត់ និងចាត់ចែងប្រគល់ការងារទៅដល់អ្នកដែលត្រូវទទួលអនុវត្តការងារនោះក្នុងឃុំ សង្កាត់។

ស្មៀនឃុំ សង្កាត់ តំណាងក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការធ្វើសេចក្តីសម្រេច និងអនុវត្តសេចក្តីសម្រេចនានាទទួលខុសត្រូវក្នុងការផ្តល់ព័ត៌មាន និងផ្តល់យោបល់សមស្រប ឬតំណាងស្របច្បាប់របស់ក្រុមប្រឹក្សា។ នៅក្នុងករណីដែលសេចក្តីសម្រេច វិធានការ និងឯកសារនានារបស់ក្រុមប្រឹក្សាបានសម្រេចរួចហើយ ឬដែលបានដាក់ស្នើសុំការសម្រេចតែគ្មានលក្ខណៈត្រឹមត្រូវតាមនីតិវិធី និងច្បាប់នោះស្មៀនឃុំ សង្កាត់ ត្រូវធ្វើការកត់សម្គាល់នូវកំហុស ឆ្គងទាំងនោះ ហើយស្នើសុំឱ្យក្រុមប្រឹក្សាកែសម្រួល។ ប្រសិនបើក្រុមប្រឹក្សាឃុំ សង្កាត់ បដិសេធ ស្មៀនត្រូវធ្វើសេចក្តី រាយការណ៍ជាបន្ទាន់ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងចម្លងជូនមេឃុំ សង្កាត់មួយច្បាប់។

ស្មៀនឃុំ សង្កាត់ត្រូវប្រកាន់ជំហរអព្យាក្រឹត្យតេតលម្អៀងក្នុងការងាររបស់ខ្លួន និងត្រូវផ្តល់សមភាពចំពោះប្រជាពល រដ្ឋទាំងអស់ សមាជិកក្រុមប្រឹក្សា ក្រុមនយោបាយព្រមទាំងគណៈកម្មការនានានៃឃុំ សង្កាត់។ ស្មៀន

---

[18] មាត្រា១ នៃប្រកាសស្តីពីតួនាទី ភារកិច្ច និងសិទ្ធិរបស់ស្មៀនឃុំ សង្កាត់

[19] មាត្រា៧ នៃប្រកាសស្តីពីតួនាទី ភារកិច្ច និងសិទ្ធិរបស់ស្មៀនឃុំ សង្កាត់

ឃុំ សង្កាត់ ត្រូវ ផ្តល់យោបល់ដល់មេឃុំ សង្កាត់អំពីសមត្ថកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការជ្រើសរើសមេភូមិ និងជំនួយការមេភូមិ សម្រាប់ភូមិនីមួយៗឱ្យបានឆាប់តាមលទ្ធភាពដែលអាចធ្វើបាន ។[20]

### ១.៣.៥. គណៈកម្មាធិការ

គណៈកម្មាធិការ គឺជាអ្នកផ្តល់យោបល់និងជួយការងារក្រុមប្រឹក្សាឃុំ សង្កាត់និងមេឃុំ ចៅសង្កាត់ពីបញ្ហាជាក់លាក់ណាមួយ។ គណៈកម្មាធិការនេះត្រូវបានតែងតាំងដោយមេឃុំចៅ សង្កាត់ដែលមានសមាជិកតិចជាង ០៣រូបដែលបានជ្រើសរើសចេញពីសមាជិកណាម្នាក់ពីក្រុមប្រឹក្សា ឬអាចយកប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតនៅក្នុងឃុំសង្កាត់ក្នុងមូលដ្ឋានរបស់ខ្លួនបាន។

### ១.៣.៦. មេភូមិ

#### ក. និយមន័យ

ភូមិ ជាកន្លែងប្រមូលផ្តុំដោយផ្ទះ និងគ្រួសារប្រជាពលរដ្ឋជាច្រើន ដែលភូមិជាច្រើនបង្កើតជាឃុំ សង្កាត់មួយ ។ ក្នុងភូមិមួយត្រូវមានការគ្រប់គ្រងដោយមេភូមិម្នាក់ អមដោយអនុប្រធានម្នាក់និង សមាជិកភូមិម្នាក់ជាជំនួការ ។[21] មេភូមិមិនមែនជាជាមន្ត្រីកិច្ចសន្យា ឬមន្ត្រីរាជការក្នុងមុខងារសាធារណៈនោះទេ ប៉ុន្តែការរៀបចំឱ្យមានមេភូមិនៅក្នុងឃុំ សង្កាត់គឺដើម្បីធ្វើជាសេនាធិការរបស់រដ្ឋបាលឃុំសង្កាត់នៃការគ្រប់គ្រងប្រកបដោយនិរន្តភាព និងប្រសិទ្ធិភាពនៃសេវា ។

មេភូមិកើតឡើងតាមរយៈការជ្រើសរើសទៅតាមនីតិវិធី ដោយមេឃុំ ចៅសង្កាត់ត្រូវតែងតាំងបេក្ខជនយ៉ាងតិច៣រូបសម្រាប់តាមភូមិនីមួយៗក្នុងឃុំ សង្កាត់របស់ខ្លួន ដែលបេក្ខជនត្រូវមានសញ្ជាតិខ្មែរចេះអាន និងសរសេរអក្សរខ្មែរ មានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោតក្នុងឃុំង្កាត់របស់ខ្លួន ហើយ មានអាយុយ៉ាងតិច៥ឆ្នាំគិតត្រឹមថ្ងៃដាក់ស្នើបេក្ខជន និងមានទីលំនៅអចិន្ត្រៃយ៍ក្នុងភូមិដែលបានដាក់ស្នើបេក្ខជន យ៉ាងតិច៦ខែជាប់ៗគ្នា ។ បន្ទាប់មកគណៈកម្មការបោះឆ្នោតដែលមានសមាជិកមិនលើសពី៣រូប ដោយមានស្មៀនចូលរួមផងដែរនោះនឹងរៀបចំសន្លឹកឆ្នោតសម្រាប់ភូមិនីមួយៗឱ្យមានចំនួនស្មើនឹងក្រុមប្រឹក្សា ដើម្បីក្រុមប្រឹក្សាជ្រើសរើសបេក្ខជនម្នាក់ដែលខ្លួនគាំទ្រទៅតាមភូមិនីមួយៗ ។ បេក្ខជនដែលទទួលបានសម្លេងឆ្នោតច្រើនជាងគេលើសពីពាក់កណ្តាលនៃសមាជិកនៃក្រុមប្រឹក្សាឃុំសង្កាត់ជាបេក្ខជនជាប់ឈ្មោះ ។

---

[20] ហៀង សាង_*សៀវភៅនីតិរដ្ឋបាលទូទៅ* (បោះពុម្ពលើកទី៤ ឆ្នាំ២០១៧៖រោងពុម្ពស៊ី ហេង) ទំព័រ ១៤២

[21] សេចក្តីណែនាំ ស្តីពីបែបបទ នីតិវិធី នៃការជ្រើសរើសមេភូមិ ការចូលតំណែង ការផ្លាស់ប្តូរមេភូមិ ការតែងតាំង ជំនួយការមេភូមិ និង តួនាទី ភារកិច្ច របៀបរបបធ្វើការងាររបស់មេភូមិ

### ខ. តួនាទីនិងភារកិច្ច

**មេភូមិ** ជាតំណាងឱ្យប្រជាពលរដ្ឋទាំងអស់នៅក្នុងភូមិ និងជាខ្សែរយៈចម្បងសម្រាប់តភ្ជាប់។ មេភូមិមានភារកិច្ចអនុវត្តនូវភារកិច្ចដែលក្រុមប្រឹក្សាឃុំ សង្កាត់ រឺមេឃុំ ចៅសង្កាត់ប្រគល់អោយ ដើម្បីជានា សន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និង អភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមក្នុងភូមិផ្តល់យោបល់ដល់ក្រុមឃុំ សង្កាត់អំពីបញ្ហានានាដែលទាក់ទងដល់ផលប្រយោជន៍ក្នុងភូមិ របស់ខ្លួនស្នើសុំយោបល់ទៅក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ដើម្បីចាត់ចែង និងសម្រប សំរួលកិច្ចការនៅក្នុងភូមិរបស់ខ្លួន ។[22]

[23]**អនុប្រធានភូមិ** ទទួលការងារជំនួសមេភូមិក្នុងពេលដែលមេភូមិអវត្តមាន ដោយមានមូលហេតុច្បាស់លាស់ដូចជា មានជំងឺ ឬមានបេសកកម្មចេញក្រៅឃុំ សង្កាត់របស់ខ្លួននៅពេលមួយថ្ងៃ។ ក្រៅពីនេះអនុប្រធានភូមិត្រូវទទួលជួយមេភូមិលើការអនុវត្តគម្រោងអភិវឌ្ឍន៍នានា ក្នុងភូមិតាមគម្រោងផែនការរបស់ឃុំ សង្កាត់។

[24]**សមាជិកភូមិ** ទទួលជួយធ្វើជាលេខាធិការឱ្យមេភូមិ និងទទួលជួយពង្រឹងការងារស្ថិតិ ការចុះបញ្ជីប្រជាពលរដ្ឋ និងការរក្សាទុកឯកសារនានារបស់ឃុំ។

### គ. លក្ខខ័ណ្ឌនានានៃការបាត់បង់មុខតំណែងរបស់មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ

[25]មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ ត្រូវបាត់បង់ពីមុខតំណែងក្នុងករណីណាមួយដូចខាងក្រោមៈ

- សាមីខ្លួនទទួលមរណភាព
- សមីខ្លួនដាក់ពាក្យសុំលាឈប់ពីមុខតំណែងជាលាយលក្ខណ៍អក្សរ
- សម័យខ្លួនបាត់បង់សម្បទាវិជ្ជាជីវៈដោយមានលិខិតបញ្ជាក់ពីភ្នាក់ងារមានសមត្ថកិច្ច
- សម័យខ្លួនត្រូវបានលុបឈ្មោះចេញពីបញ្ជីឈ្មោះអ្នកបោះឆ្នោតនៃឃុំ សង្កាត់របស់ខ្លួន
- សមីខ្លួនត្រូវតុលាការផ្តន្ទាទោសពីបទឧក្រិដ្ឋ រឺបទមជ្ឈឹមណាមួយ
- សមីខ្លួនផ្លាស់ទីលំនៅទៅភូមិផ្សេង
- សមីខ្លួនមានកំហុសឆ្គងក្នុងការងារ ហើយត្រូវបញ្ឈប់ពីមុខតំណែងដោយក្រុមប្រឹក្សាឃុំសង្កាត់របស់ខ្លួន ។

[22] សេចក្តីណែនាំ ស្តីពីបែបបទ នីតិវិធី នៃការជ្រើសរើសមេភូមិ ការចូលតំណែង ការផ្លាស់ប្តូរមេភូមិ ការតែងតាំង ជំនួយការមេភូមិ និង តួនាទី ភារកិច្ច របៀបរបបធ្វើការងាររបស់មេភូមិ

[23] ក្រសួងមហាផ្ទៃ, *ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការ* ឆ្នាំ២០១៧

[24] ក្រសួងមហាផ្ទៃ, *ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការ* ឆ្នាំ២០១៧

[25] សេចក្តីណែនាំ ស្តីពីបែបបទ នីតិវិធី នៃការជ្រើសរើសមេភូមិ ការចូលតំណែង ការផ្លាស់ប្តូរមេភូមិ ការតែងតាំង ជំនួយការមេភូមិ និង តួនាទី ភារកិច្ច របៀបរបបធ្វើការងាររបស់មេភូមិ

មេភូមិ ឬអនុប្រធាន ឬសមាជិកភូមិដែលអនុវត្តផ្ទុយពីតួនាទីភារកិច្ច នឹងមានរបៀបរបបការងារ ដូចមានចែងនៅក្នុងសេចក្តីណែនាំលេខ ស.ណ.ន ចុះថ្ងៃទី ១៧ ខែមីនា ឆ្នាំ ២០០៦ របស់ក្រសួងមហាផ្ទៃស្តីពីបែបបទនីតិវិធីនៃការជ្រើសរើសមេភូមិ ការចូលកាន់តំណែង ការផ្លាស់ប្តូរ ការតែងតាំងជំនួយការមេភូមិ និងតួនាទី ភារកិច្ច របៀបរបបធ្វើការងាររបស់មេភូមិត្រូវចាត់ទុកថាមានកំហុសឆ្គងក្នុងការងារ ។

# ជំពូកទី ២

# គោលការណ៍គ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការ

# ជំពូកទី ២

# គោលការណ៍គ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការ

## ២.១ ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់

### ២.១.១. លិខិតបទដ្ឋានគតិយុត្តឃុំ-សង្កាត់

លិខិតបទដ្ឋានគតិយុត្តរបស់រដ្ឋបាលឃុំ សង្កាត់ គឺជាលិខិតដែលកំណត់នូវវិធាន បទបញ្ញត្តិ បទបញ្ជា ឬគោលការណ៍នានាសម្រាប់ការគ្រប់គ្រង ការតែងតាំង ការបង្កើតឡើងនូវយន្តការ និងការណែនាំអនុវត្តកិច្ចការនានា។

ប្រភេទលិខិតបទដ្ឋានគតិយុត្តរបស់រដ្ឋបាលឃុំ សង្កាត់រួមមាន ដីកា សេចក្តីសម្រេច និងសេចក្តីណែនាំ។

ដីកាឃុំ សង្កាត់ គឺជាលិខិតបទដ្ឋានគតិយុត្តដែលកំណត់នូវបទប្បញ្ញត្តិទាំងឡាយដែលរដ្ឋបាលឃុំ សង្កាត់បង្កើតឡើង សំដៅបម្រើផលប្រយោជន៍ប្រជាពលរដ្ឋទូទៅក្នុងឃុំ សង្កាត់ដោយស្មើភាព មិនរើសអើង និងសម្រាប់គ្រប់គ្រងកិច្ចការនានាក្នុងក្របខ័ណ្ឌតួនាទី មុខងារ និងអំណាចអនុវត្តក្នុងរង្វង់ដែនដីរបស់ខ្លួន។

ដីកាឃុំ សង្កាត់មិនត្រូវផ្ទុយនឹងច្បាប់ និងលិខិតបទដ្ឋាននានារបស់រដ្ឋឡើយ។ ដីកាឃុំ សង្កាត់ត្រូវចុះហត្ថលេខាដោយមេឃុំ ចៅសង្កាត់ តាមការសម្រេចរបស់អង្គប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ ដែលមានចំនួនលើសពីពាក់កណ្តាលនៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូល។

សេចក្តីសម្រេចឃុំ សង្កាត់ គឺជាលិខិតបទដ្ឋានគតិយុត្តដែលបង្កើតឡើង ដើម្បីអនុវត្តដីការបស់ខ្លួន ឬលិខិតបទដ្ឋាននានារបស់រដ្ឋ ឬចែងអំពីការបង្កើតការតែងតាំងការរៀបចំ ឬការគ្រប់គ្រងកិច្ចការនានាក្នុងក្របខ័ណ្ឌតួនាទី មុខងារ និងអំណាចអនុវត្តក្នុងរង្វង់ដែនដីរបស់ខ្លួន។

សេចក្តីសម្រេចឃុំ សង្កាត់ត្រូវចុះហត្ថលេខាដោយមេឃុំ ចៅសង្កាត់តាមការសម្រេចរបស់អង្គប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ដែលមានចំនួនលើសពីពាក់កណ្តាលនៃសមាជិកក្រុមប្រឹក្សាឃុំសង្កាត់ទាំងមូល។ ក្នុងករណីប្រធានសក្តិ និងបន្ទាន់បំផុតដែលមិនអាចកោះប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់បាន មេឃុំ ចៅសង្កាត់អាចចេញសេចក្តីសម្រេច ដើម្បីដោះស្រាយស្ថានភាពបន្ទាន់នោះ។[26]

### ២.១.២. លិខិតរដ្ឋបាលឃុំ-សង្កាត់

លិខិតរដ្ឋបាល ត្រូវបានកំនត់អត្ថន័យតាមរបៀបផ្សេងៗដូចខាងក្រោមៈ

[26] ក្រសួងមហាផ្ទៃ, *ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការ* ឆ្នាំ២០១៧

- ផ្អែកលើរបបគតិយុត្តៈ គឺជាលិខិតទាំងឡាយចំណុះឲ្យនីតិរដ្ឋបាល ហើយស្ថិតនៅក្រោមសមត្ថកិច្ចរដ្ឋបាល។

- តាមន័យទូទៅៈ គឺជាលិខិតស្នាមទាំងឡាយដែលបេសកៈបានរៀបរៀង និងតាក់តែងជាលាយលក្ខណ៍អក្សរថ្លែងទៅកាន់រូបវន្តបុគ្គល ឬនីតិបុគ្គលក្នុងក្របខណ្ឌជាផ្លូវការ ឬជាកិច្ចការដែលពាក់ព័ន្ធនឹងការគ្រប់គ្រង និងការប្រព្រឹត្តទៅនៃក្រសួង ស្ថាប័ន អង្គភាព តាមបែបបទមួយមានសណ្ដាប់ធ្នាប់ ពោលគឺជាមធ្យាបាយមួយក្នុងការទំនាក់ទំនងរបស់រដ្ឋបាលឃុំ សង្កាត់ជាមួយក្រសួង ស្ថាប័ន អង្គភាពនិងបុគ្គលនានា ដែលមានលក្ខណៈតឹកតាងស្ថិតស្ថេរមិនអាចក្រឡាស់បានក្នុងគោលបំណងជូនព័ត៌មាន ណែនាំ អញ្ជើញ រាយការណ៍ ផ្សព្វផ្សាយ ឆ្លើយតប ឬចាត់តាំងបុគ្គលណាមួយឲ្យទៅបំពេញបេសកកម្ម។[27]

ប្រភេទលិខិតរដ្ឋបាលរបស់រដ្ឋបាលឃុំ សង្កាត់រួមមាន លិខិតស្នើសុំ សេចក្ដីជូនដំណឹង លិខិតអញ្ជើញ លិខិតបញ្ជាបេសកកម្ម របាយការណ៍ កំនត់ហេតុ លិខិតផ្ទេរសិទ្ធិ និងដីកាអម។

**លិខិតស្នើសុំ** គឺជាលិខិតដែលឃុំ សង្កាត់រៀបចំឡើងដើម្បីបង្ហាញពីគោលបំណង និងមូលហេតុនៃតម្រូវការជាក់លាក់ណាមួយរបស់ខ្លួនថ្លែងទៅកាន់រូបវន្តបុគ្គល នីតិបុគ្គលសាធារណៈ ឯកជន ក្រសួង ស្ថាប័ន អង្គការ ឬអង្គការសង្គមស៊ីវិលដែលមានសិទ្ធិអំណាចសម្រេច ឬដោះស្រាយចំពោះការស្នើសុំនោះ។

**សេចក្ដីជូនដំណឹង** គឺជាលិខិតដែលឃុំ សង្កាត់រៀបចំឡើងដើម្បីធ្វើការទំនាក់ទំនងជាមួយបុគ្គលក្រសួង ស្ថាប័ន អង្គការសង្គមស៊ីវិលមានខ្លឹមសារជាការឆ្លើយបំភ្លឺចំពោះបញ្ហា ឬជាការឆ្លើយតបចំពោះសំណើ ឬជាការជូនដំណឹងឱ្យសាធារណជនបានដឹងនូវព័ត៌មានទាំងឡាយដែលឃុំ សង្កាត់ត្រូវការផ្សព្វផ្សាយ។

**លិខិតអញ្ជើញ** គឺជាលិខិតដែលឃុំ សង្កាត់រៀបចំឡើងដើម្បីធ្វើការអញ្ជើញបុគ្គល ឬតំណាងក្រសួង ស្ថាប័ន អង្គការសង្គមស៊ីវិលឱ្យចូលរួមក្នុងសកម្មភាពរបស់ឃុំ សង្កាត់ ចំពោះកិច្ចការដែលពាក់ព័ន្ធទៅនឹងបុគ្គល ឬអង្គភាពទាំងនោះ ដោយមានបញ្ជាក់ឈ្មោះ និងឋានៈ(អ្នកដែលត្រូវអញ្ជើញ) ទីកន្លែងប្រជុំ ឬប្រារព្ធពិធី កាលបរិច្ឆេទកម្មវិធី ឬរបៀបវារៈប្រជុំ (និងអាចមានឯកសារដែលពាក់ព័ន្ធនឹងការប្រជុំភ្ជាប់ជាមួយ)។

**លិខិតបញ្ជាបេសកកម្ម** គឺជាលិខិតដែលឃុំ សង្កាត់រៀបចំឡើង ដើម្បីចាត់តាំងមន្ត្រី បុគ្គលិកឃុំ សង្កាត់ឱ្យចូលរួមក្នុងសកម្មភាពនានានៅក្រៅឃុំ សង្កាត់។ លិខិតនេះមានភ្ជាប់ជាមួយនូវទិដ្ឋាការធ្វើដំណើរ។

- ទិដ្ឋាការធ្វើដំណើរ គឺជាលិខិតរដ្ឋបាលមួយប្រភេទ សម្រាប់ឱ្យអ្នកដែលមានភារកិច្ចទៅបំពេញបេសកកម្ម យកទៅចុះទិដ្ឋាការនូវទីកន្លែង កាលបរិច្ឆេទ មធ្យោបាយធ្វើដំណើរ និងហត្ថលេខារបស់អង្គ

[27] ង៉ីយ ធឿន_*សៀវភៅរដ្ឋបាលសាធារណៈ* (បោះពុម្ព ឆ្នាំ២០២០) ទំព័រ ៦៦

ភាពមានសមត្ថកិច្ចដែលបានអនុញ្ញាត និងអង្គភាពដែលបានទទួលដឹងឮអំពីការចេញដំណើរ និងការមកដល់ពីដំណាក់មួយទៅដំណាក់មួយទៀត។

- នៅពេលត្រឡប់មកវិញ ត្រូវធ្វើរបាយការណ៍ ឬរាយការណ៍ជូនមេឃុំ ចៅសង្កាត់ ឬក្រុមប្រឹក្សាឃុំ សង្កាត់ឱ្យបានជ្រាបអំពីលទ្ធផល ឬបញ្ហា សំខាន់ៗដែលខ្លួនបានទៅចូលរួម។

**របាយការណ៍** គឺជាសេចក្តីរាយការណ៍អំពីសកម្មភាព ដំណើរការនិងលទ្ធផលការងាររបស់ឃុំ សង្កាត់ ឬបុគ្គលិកណាម្នាក់ ឬមួយក្រុមដែលរដ្ឋបាលឃុំ សង្កាត់បានបំពេញឬឃុំ សង្កាត់បានចាត់តាំងឱ្យទៅបំពេញ ដើម្បីរាយការណ៍ជូនថ្នាក់ដឹកនាំ និងអង្គភាពពាក់ព័ន្ធ។ ទម្រង់របាយការណ៍ប្រចាំខែ និងប្រចាំឆ្នាំរបស់រដ្ឋបាលឃុំ សង្កាត់ត្រូវអនុវត្តតាមសេចក្តីណែនាំលេខ០៣៥ស.ណ.ន ចុះថ្ងៃទី១៦ ខែតុលាឆ្នាំ២០១៣ របស់ក្រសួងមហាផ្ទៃ ស្តីពីការរៀបចំរបាយការណ៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**កំណត់ហេតុ** គឺជាការកត់ត្រាស្រង់យកមតិយោបល់សេចក្តីសម្រេច និងការឯកភាពលើសកម្មភាពដែលត្រូវអនុវត្តពីគ្រប់សមាជិកអង្គប្រជុំ និងការសម្រេចរបស់អង្គប្រជុំ ឬជាការកត់ត្រារាល់ហេតុការណ៍ណាមួយដែលបានកើតឡើងជាក់ស្តែង ដើម្បីរក្សាទុកជាសក្ខីភាពនៅពេលដែលមានតម្រូវការ។

**លិខិតផ្ទេរសិទ្ធិ** គឺជាលិខិតរបស់មេឃុំ ចៅសង្កាត់ប្រកាសជាលាយល័ក្ខណ៍អក្សរប្រគល់សិទ្ធិឱ្យជំទប់ចៅសង្កាត់រងតាមឋានានុក្រមដើម្បីធ្វើជាមេឃុំ ចៅសង្កាត់ស្តីទីក្នុងអំឡុងពេលដែលមេឃុំ ចៅសង្កាត់អវត្តមាន។

**ដីកាអម** គឺជាឯកសាររដ្ឋបាលដែលឃុំសង្កាត់រៀបចំឡើង ធ្វើអមភ្ជាប់ជាមួយសំណុំលិខិត ដែលត្រូវផ្ញើចេញទៅឱ្យអង្គភាព ក្រសួង ស្ថាប័នណាមួយ ដោយមានកត់ត្រាឈ្មោះ និងចំនួនលិខិត(ឯកសារ)លើដីកាអមនោះ។ ឃុំ សង្កាត់ប្រើដីកាអម ដើម្បីជៀសវាងការបាត់បង់ឯកសារដែលរដ្ឋបាលឃុំ សង្កាត់ផ្ញើចេញ។[28]

**២.១.៣. ការគ្រប់គ្រងសម្ភារបរិក្ខារឃុំ-សង្កាត់**

គ្រប់សម្ភារបរិក្ខាររបស់ឃុំ សង្កាត់ត្រូវចុះបញ្ជីឲ្យបានត្រឹមត្រូវ។ បញ្ជីគ្រប់គ្រងបរិក្ខារនេះត្រូវរក្សាទុកឲ្យបានល្អ ប្រកបដោយសុវត្ថិភាព និងធ្វើបច្ចុប្បន្នភាពជាប្រចាំ។

គ្រប់សម្ភារបរិក្ខារឃុំ សង្កាត់ដែលកាត់ចេញពីបញ្ជីត្រូវធ្វើឡើងស្របតាមនីតិវិធី និងត្រូវសម្រេចដោយអង្គប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់។

**២.១.៤. ការគ្រប់គ្រងឯកសារឃុំ-សង្កាត់**

ការគ្រប់គ្រងឯកសារ គឺជាការរៀបចំទុកដាក់ និងថែរក្សាឯកសារទាំងឡាយតាមប្រព័ន្ធមួយមានសណ្តាប់ធ្នាប់ និងសុវត្ថិភាព។

[28] ក្រសួងមហាផ្ទៃ, *ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការ* ឆ្នាំ២០១៧

យោងតាមអនុក្រឹត្យលេខ ២២ អនក្រ.បក ស្តីពីការផ្ទេរមជ្ឈការអំណាច តួនាទី និងភារកិច្ចទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ត្រង់មាត្រា៩ ចែងថា ៖

- ឃុំ សង្កាត់ គឺជាម្ចាស់លើរាល់លិខិត និងឯកសារដែលរៀបចំឡើងដោយក្រុមប្រឹក្សាឃុំ សង្កាត់ ឬក្នុងនាមក្រុមប្រឹក្សាឃុំ សង្កាត់ និងជាម្ចាស់កម្មសិទ្ធិលើតែមប្រ៏ ត្រាឃុំ សង្កាត់ ព្រមទាំងឧបករណ៍ផ្សេងៗទៀតទាំងអស់របស់ឃុំ សង្កាត់។
- ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធានាទុកដាក់ឯកសារ លិខិតស្នាមតែមប្រ៏ ត្រាឱ្យបានត្រឹមត្រូវ និងគង់វង្ស។

**ក. ផលប្រយោជន៍នៃការគ្រប់គ្រងឯកសារ**

ការគ្រប់គ្រងឯកសារនឹងផ្តល់នូវផលប្រយោជន៍មួយចំនួនដូចជា ៖

- បង្កលក្ខណៈងាយស្រួលក្នុងការស្វែងរកព័ត៌មាន និងទិន្នន័យសម្រាប់ដឹកនាំនៅក្នុងការពិភាក្សា និងការធ្វើសេចក្តីសម្រេច
- ជួយបន្តនិរន្តរភាពព័ត៌មាន នៅពេលមានអ្នកមកកាន់ការងារថ្មី និងអ្នកផ្លាស់ចេញ
- ផ្តល់នូវភស្តុតាងជាក់លាក់ពីកិច្ចការ ឬព្រឹត្តិការណ៍ដែលកើតរួចមកហើយ
- បង្កើនប្រសិទ្ធភាព និងសន្សំពេលវេលាដល់ការងាររដ្ឋបាលឃុំ សង្កាត់។

**ខ. ប្រភេទឯកសារ**

ជាទូទៅ ឯកសារឃុំ សង្កាត់ មាន២ប្រភេទ គឺឯកសារផ្ទៃក្នុង និងឯកសារសាធារណៈ ។

ឯកសារផ្ទៃក្នុង គឺជាឯកសារទាំងឡាយណាដែលត្រូវបានប្រើប្រាស់ និងផ្សព្វផ្សាយសម្រាប់តែផ្ទៃក្នុងរបស់រដ្ឋបាលឃុំ សង្កាត់ និងបុគ្គលពាក់ព័ន្ធផ្ទាល់ប៉ុណ្ណោះ។

ឯកសារផ្ទៃក្នុងរួមមាន៖

- របាយការណ៍ស៊ើបអង្កេត
- ឯកសារទាក់ទងនឹងសន្តិសុខបុគ្គល ឬប្រជាពលរដ្ឋ
- ឯកសារទាក់ទងនឹងកិត្តិយសរបស់បុគ្គល
- ឯកសារអត្រានុកូលដ្ឋាន...។ល។

ឯកសារសាធារណៈ គឺជាឯកសារទាំងឡាយណាដែលត្រូវបានប្រើប្រាស់ និងផ្សព្វផ្សាយសម្រាប់សាធារណជនទូទៅ។

ឯកសារសាធារណៈ រួមមាន៖

- ផែនការអភិវឌ្ឍន៍
- កម្មវិធីវិនិយោគឃុំ សង្កាត់

- គម្រោងថវិការប្រចាំឆ្នាំរបស់ឃុំ សង្កាត់
- លិខិតបទដ្ឋានគតិយុត្ត
- លិខិតរដ្ឋបាលធម្មតា
- ស្ថិតិ
- ព្រឹត្តិបត្រ
- ឯកសារបច្ចេកទេស
- កម្មវិធីវិនិយោគបីឆ្នាំរំកិល
- របាយការណ៍ហិរញ្ញវត្ថុឃុំ សង្កាត់...។ល។[29]

### ២.១.៥. កិច្ចប្រជុំក្រុមប្រឹក្សាឃុំ-សង្កាត់

ប្រជុំ គឺជាការជួបជុំគ្នាដែលមានមនុស្សពី ៣នាក់ឡើងទៅដោយមានគោលបំណងរួម ហើយយកការផ្លាស់ប្តូរយោបល់គ្នា (ទោះជាតាមរយៈការនិយាយផ្ទាល់មាត់ ឬការសរសេរ) ធ្វើជាមធ្យោបាយចម្បងក្នុងការសម្រេចនូវគោលបំណងទាំងនោះ។

កិច្ចប្រជុំដែលមានប្រសិទ្ធភាព និងលទ្ធផលល្អ គឺជាការប្រជុំមួយ ដែលៈ

- សម្រេចបាននូវគោលបំណងរបស់អង្គប្រជុំ
- ប្រើប្រាស់ពេលវេលាតិចបំផុត (អប្បបរមា) និង
- មានការពេញចិត្តពីអ្នកចូលរួម។[30]

យោងតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ៖

- មាត្រា២១ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើការប្រជុំយ៉ាងតិចណាស់ចំនួនមួយដងក្នុងមួយខែ។
- មាត្រា២៣ ការប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើជាសាធារណៈ និងមានលក្ខណៈប្រជាធិបតេយ្យ។ក្រុមប្រឹក្សាឃុំ សង្កាត់អាចប្រជុំជាសម្ងាត់បាន។

ក្រុមប្រឹក្សាឃុំ សង្កាត់អាចចាត់ឲ្យមានកិច្ចប្រជុំជាសម្ងាត់ដើម្បីពិភាក្សាបញ្ហាដូចជាៈ

- ការដាក់វិន័យ ឬបញ្ឈប់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់
- បញ្ហាសន្តិសុខក្នុងឃុំ សង្កាត់

[29] ក្រសួងមហាផ្ទៃ, *ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការ* ឆ្នាំ២០១៧

[30] ក្រសួងមហាផ្ទៃ, *រាជរដ្ឋាភិបាលកម្ពុជាគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ សៀវភៅណែនាំស្តីពីកិច្ចការរដ្ឋបាលឃុំ សង្កាត់* ឆ្នាំ ២០០៥

- ការរៀបចំសំណុំរឿងដើម្បីតវ៉ា ឬការពារក្តីអ្វីមួយ និង
- ការដោះស្រាយបញ្ហាដែលពាក់ព័ន្ធនឹងកិត្តិយសបុគ្គល។

### ក. ការត្រៀមរៀបចំកិច្ចប្រជុំ

គ្រប់ការប្រជុំទាំងអស់ត្រូវតែមានគោលបំណង ពេលដែលចាប់ផ្តើមបើកការប្រជុំ ប្រធានអង្គប្រជុំត្រូវជំរាបអំពីគោលបំណងនៃការប្រជុំឲ្យបានច្បាស់លាស់ដល់អ្នកចូលរួម ដើម្បីឲ្យការពិភាក្សាផ្តោតចំគោលដៅ។ លើសពីនេះទៅទៀត ការរៀបចំរបៀបវារៈក៏ត្រូវតែធ្វើឡើងដោយខានពុំបានផងដែរ ព្រោះថារបៀបវារៈអាចជួយតម្រង់ទិសនៃការពិភាក្សាឲ្យផ្តោតទៅលើតែប្រធានបទដែលបានកំនត់ និងគួរតែត្រូវបានរៀបចំជាមុន ហើយចែកជូនអ្នកដែលត្រូវចូលរួមប្រជុំ មុននឹងការប្រជុំចាប់ផ្តើមដំណើរការ។ ការចែករបៀបវារៈមុនពេលប្រជុំអាចជួយជំរុញ និងលើកទឹកចិត្តឲ្យអ្នកចូលរួមបានត្រៀម និងរៀបចំខ្លួនជាមុន។

ម្យ៉ាងទៀតមុនពេលកិច្ចប្រជុំចាប់ផ្តើម មេឃុំ ចៅសង្កាត់ត្រូវតែធានាថា លិខិតអញ្ជើញត្រូវបានរៀបចំ និងផ្ញើជូនដល់អ្នកដែលត្រូវចូលរួមប្រជុំគ្រប់គ្នាទាំងអស់។ លិខិតអញ្ជើញ ត្រូវតែបញ្ជាក់ឲ្យបានច្បាស់អំពី ពេលវេលា ទីកន្លែង និងបញ្ហាសំខាន់ដែលត្រូវពិភាក្សា ឬជំរាបនៅពេលប្រជុំ។

### ខ. ការប្រព្រឹត្តទៅនៃកិច្ចប្រជុំ

ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ឬប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ស្តីទី ត្រូវដឹកនាំរាល់កិច្ចប្រជុំក្រុមប្រឹក្សាទាំងអស់។ ចំពោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ គឺត្រូវចូលរួមរាល់កិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ និងអាចអវត្តមានបានលុះត្រាតែមានការអនុញ្ញាតជាមុន។ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ មានសេរីភាពក្នុងការបញ្ចេញមតិក្នុងអង្គប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់។ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់រូបណាក៏ដោយ មិនអាចត្រូវបានចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួនដោយហេតុពីការសំដែងយោបល់ ឬបញ្ចេញមតិក្នុងអង្គប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់បានឡើយ។ រីឯប្រជាពលរដ្ឋមានសិទ្ធិចូលរួមស្តាប់រាល់កិច្ចប្រជុំជាសាធារណៈរបស់ក្រុមប្រឹក្សាឃុំ សង្កាត់បាន ប៉ុន្តែពុំមានសិទ្ធិអនុម័តបានទេ។

កិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់អាចប្រព្រឹត្តទៅបាន លុះត្រាណាតែមានសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់លើសពីពាក់កណ្តាលនៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូលចូលរួមនៅក្នុងកិច្ចប្រជុំនោះ។

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់គ្រប់រូបមានសិទ្ធិបោះឆ្នោតនៅក្នុងគ្រប់កិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់។ ការបោះឆ្នោតត្រូវធ្វើឡើងដោយការលើកដៃ។ សំឡេងគាំទ្រ និងមិនគាំទ្រត្រូវប្រកាសឲ្យដឹងភ្លាម ហើយកត់ត្រាទុកនៅក្នុងកំនត់ហេតុ។ ស្មៀនឃុំ បុគ្គលិក និងអ្នកផ្សេងទៀតដែលចូលរួមប្រជុំ មិនអាចបោះឆ្នោតបានទេ។ សេចក្តីសម្រេចនៃកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់អាចចាត់ទុកជាបានការ លុះត្រាតែសេចក្តីសម្រេចនេះ ត្រូវបាន

អនុម័តដោយសំឡេងលើសពីពាក់កណ្តាលនៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូល ដើម្បីសម្រេចបញ្ហាមួយចំនួនដូចជា៖

- អនុម័តលើគម្រោងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់
- អនុម័តលើគម្រោងថវិការឃុំ សង្កាត់
- កំនត់តម្លៃសារពើពន្ធមូលដ្ឋាន និងកំរៃសេវាផ្សេងៗ
- អនុម័តបទបញ្ជាផ្ទៃក្នុង និងដីការឃុំ សង្កាត់
- កិច្ចការផ្សេងៗទៀតដែលកំនត់ដោយក្រសួងមហាផ្ទៃ។

ចំពោះសេចក្តីសម្រេចលើកិច្ចការផ្សេងពីនេះ អាចចាត់ទុកជាបានការ លុះត្រាតែមានសំឡេងគាំទ្រភាគច្រើននៃចំនួនសមាជិកក្រុមប្រឹក្សាដែលមានវត្តមានក្នុងអង្គប្រជុំ។

### គ. កិច្ចការនានាក្រោយពេលប្រជុំ

ចំពោះកិច្ចការចំនួន ៣ ធំៗដែលតម្រូវឲ្យធ្វើក្រោយពេលប្រជុំរួចមានដូចជា ការរៀបចំកំនត់ហេតុប្រជុំ ការរៀបចំសេចក្តីជូនដំណឹងអំពីលទ្ធផលនៃការប្រជុំ ដើម្បីផ្សព្វផ្សាយដល់សាធារណជន និងការអនុវត្តសេចក្តីសម្រេចរបស់អង្គប្រជុំ។ ការរៀបចំកំនត់ហេតុប្រជុំ ត្រូវធ្វើឡើងដោយស្មៀនឃុំ សង្កាត់ដែលមានការពិគ្រោះយោបល់ជាមួយប្រធានក្រុមប្រឹក្សាឃុំ សង្កាត់។ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់គ្រប់រូបនឹងទទួលបានកំនត់ហេតុដែលមានចុះហត្ថលេខារបស់ប្រធានអង្គប្រជុំចំនួន ០១ច្បាប់ម្នាក់នៅក្នុងប្រជុំបន្ទាប់។

បន្ទាប់ពីប្រជុំចប់ភ្លាម ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវចាត់ឲ្យធ្វើការជូនដំណឹងដល់សាធារណជនអំពីសេចក្តីសម្រេចនានារបស់ខ្លួនដោយបិទផ្សាយលើក្តារខៀនព័ត៌មានឃុំ សង្កាត់។

មួយវិញទៀត សេចក្តីសម្រេចរបស់អង្គប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានអនុវត្តនៅក្នុងរង្វង់ដែនដីឃុំ សង្កាត់របស់ខ្លួនបន្ទាប់ពីបញ្ចប់កិច្ចប្រជុំភ្លាម។

### ២.១.៦. ការរៀបចំបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់

មុនពេលចាប់ផ្តើមការងារក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗត្រូវរៀបចំ និងអនុម័តបទបញ្ជាផ្ទៃក្នុង ដើម្បីកំនត់វិធានទាំងឡាយសម្រាប់អង្គប្រជុំ និងរបៀបរបបធ្វើការងាររបស់ខ្លួន។ បទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើឡើងជា ទម្រង់ដីកា និងពិភាក្សា អនុម័តក្នុងកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់យ៉ាងយូរបំផុតក្នុងរយៈពេល ៣០ថ្ងៃ បន្ទាប់ពីកិច្ចប្រជុំដំបូង មុននឹងឈានទៅអនុវត្តកិច្ចការផ្សេងទៀត។

## ២.២ ការគ្រប់គ្រងហិរញ្ញវត្ថុឃុំ-សង្កាត់

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់នៅក្នុងសម័យអាណានិគមបារាំងក្នុងឆ្នាំ១៩០៨ មិនបានធ្វើការអនុវត្តបានទេ។ ការអនុវត្តដែលពិតប្រាកដ គឺធ្វើឡើងនៅក្នុងឆ្នាំ១៩១៩ និងត្រូវបានកែប្រែ(ធ្វើវិសោធនកម្ម) ក្នុងឆ្នាំ១៩២៤ ដោយអនុញ្ញាតឲ្យឃុំ សង្កាត់ មានថវិកាឃុំ សង្កាត់។

ស្វ័យភាពថវិកាឃុំ សង្កាត់ត្រូវបានទទួលស្គាល់ដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។ ផ្តើមចេញពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ជាលើកដំបូង ឆ្នាំ២០០២នៅក្នុងប្រទេស ក៏ដូចជាការធ្វើវិមជ្ឈការអំណាចនៅថ្នាក់មូលដ្ឋានឃុំ សង្កាត់ មានធនធានហិរញ្ញវត្ថុ ថវិកា និងទ្រព្យសម្បត្តិផ្ទាល់ សម្រាប់ដំណើរការការងារនៅមូលដ្ឋានខ្លួនស្របតាមប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ និងនីតិវិធីដែលទាក់ទងទៅនឹងការងារដូចជាៈ

- ថវិកាឃុំ សង្កាត់
- ប្រព័ន្ធគណនេយ្យ និងប្រព័ន្ធទូទាត់សម្រាប់ឃុំ សង្កាត់
- ការគ្រប់គ្រងចំណាយរបស់ឃុំ សង្កាត់
- ទ្រព្យសម្បត្តិឃុំ សង្កាត់
- សវនកម្ម និងរបាយការណ៍ហិរញ្ញវត្ថុឃុំ សង្កាត់។[31]

### ២.២.១. ប្រភពចំណូលឃុំ-សង្កាត់

ប្រភពចំណូលឃុំ សង្កាត់សំខាន់ៗមាន៣ គឺ

- ចំណូលផ្ទាល់
- ចំណូលពីមូលនិធិឃុំ សង្កាត់និង
- ចំណូលពីការអនុវត្តមុខងារជាភ្នាក់ងារ។

ឃុំ សង្កាត់ មានសិទ្ធិទទួលជំនួយផ្ទាល់ដែលបានមកពីចំណូលសារពើពន្ធ ចំណូលមិនមែនសារពើពន្ធ និងកំរៃសេវាផ្សេងៗ។

ចំណូលពីមូលនិធិឃុំ សង្កាត់ គឺជាចំណូលដែលបានមកពីការផ្ទេរធនធានពីមូលនិធិឃុំ សង្កាត់ឲ្យទៅឃុំ សង្កាត់នីមួយៗ ដែលក្នុងនោះមានចំណាយសម្រាប់ផ្នែករដ្ឋបាល និងចំណាយផ្នែកអភិវឌ្ឍន៍ឃុំ សង្កាត់។

ចំណូលពីការអនុវត្តមុខងារជាភ្នាក់ងារ គឺជាចំណូលដែលបានមកពីការបំពេញភារកិច្ចដោយឃុំ សង្កាត់ ជំនួសមុខឲ្យក្រសួង ស្ថាប័ន ឬអង្គភាពនានារបស់រដ្ឋ ទៅតាមការព្រមព្រៀងគ្នា។

ក្រៅពីចំណូលសំខាន់ៗទាំង ៣ នេះឃុំ សង្កាត់ មានជំនួយផ្សេងៗទៀតដូចជាៈ

[31] ឡាញ់ ដា, *សៀវភៅសិក្សាសង្ខេបអំពីនីតិថវិកានិងពន្ធដារ និងនីតិមុខងារសាធារណៈ*, (បោះពុម្ពផ្សាយឆ្នាំ២០១៦),ទំព័រទី១៩

- ចំណូលពីការចូលរួមចំណែករបស់ប្រជាពលរដ្ឋមូលដ្ឋាន
- ចំណូលពីអង្គការមិនមែនរដ្ឋាភិបាល និងកម្មវិធីនានា។

ឃុំ សង្កាត់ត្រូវទទួលខុសត្រូវចំពោះការគ្រប់គ្រងធនធានហិរញ្ញវត្ថុថវិកា និងទ្រព្យសម្បត្តិទាំងនេះយ៉ាងហ្មត់ចត់ ដើម្បីធានាថាការប្រើប្រាស់ធនធានរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ធ្វើឡើងឲ្យបានត្រឹមត្រូវ មានតម្លាភាព សន្សំសំចៃ និងមានប្រសិទ្ធភាពខ្ពស់។

**២.២.២. ថវិកាឃុំ-សង្កាត់**

ថវិការបស់ឃុំ សង្កាត់ គឺជាលិខិតគតិយុត្តដែលក្រុមប្រឹក្សាឃុំ សង្កាត់មានសិទ្ធិពេញលេញក្នុងការគ្រោងចំណូលចំណាយ និងអនុវត្តចំណូល ចំណាយតាមថវិកាគ្រោង។

គោលការណ៍ថវិកាសំខាន់ៗនៃការរៀបចំគម្រោងថវិកាឃុំ សង្កាត់មានដូចជាៈ

- គម្រោងថវិកាឃុំ សង្កាត់ត្រូវរៀបចំ និងអនុម័តប្រចាំឆ្នាំ (ថវិកាចាប់ផ្តើមពីថ្ងៃទី ០១ ខែមករានឹងបញ្ចប់នៅថ្ងៃទី ៣១ ខែធ្នូ)
- ថវិកាត្រូវតែមានតុល្យភាពៈ ផែនការចំណាយសរុបត្រូវតែប៉ាប់រងពេញលេញដោយផែនការចំណូលសរុប
- ថវិកាឃុំ សង្កាត់ត្រូវតែឆ្លុះបញ្ចាំងចំណាយជាអាទិភាពរបស់ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់។

ការរៀបចំ ការអនុម័ត និងការបញ្ជាក់ទទួលស្គាល់គម្រោងថវិកាមានដូចតទៅៈ

- មេឃុំចៅសង្កាត់ត្រូវធានាថាដំណើរការនៃការរៀបចំថវិកាមានការចូលរួមពីប្រជាពលរដ្ឋមូលដ្ឋាន។
- គណៈកម្មាធិការកសាងផែនការ និងថវិកាជួយមេឃុំ ចៅសង្កាត់ ក្នុងការរៀបចំគម្រោងថវិកាឃុំ សង្កាត់។
- ក្រុមប្រឹក្សាឃុំ ពិនិត្យនិងអនុម័តគម្រោងថវិកាឃុំ រួចបញ្ជូនទៅអភិបាលខេត្តដើម្បីត្រួតពិនិត្យអនុលោមភាព និងបញ្ជាក់ទទួលស្គាល់លើគម្រោងថវិកានេះ។
- ក្រុមប្រឹក្សាសង្កាត់ ចំណុះក្រុង ពិនិត្យ និងអនុម័តគម្រោងថវិកាសង្កាត់ រួចបញ្ជូនទៅអភិបាលក្រុងដើម្បីបញ្ចូលជាមួយគម្រោងថវិកាក្រុង។
- ក្រុមប្រឹក្សាសង្កាត់ចំណុះរាជធានីពិនិត្យ និងអនុម័តគម្រោងថវិកាសង្កាត់ រួចបញ្ជូនទៅអភិបាលរាជធានី ដើម្បីបញ្ចូលជាមួយគម្រោងថវិការាជធានី។
- អភិបាលខេត្តត្រូវត្រួតពិនិត្យអនុលោមភាព និងបញ្ជាក់ទទួលស្គាល់លើក្រុមគម្រោងថវិការបស់ឃុំ។
- អភិបាលខេត្តត្រូវត្រួតពិនិត្យអនុលោមភាព និងបញ្ជាក់ទទួលស្គាល់លើគម្រោងថវិការបស់ក្រុងដែលមានបញ្ចូលថវិកាសង្កាត់។

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវត្រួតពិនិត្យអនុលោមភាព និងបញ្ជាក់ទទួលស្គាល់លើគម្រោងថវិការបស់រាជធានីដែលមានបញ្ចូលថវិកាឃុំ សង្កាត់ចំណុះរាជធានី។

### ២.២.៣. ការគ្រប់គ្រង និងការអនុវត្តថវិកាឃុំ-សង្កាត់

- ការកែតម្រូវថវិកា៖ ថវិកាឃុំ សង្កាត់អាចនឹងកែតម្រូវក្នុងឆ្នាំថវិកា ដោយសារមានការផ្លាស់ប្តូរសភាពការណ៍សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលជះឥទ្ធិពលដល់ការព្យាករណ៍ដំបូងនៃចំណូល និងចំណាយ។
- ការកំណត់តម្លៃ និងប្រមូលចំណូល៖ ចំណូលផ្ទាល់របស់ឃុំ សង្កាត់ត្រូវកំណត់ និងប្រមូលតាមបទបញ្ញត្តិច្បាប់ដោយឡែក។
- ខួបនៃការចំណាយ៖ រួមមាន ការពន្យាចំណាយ ការជម្រះបញ្ជី ការចេញអាណត្តិបើកប្រាក់ និងការទូទាត់ដូចដែលបានបញ្ជាក់ក្នុងប្រកាសណែនាំស្តីពីនីតិវិធីចំណាយ និងលទ្ធកម្មរបស់ឃុំ សង្កាត់។

របាយការណ៍អំពីលទ្ធផលនៃការអនុវត្តថវិកា ឃុំ សង្កាត់ត្រូវធ្វើរបាយការណ៍ស្តីពីការអនុវត្តថវិកាតាមប្រតិទិន និងនីតិវិធីដែលបានបញ្ជាក់ក្នុងប្រកាសណែនាំស្តីពីប្រព័ន្ធទូទាត់ និងគណនេយ្យរបស់ឃុំ សង្កាត់។

ការបិទបញ្ជីថវិកាមានដំណើរការដូចតទៅ៖

- នៅដំណាច់ឆ្នាំថវិកាឃុំ សង្កាត់ត្រូវបិទបញ្ជីថវិកា
- គណនេយ្យករឃុំ សង្កាត់ត្រូវរៀបចំរបាយការណ៍បិទបញ្ជីគណនេយ្យជូនមេឃុំ ចៅសង្កាត់
- ក្រុមប្រឹក្សាឃុំ សង្កាត់ពិនិត្យ និងអនុម័តរបាយការណ៍បិទបញ្ជីគណនេយ្យ
- អភិបាលរាជធានី ខេត្តពិនិត្យ និងបញ្ជាក់ទទួលស្គាល់លើសេចក្តីសម្រេចស្តីពីការបិទបញ្ជីថវិកា។

### ២.២.៤. ប្រព័ន្ធទូទាត់និងគណនេយ្យឃុំ-សង្កាត់

#### ក. គោលការណ៍ទូទៅ

ឃុំ សង្កាត់ត្រូវបើកគណនីប្រាក់បញ្ញើនៅរតនាគាររាជធានីខេត្ត។ មេឃុំ ចៅសង្កាត់ជាអាណាប័ក និងមានសិទ្ធិពេញលេញលើការប្រមូល ឬការទទួលចំណូល ការអនុវត្តចំណាយ និងការចេញអាណត្តិ បើកប្រាក់ដោយផ្អែកទៅលើថវិកាដែលបានអនុម័ត។ មេឃុំ ចៅសង្កាត់ អាចផ្ទេរសិទ្ធិក្នុងការសំរេចទៅលើថវិកាជាតិឲ្យជំទប់ចៅសង្កាត់របស់រដ្ឋបាលឃុំ សង្កាត់។ ការផ្ទេរសិទ្ធិ ជាអាណាប័កនេះ ត្រូវធ្វើសកម្មភាពដោយស្ថិតនៅក្នុងការទទួលខុសត្រូវ និងត្រួតពិនិត្យរបស់មេឃុំ ចៅសង្កាត់។ មេឃុំ ចៅសង្កាត់ និងអ្នកទទួលសិទ្ធិ ត្រូវតែតម្កល់គំរូហត្ថលេខាជាផ្លូវការនៅរតនាគាររាជធានី ខេត្ត។ មេឃុំ ចៅសង្កាត់ អ្នកទទួលសិទ្ធិ និងបុគ្គលិករដ្ឋបាលឃុំ សង្កាត់ ជាទូទៅមិនត្រូវបានអនុញ្ញាតឱ្យកាន់កាប់មូលនិធិ ឬធ្វើការទូទាត់ចំណាយលើកលែងតែក្នុងករណីទូទាត់ជូនទេយ្យបុរេប្រទាន និងចំណូលដែលប្រមូលដោយភ្នាក់ងារប្រមូលចំណូល។ សិទ្ធិបញ្ជាចំណាយ និងការ

ទូទាត់មិនត្រូវប្រគល់អោយមនុស្សតែម្នាក់បានឡើយ។ រតនាគាររាជធានី ខេត្តបំពេញមុខងារ ជាគណនេយ្យករឃុំ សង្កាត់។

**ខ. ប្រព័ន្ធទូទាត់**

- ការទូទាត់ផ្ទាល់ ជាការទូទាត់តាមរយៈរតនាគាររាជធានី ខេត្ត។
- ការទូទាត់តាមរយៈរដ្ឋទេយ្យបុរេប្រទាន ៖ ចំនួនទឹកប្រាក់សម្រាប់មួយគោលការណ៍ចំណាយ ឬមួយប័ណ្ណចំណាយនៃរដ្ឋទេយ្យបុរេប្រទានយ៉ាងច្រើនបំផុតត្រឹម៥០០.០០០រៀល (ប្រាំរយពាន់រៀល)។

**គ. ប្រព័ន្ធគណនេយ្យ**

- គណនេយ្យហិរញ្ញវត្ថុ ៖ គណនេយ្យករនៅរតនាគាររាជធានីខេត្តមានភារកិច្ចអនុវត្តគណនេយ្យហិរញ្ញវត្ថុ។ គណនេយ្យហិរញ្ញវត្ថុ គឺជាកិច្ចបញ្ជីការរាល់ចំណូល ចំណាយទៅក្នុងប្រព័ន្ធគណនេយ្យ។
- គណនេយ្យថវិកា ៖ មេឃុំ ចៅសង្កាត់មានភារកិច្ចទទួលខុសត្រូវក្នុងការអនុវត្តគណនេយ្យថវិកា។គណនេយ្យថវិការ គឺជាការតាមដាន និងរាយការណ៍អំពីការអនុវត្តចំណូល ចំណាយ ថវិកាដែលមានអនុម័ត។

### ២.២.៥. របាយការណ៍ហិរញ្ញវត្ថុឃុំ-សង្កាត់

របាយការណ៍ហិរញ្ញវត្ថុឃុំ សង្កាត់មានបីប្រភេទគឺ៖

- របាយការណ៍ស្តីពីចំណូល ចំណាយថវិកាប្រចាំខែ
- របាយការណ៍ស្តីពីចំណូល ចំណាយថវិកាប្រចាំឆមាស
- របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ។

### ២.២.៦. កិច្ចលទ្ធកម្មឃុំ-សង្កាត់

កិច្ចលទ្ធកម្ម គឺជាដំណើរការលទ្ធកម្មចាប់ពីពេលរៀបចំឯកសារដេញថ្លៃរហូតដល់ពេលទទួលបានទំនិញ សំណង់ ឬសេវាកម្ម។ លទ្ធកម្ម សំដៅដល់ការទិញ ឬការរកបាននូវទំនិញ សំណង់ ឬសេវាកម្មតាមរយៈវិធីសាស្ត្រដែលបានកំណត់។

គោលការណ៍សំខាន់ៗនៃកិច្ចលទ្ធកម្ម

- លទ្ធកម្មសំណង់ លទ្ធកម្មសេវាកម្ម និងលទ្ធកម្មទំនិញ ត្រូវអនុវត្តក្នុងលក្ខណៈមួយដែលមានតម្លាភាព ប្រសិទ្ធិភាព និងសន្សំសំចៃបំផុតតាមដែលអាចធ្វើទៅបានដោយធានាគុណភាព
- អ្នកទទួលការ អ្នកផ្តល់សេវាកម្ម និងអ្នកផ្គត់ផ្គង់ត្រូវបានផ្តល់ឱកាសស្មើៗគ្នា ដើម្បីចូលរួមនៅក្នុងដំណើរការដេញថ្លៃក្រោមលក្ខខណ្ឌយុត្តិធម៌ និងស្មើភាព
- លទ្ធផលនៃការដេញថ្លៃត្រូវផ្សព្វផ្សាយជាសាធារណៈ។

សមាសភាពគណៈកម្មការលទ្ធកម្ម

- មេឃុំ ចៅសង្កាត់ជាប្រធាន
- សមាជិកក្រុមប្រឹក្សា ឃុំ សង្កាត់ ០២រូប ជាសមាជិកឃុំ សង្កាត់ ស្មៀនឃុំ សង្កាត់បំពេញតួនាទីជាលេខាធិការឲ្យគណៈកម្មការលទ្ធកម្មឃុំ សង្កាត់។

វិធីសាស្ត្រលទ្ធកម្ម

- ការដេញថ្លៃដោយប្រកួតប្រជែងជាចំហ (ជាសាធារណៈ)
- ការស្ទង់តម្លៃក្នុងស្រុក
- ការទិញផ្ទាល់ ឬការចុះកិច្ចសន្យាផ្ទាល់ (ការចរចាតម្លៃផ្ទាល់)។

**២.២.៧. ការទូទាត់**

- មេឃុំ ចៅសង្កាត់នឹងត្រូវធ្វើការទូទាត់ឲ្យអ្នកទទួលការ ឬអ្នកផ្តល់សេវាកម្ម ឬអ្នកផ្គត់ផ្គង់ជាមុនឡើយ។
- ការទូទាត់ត្រូវធ្វើឡើងតែនៅពេលដែលទំនិញត្រូវបានប្រគល់ទទួលត្រឹមត្រូវ និងការងារសំណង់ និងការងារសេវាកម្មត្រូវបានបំពេញត្រឹមត្រូវតាមល័ក្ខខ័ណ្ឌដែលមានចែងនៅក្នុងកិច្ចសន្យា។[32]

## ២.៣. ផែនការអភិវឌ្ឍឃុំ-សង្កាត់

ផែនការអភិវឌ្ឍន៍ឃុំ គឺមានអាណត្តិ ៥ឆ្នាំ ដូចអាណត្តិក្រុមប្រឹក្សាដែរ។ ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ដែលត្រូវប្រើប្រាស់សម្រាប់កំណត់អំពីបញ្ហា តម្រូវការ និងយុទ្ធសាស្ត្រនានា គឺដើម្បីដោះស្រាយរាល់បញ្ហាទាំងនោះ សំដៅឆ្លើយតបទៅនឹងបញ្ហាជាអាទិភាពរបស់ប្រជាពលរដ្ឋឲ្យមានប្រសិទ្ធិភាព។

### ២.៣.១. ការរៀបចំ និងដំណើរការនៃផែនការអភិវឌ្ឍន៍ឃុំ-សង្កាត់

ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវរៀបចំអនុម័ត និងអនុវត្តនូវផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ក្នុងគោលបំណងកំណត់នូវទស្សនវិស័យ កម្មវិធី និងកិច្ចអភិវឌ្ឍន៍ឃុំ សង្កាត់របស់ខ្លួន។ ក្រុមប្រឹក្សាឃុំ សង្កាត់ គឺជាក្រុមប្រឹក្សារដ្ឋបាលមួយផ្នែកដែលនៅជិតប្រជាពលរដ្ឋបំផុត ដើម្បីទទួលបានព័ត៌មាន ក៏ដូចជាអាចមានភាពងាយស្រួលក្នុងការស្វែងយល់ឲ្យបានច្បាស់អំពីតម្រូវការលើគ្រប់វិស័យរបស់ប្រជាពលរដ្ឋ ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ក្នុងការរៀបចំផែនការអភិវឌ្ឍន៍ឃុំ សង្កាត់និមួយៗរបស់ខ្លួន គឺត្រូវពឹងផ្អែកទៅលើការយល់ដឹងរបស់មេឃុំ ចៅសង្កាត់អំពី ប្រជាពលរដ្ឋក្នុងតំបន់នោះ ដើម្បីឲ្យការអភិវឌ្ឍនោះមានភាពឆ្លើយតបទៅនឹងតម្រូវការដែលចាំបាច់បំផុតរបស់ប្រជារាស្ត្រ។ ផែនការអភិវឌ្ឍន៍និមួយៗ គឺធ្វើឡើងដោយកំណត់ទៅលើថាតើការងារណាដែលជាតម្រូវការចាំបាច់មុន ដើម្បីឲ្យប្រជាពលរដ្ឋមានភាពងាយស្រួល និងពេញចិត្តក្នុងការទទួលយកនូវការផ្តល់របស់រដ្ឋាភិបាល។ ទោះបីជាឃុំ សង្កាត់ត្រូវបានកំនត់ឲ្យរៀបចំនៅផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ដោយខ្លួនឯង និង

---

[32] ក្រសួងមហាផ្ទៃ, *ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការ* ឆ្នាំ២០១៧

តាមលទ្ធភាពនៃឃុំ សង្កាត់រៀងៗខ្លួនក៏ដោយ តែផែនការអភិវឌ្ឍន៍នេះ គឺត្រូវតែស្របទៅនឹងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមកិច្ចរបស់ជាតិ។

ផែនការអភិវឌ្ឍន៍ គឺជាភារកិច្ចមួយយ៉ាងសំខាន់ចំពោះឃុំ សង្កាត់និមួយៗដោយសារតែមុនពេលមានការអភិវឌ្ឍអ្វីមួយកើតឡើងគឺ មេឃុំ ចៅសង្កាត់ត្រូវធ្វើការស្វែងយល់ពីប្រជាជនរបស់ខ្លួនថាគ្រប់គ្រាន់ចំណុចណា និងខ្វះខាតចំណុចណាដែលតម្រូវឲ្យមានការបំពេញបន្ថែម។ ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ត្រូវរៀបចំជាលាយលក្ខណ៍អក្សរដោយមានផែនទី ស្ថិតិ និងសំណុំឯកសារពាក់ព័ន្ធផ្សេងៗទៀតភ្ជាប់ជាមួយផង។ ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ក៏ត្រូវកំនត់ផងដែរនូវវិធីសាស្ត្រ និងមធ្យោបាយនានា ដើម្បីបង្កលទ្ធភាពឲ្យមានការចូលរួមពីប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់ខ្លួនក្នុងកិច្ចដំណើរការទាំងមូល។ ប្រជាជនក៏មានតួនាទីយ៉ាងសំខាន់ក្នុងការចូលរួមសហការជាមួយក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួនផងដែរ ដើម្បីឲ្យវាស្របគ្នាទៅវិញទៅមក និងអាចធ្វើឲ្យមានភាពរីកចម្រើន ក៏ដូចជាល្អប្រសើរនូវជីវភាពរបស់ប្រជាពលរដ្ឋក្នុងតំបន់នោះ។ ការអភិវឌ្ឍមួយអាចនឹងទទួលជោគជ័យបាន នោះវាអាស្រ័យទៅលើការចូលរួមពីថ្នាក់ដឹកនាំ មេឃុំ ចៅសង្កាត់ និងពីប្រជាពលរដ្ឋក្នុងតំបន់នោះយ៉ាងចាំបាច់។ លុះត្រាមានភាពស្របគ្នាពីអ្នកទាំងអស់នេះទើបធ្វើឲ្យស្ថានភាពក្នុងឃុំ សង្កាត់នោះអាចរីកចម្រើនបានយ៉ាងឆាប់រហ័ស។

ក្នុងករណីដែលផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ណាមួយធ្វើឡើងមិនស្របតាមល័ក្ខខ័ណ្ឌដែលបានចែងក្នុងច្បាប់នេះរដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវណែនាំឲ្យក្រុមប្រឹក្សាឃុំសង្កាត់កែតំរូវផែនការរបស់ខ្លួនឱ្យសមស្របក្នុងអំឡុងពេលយ៉ាងយូរ ៤៥ ថ្ងៃបន្ទាប់ពីថ្ងៃបានទទួលច្បាប់ចំលងនៃផែនការនោះ។ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើការកែសម្រួលផែនការអភិវឌ្ឍន៍ឃុំ សង្កាត់របស់ខ្លួនឲ្យបានសមស្របតាមការណែនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

### ២.៣.២. វដ្តនៃផែនការអភិវឌ្ឍន៍ឃុំ-សង្កាត់

វដ្តនៃការអភិវឌ្ឍឃុំ សង្កាត់មាន៥ ជំហានគឺ

ជំហានទី ១ ៖ សេចក្តីព្រាងក្របខណ្ឌអភិវឌ្ឍ និងថវិកា

ជំហានទី ២ ៖ កិច្ចប្រជុំពិគ្រោះយោបល់ស្តីពីការអភិវឌ្ឍឃុំ សង្កាត់

ជំហានទី ៣ ៖ សេចក្តីព្រាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់

ជំហានទី ៤ ៖ ការអនុម័តផែនការអភិវឌ្ឍន៍ឃុំ សង្កាត់

ជំហានទី ៥ ៖ ការវាយតម្លៃអំពីការអនុវត្តផែនការអភិវឌ្ឍន៍ឃុំ សង្កាត់

#### ជំហានទី១៖ សេចក្តីព្រាងក្របខណ្ឌអភិវឌ្ឍ និងថវិកា

គោលបំណងនៃជំហាននេះ គឺរៀបចំសេចក្តីព្រាងក្របខ័ណ្ឌអភិវឌ្ឍ និងថវិកាឃុំ សង្កាត់ ដើម្បីដាក់ជូនកិច្ចប្រជុំពិភាក្សាពិគ្រោះយោបល់ស្តីពីការអភិវឌ្ឍឃុំ សង្កាត់ផ្តល់យោបល់ និងអនុសាសន៍។ សេចក្តីព្រាងនេះ

រួមមាន សេចក្តីត្រូវការ គោលដៅ យុទ្ធសាស្ត្រ សកម្មភាពជាអាទិភាព ព្រមទាំងការប៉ាន់ស្មានលទ្ធភាពធនធានសម្រាប់រយៈពេល ៥ ឆ្នាំខាងមុខផងដែរ។ គណៈកម្មាធិការកសាងផែនការ និងថវិកាជួបប្រជុំនៅឃុំ សង្កាត់ ដើម្បីធ្វើការវិភាគទិន្នន័យភូមិ ទិន្នន័យឃុំ សង្កាត់ ឯកសារព័ត៌មានស្ថានភាពឃុំ សង្កាត់ និងទិន្នន័យ ឬព័ត៌មាន ឬប្រើឧបករណ៍វិភាគផ្សេងៗ ក្នុងការកំណត់អំពី បញ្ហាទីតាំងនៃបញ្ហា មូលហេតុនៃបញ្ហា តម្រូវការ ឧបសគ្គនាំឱ្យរាំងស្ទះដល់ការសម្រេចបាននូវតម្រូវការ និងដំណោះស្រាយនានា។ បន្ទាប់មក គឺមានការជួបប្រជុំ នៅតាមភូមិនីមួយៗដែលពេលនោះតំណាងគណៈកម្មាធិការកសាងផែនការ និងថវិកា ត្រូវបង្ហាញអំពីបញ្ហា ទីតាំងនៃបញ្ហា មូលហេតុនៃបញ្ហា តម្រូវការ ឧបសគ្គ និងដំណោះស្រាយដល់ប្រជាពលរដ្ឋដែលបានចូលរួម ដើម្បីយកមកធ្វើការពិភាក្សា និង ធ្វើសុពលភាព។ បន្ទាប់ពីប្រជុំនៅតាមភូមិរួចមក គណៈកម្មាធិការកសាងផែនការ និងថវិកាជួបប្រជុំនៅឃុំ សង្កាត់ម្តងទៀតដើម្បីបកស្រាយបញ្ហាទីតាំងនៃបញ្ហា មូលហេតុនៃបញ្ហា តម្រូវការ ឧបសគ្គ និងដំណោះស្រាយនានាដែលបានមកពីបណ្តាភូមិ និងពិភាក្សាកំណត់អំពីសេចក្តីត្រូវការអភិវឌ្ឍ គោលដៅអភិវឌ្ឍន៍ យុទ្ធសាស្ត្រអភិវឌ្ឍន៍ និងសកម្មភាពជាអាទិភាព។

**ជំហានទី ២ ៖ កិច្ចប្រជុំពិគ្រោះយោបល់ស្តីពីការអភិវឌ្ឍឃុំ សង្កាត់**

ជំហាននេះធ្វើឡើងក្នុងគោលបំណងបង្ហាញ អំពីសេចក្តីព្រាងក្របខណ្ឌអភិវឌ្ឍ និងថវិការបស់ឃុំ សង្កាត់ ដល់ប្រជាពលរដ្ឋក្នុងឃុំ សង្កាត់ និងអ្នកពាក់ព័ន្ធនានា។ ម្យ៉ាងទៀត គឺដើម្បីស្តាប់មតិយោបល់របស់ប្រជាពលរដ្ឋក្នុងឃុំ សង្កាត់ និងពាក់ព័ន្ធនានា ហើយធ្វើការស្រង់មតិយោបល់របស់ពួកគេ ដើម្បីរៀបចំសេចក្តីព្រាង។ ប្រជាពលរដ្ឋទាំងអស់អាចចូលរួមកិច្ចប្រជុំពិគ្រោះយោបល់នេះ។ មេឃុំ ចៅសង្កាត់ត្រូវប្រកាសជូនដំណឹង និងផ្សព្វផ្សាយពីកាលបរិច្ឆេទនៃកិច្ចប្រជុំពិគ្រោះយោបល់ស្តីពីការអភិវឌ្ឍឃុំ សង្កាត់ឲ្យបាន ៥ ថ្ងៃមុនកិច្ចប្រជុំ។ ឃុំ សង្កាត់ ត្រូវរៀបចំការប្រជុំផ្ទៃក្នុងជាមុន ដើម្បីរៀបចំឯកសារសម្រាប់បង្ហាញនៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់ស្តីពីការអភិវឌ្ឍឃុំ សង្កាត់។ គណៈអធិបតីបើកកិច្ចប្រជុំពិគ្រោះយោបល់ដោយបញ្ជាក់ពីគោលបំណងរបស់កិច្ចប្រជុំ និងជម្រាបអំពីវិន័យផ្ទៃក្នុងសម្រាប់កិច្ចប្រជុំពិគ្រោះយោបល់។

**ជំហានទី ៣ ៖ សេចក្តីព្រាងផែនការអភិវឌ្ឍឃុំ សង្កាត់**

គោលបំណងនៃជំហាននេះ គឺចងក្រងសេចក្តីព្រាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ដោយផ្អែកលើការបូកសរុបយោបល់ដែលបានមកពីកិច្ចប្រជុំពិភាក្សាពិគ្រោះយោបល់ ស្តីពីការអភិវឌ្ឍឃុំ សង្កាត់ និងសេចក្តីព្រាងក្របខណ្ឌអភិវឌ្ឍ និងថវិកាឃុំ សង្កាត់ ដើម្បីដាក់ជូនក្រុមប្រឹក្សាឃុំ សង្កាត់ពិនិត្យ ឯកភាព និងដាក់ជូនអភិបាលខេត្ត ក្រុងពិនិត្យ និងផ្តល់យោបល់។ ជំហាននេះរៀបចំឡើងក្នុងអំឡុង ៥ ថ្ងៃបន្ទាប់ពីបញ្ចប់កិច្ចប្រជុំពិគ្រោះយោបល់ត្រូវរៀបចំផែនការអភិវឌ្ឍន៍ឃុំ សង្កាត់តាមទម្រង់នៃផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ដែលបានកំណត់ដោយផ្អែកតាមលទ្ធផលនៃជំហានទី ១ និងជំហានទី ២។ បន្ទាប់ពីបញ្ចប់សេចក្តីព្រាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់គ

ណៈកម្មាធិការកសាងផែនការ និងថវិកា ដាក់ជូនសេចក្តីព្រាងនេះទៅក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីពិនិត្យ និងឯកភាព។ បន្ទាប់មកមេឃុំ ចៅសង្កាត់ ផ្ញើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ រួមទាំងអភិបាលខេត្ត ក្រុង តាមរយៈអង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត ក្រុងដើម្បីពិនិត្យ និងផ្តល់យោបល់។

**ជំហានទី ៤ ការអនុម័តផែនការអភិវឌ្ឍន៍ឃុំ សង្កាត់**

គោលបំណងនៃជំហាននេះ គឺការពិនិត្យកែសម្រួល អនុម័ត និងផ្សព្វផ្សាយផែនការអភិវឌ្ឍន៍ឃុំ សង្កាត់។ អភិបាលខេត្ត ក្រុងពិនិត្យ និងផ្តល់យោបល់ទៅលើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ដោយមានជំនួយពីអង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត ក្រុង។ គណៈកម្មាធិការកសាងផែនការ និងថវិកាឃុំ សង្កាត់ និងស្មៀនឃុំ ពិនិត្យពិចារណា និងកែសម្រួល សេចក្តីព្រាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់តាមមតិយោបល់របស់អភិបាលខេត្ត ក្រុងដោយមានជំនួយពីអ្នកសម្របសម្រួលស្រុកខណ្ឌ។

**ជំហានទី ៥ ការវាយតម្លៃអំពីការអនុវត្តន៍ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់**

លទ្ធផលដែលសម្រេចបាននៅក្នុងជំហាននេះគឺ របាយការណ៍វាយតម្លៃដែលឆ្លុះបញ្ចាំងអំពីលទ្ធផលនៃការអនុវត្តផែនការអភិវឌ្ឍន៍ឃុំ សង្កាត់, ចំណុចខ្លាំងនិងចំណុចខ្សោយនៃការអភិវឌ្ឍផែនការអភិវឌ្ឍន៍ឃុំ សង្កាត់, អនុសាសន៍សម្រាប់កែលម្អការរៀបចំ និងគ្រប់គ្រងការអនុវត្តផែនការអភិវឌ្ឍន៍ឃុំ សង្កាត់, មេរៀនបទពិសោធន៍សម្រាប់ការរៀបចំ និងគ្រប់គ្រងការអនុវត្តផែនការឃុំ សង្កាត់, ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់។ គណៈកម្មាធិការកសាងផែនការ និងថវិកា ពិនិត្យ និងវាយតម្លៃទៅលើប្រសិទ្ធភាពនៃការអនុវត្តផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងដកស្រង់បទពិសោធន៍នានាសម្រាប់ជាមូលដ្ឋានក្នុងការគ្រប់គ្រង ការអនុវត្ត និងការរៀបចំផែនការនាពេលក្រោយ។ ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវពិនិត្យ និងអនុម័តរបាយការណ៍វាយតម្លៃ ហើយផ្សាយរបាយការណ៍នេះជាសាធារណៈដល់អ្នកដែលពាក់ព័ន្ធនានា។

**២.៣.៣. កម្មវិធីវិនិយោគរបស់ឃុំ**

**ក. ក្របខ័ណ្ឌវិនិយោគ**

ក្របខ័ណ្ឌវិនិយោគ គឺជាផ្នែកមួយដ៏សំខាន់របស់កម្មវិធីវិនិយោគឃុំ សង្កាត់។ ក្នុងការសរសេរក្របខ័ណ្ឌនេះក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវរៀបចំអំពី គោលបំណងសំខាន់ៗសម្រាប់អភិវឌ្ឍមូលដ្ឋាននាពេលខាងមុខដោយផ្អែកលើបញ្ហាប្រឈមនានាដែលបានកើតឡើងក្នុងផ្នែកនៃការវិភាគស្ថានភាពបច្ចុប្បន្នរបស់ឃុំ សង្កាត់។ លើសពីនេះទៀត ការសរសេរក្របខណ្ឌត្រូវគិតផងដែរអំពីថវិកាវិនិយោគសរុប ដែល ឃុំ សង្កាត់ពីប្រភពផ្សេងៗ និងដោយសមត្ថភាពរបស់ឃុំ សង្កាត់ ដើម្បីធានាឲ្យក្របខណ្ឌនេះអាចអនុវត្តបានប្រកបដោយជោគជ័យ។

**ខ. វដ្តនៃកម្មវិធីវិនិយោគឃុំ-សង្កាត់**

វដ្តនៃកម្មវិធីវិនិយោគឃុំ សង្កាត់មាន ៥ ជំហានគឺ៖

**ជំហានទី ១ ការពិនិត្យបញ្ហា ឬតម្រូវការជាមួយប្រជាពលរដ្ឋឡើងវិញ**

គោលបំណងនៃជំហាននេះ គឺជាការពិភាក្សា អំពីបញ្ហា ទីតាំងនៃបញ្ហា មូលហេតុនៃបញ្ហា តម្រូវការ ឧបសគ្គ និងដំណោះស្រាយនានាឡើងវិញ ដើម្បីរៀបចំគម្រោងវិនិយោគប្រចាំឆ្នាំរបស់ឃុំ សង្កាត់។ គណៈកម្មាធិការកសាងផែនការ និងថវិកា ជួបប្រជុំនៅថ្នាក់ឃុំ ដើម្បីពិភាក្សាពិនិត្យបញ្ហា ឬតម្រូវការមូលហេតុនៃបញ្ហា និងដំណោះស្រាយឡើងវិញ ដោយធ្វើការឆ្លុះបញ្ចាំងជាមួយទិន្នន័យភូមិ ទិន្នន័យឃុំ ឯកសារព័ត៌មានស្ថានភាពឃុំ និងទិន្នន័យ ឬព័ត៌មានផ្សេងៗ ហើយកំណត់អំពីមូលហេតុនៃបញ្ហា និងដំណោះស្រាយនានាសម្រាប់ពិភាក្សាជាមួយប្រជាពលរដ្ឋ។ បន្ទាប់មកគណៈកម្មាធិការធ្វើការរៀបចំប្រជុំនៅតាមភូមិ ដើម្បីពិភាក្សា និងធ្វើសុពលភាពទៅលើបញ្ហា មូលហេតុ និងដំណោះស្រាយទាំងឡាយដែលបានកំណត់នៅថ្នាក់ឃុំ ដើម្បីពិភាក្សាកំណត់បញ្ហា ឬតម្រូវការ និងដំណោះស្រាយនានាបន្ថែម។ ចុងក្រោយនោះ គឺគណៈកម្មាធិការធ្វើការជួបប្រជុំម្តងទៀតនៅថ្នាក់ឃុំ ដើម្បីបូកសរុបបញ្ហាមូលហេតុ និងដំណោះស្រាយដែលបានមកពីបណ្តាភូមិនានា។

**ជំហានទី ២ ការរៀបចំគម្រោងថវិកាឃុំ សង្កាត់**

គណៈកម្មាធិការកសាងផែនការ និងថវិកា ធ្វើការឆ្លុះបញ្ចាំងនូវលទ្ធផលនៃជំហានទី១ ជាមួយនឹងគម្រោងតាមបណ្តាឆ្នាំនីមួយៗនៃផែនការអភិវឌ្ឍន៍ឃុំ ដើម្បីកំណត់គម្រោងកម្មវិធីវិនិយោគប្រចាំឆ្នាំដែលត្រូវយកទៅបង្ហាញ និងកៀរគរធនធាននៅសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុក ខណ្ឌ។

**ជំហានទី ៣ សិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ ស្រុក**

សិក្ខាសាលាសមាហរណកម្មផែនការនេះត្រូវរៀបចំឡើង ដើម្បីផ្តល់ឱកាសឲ្យមានការផ្សារភ្ជាប់រវាងកម្មវិធីវិនិយោគឃុំជាមួយនឹងផែនការរបស់មន្ទីរជំនាញ អង្គការក្រៅរដ្ឋាភិបាល សង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍នានា ហើយធ្វើការកៀរគរ និងសម្របសម្រួលធនធានពីប្រភពផ្សេងៗ សម្រាប់គាំទ្រ ដល់គម្រោងវិនិយោគឃុំ សង្កាត់ ជាពិសេសជួយតម្រង់ទិសសកម្មភាពរបស់មូលដ្ឋានឃុំ ឲ្យស្របតាមគោលនយោបាយអភិវឌ្ឍន៍ជាតិ និងខេត្ត។

**ជំហានទី ៤ ការអនុវត្តកម្មវិធីវិនិយោគឃុំ**

គណៈកម្មាធិការកសាងផែនការ និងថវិកា បានរៀបចំនូវតារាងថវិកាវិនិយោគតាមប្រភពតារាងគម្រោងវិនិយោគដែលមានការសន្យាគាំទ្រ និងតារាងគម្រោងវិនិយោគដែលមិនទាន់មានការសន្យាគាំទ្រជាពិសេសជ្រើសរើសនូវគម្រោងដែលមិនទាន់មានការសន្យាគាំទ្រ សម្រាប់ប្រើប្រាស់មូលនិធិឃុំ។ ក្រោយពីប្រមូលមតិយោបល់រួច កណៈកម្មាធិការត្រូវរៀបចំសេចក្តីព្រាងកម្មវិធីវិនិយោគឃុំ ហើយដាក់ជូនក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីពិនិត្យ និងអនុម័ត។ ឯកសារកម្មវិធីវិនិយោគដែលអនុម័តរួច ត្រូវប្រកាសផ្សព្វផ្សាយ និងដាក់ឲ្យប្រើប្រាស់ជាផ្លូវការ និងបង្កភាពងាយស្រួលដល់អ្នកពាក់ព័ន្ធ ដើម្បីធ្វើការស្វ័យសិក្សាស្វែងយល់។

**ជំហានទី ៥ ការតាមដានត្រួនពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគឃុំ**

ជំហានចុងក្រោយ គណៈកម្មាធិការត្រូវតាមដានត្រួតពិនិត្យការរីកចម្រើន និងប្រសិទ្ធភាពនៃការអនុវត្តគម្រោង ឬសកម្មភាពនានា ដែលមាននៅក្នុងកម្មវិធីវិនិយោគឃុំ និងដើម្បីធានាការអនុវត្តគម្រោង ឬសកម្មភាពទាំងនោះឲ្យបានត្រឹមត្រូវ និងទាន់ពេលវេលា។ មិនត្រឹមតែប៉ុណ្ណោះគណៈកម្មាធិការត្រូវពិនិត្យ និងវាយតម្លៃលើប្រសិទ្ធភាព នៃការអនុវត្តន៍កម្មវិធីវិនិយោគឃុំ ហើយដកស្រង់បទពិសោធន៍នានាសម្រាប់ជាមូលដ្ឋាននៅក្នុងការគ្រប់គ្រង ការអនុវត្ត និងការរៀបចំកម្មវិធីវិនិយោគឆ្នាំក្រោយ។[33]

**២.៣.៤. តួនាទី និងភារកិច្ចរបស់អ្នកពាក់ព័ន្ធ**

ចំពោះតួនាទី និងភារកិច្ចអ្នកដែលទទួលខុសត្រូវក្នុងការរៀបចំ កសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ សង្កាត់គឺៈ

**ក. ក្រុមប្រឹក្សាឃុំ សង្កាត់**

ក្រុមប្រឹក្សាឃុំ សង្កាត់ មានភារកិច្ចក្នុងការពិនិត្យ និងអនុម័តផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគឃុំ សង្កាត់ និងរាល់ការធ្វើវិសោធនកម្មផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ សង្កាត់។ ម្យ៉ាងទៀតក្រុមប្រឹក្សាឃុំ សង្កាត់ក៏មានភារកិច្ចក្នុងការតាមដាន និងវាយតម្លៃអំពីលទ្ធផលនៃការសម្រេចបាននូវផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ សង្កាត់ផងដែរ។

**ខ. មេឃុំចៅ សង្កាត់**

មេឃុំ ចៅសង្កាត់ មានតួនាទីក្នុងការប្រមូលទិន្នន័យភូមិ ឃុំ សង្កាត់ កសាងផែនការអភិវឌ្ឍន៍ ដាក់សេចក្តីព្រាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ សង្កាត់ជូនទៅក្រុមប្រឹក្សាឃុំ សង្កាត់ដើម្បីពិនិត្យ និងអនុម័ត។

**គ. គណៈកម្មាធិការកសាងផែនការ និងថវិកាឃុំ សង្កាត់**(**គ.ផ.ថ**)

គណៈកម្មាធិការកសាងផែនការ និងថវិកាឃុំ សង្កាត់ មានតួនាទីក្នុងការជួយមេឃុំ ចៅសង្កាត់ក្នុងការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ និងមួយទៀត គឺកម្មវិធីវិនិយោគឃុំ សង្កាត់ដោយអនុវត្តតាមបែបបទនីតិវិធីដូចដែលមានកំណត់នៅក្នុងសេចក្តីណែនាំបច្ចេកទេសស្តីពីការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងសេចក្តីណែនាំស្តីពីការរៀបចំ និងកសាងកម្មវិធីវិនិយោគឃុំ សង្កាត់។

**ឃ. អភិបាលរាជធានី ខេត្ត**

អភិបាលរាជធានី ខេត្ត មានតួនាទីក្នុងការបង្កើតយន្តការគាំទ្រការកសាង និងអនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ សង្កាត់។ មួយវិញទៀត គឺការកៀរគរ និងដឹកនាំចាត់ចែងសកម្មភាពរបស់មន្ទីរជំនាញខេត្ត ក្រុង និងអង្គភាពពាក់ព័ន្ធក្នុងការផ្តល់ការគាំទ្រ និងណែនាំនូវការងារបច្ចេកទេសដល់ក្រុមប្រឹក្សាឃុំ សង្កា

[33] ក្រុមការងារអន្តរក្រសួង, *រាជរដ្ឋាភិបាលកម្ពុជាគណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការសេចក្តីណែនាំស្តីពីការកសាងផែនការអភិវឌ្ឍន៍ឃុំសង្កាត់និងកម្មវិធីវិនិយោគឃុំសង្កាត់*, ឆ្នាំ២០០៧

ត់។ ជាចុងក្រោយនោះ គឺមានភារកិច្ចនៅក្នុងការត្រួតពិនិត្យ និងផ្តល់យោបល់ទៅលើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់។

**ខ. អង្គភាពរដ្ឋបាលមូលដ្ឋានរាជធានី ខេត្ត**

អង្គភាពមូលដ្ឋានខេត្ត ក្រុង ទទួលខុសត្រូវជាខ្សែរយៈទាក់ទងទៅរវាងក្រុមប្រឹក្សាឃុំ សង្កាត់ជាមួយរដ្ឋបាលខេត្ត ក្រុង ធ្វើការផ្តល់ការបណ្តុះបណ្តាលឲ្យក្រុមប្រឹក្សាឃុំ សង្កាត់គណៈកម្មាធិការគណៈកម្មការកសាងផែនការ និងថវិកាឃុំ សង្កាត់ និងអ្នកពាក់ព័ន្ធអំពីផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំសង្កាត់ ហើយនឹងជួយក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការរៀបចំ និងអនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ សង្កាត់។ ម្យ៉ាងទៀតអង្គភាពមូលដ្ឋានខេត្ត ក្រុង ក៏មានតួនាទីធ្វើការតាមដានវាយតម្លៃអំពីផលប៉ះពាល់នៃការអនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ សង្កាត់។

**គ. មន្ទីរ និងអង្គភាពជំនាញរាជធានី ខេត្តនានា**

មន្ទីរ និងអង្គភាពជំនាញខេត្ត ក្រុងនានា ទទួលខុសត្រូវក្នុងការផ្តល់ជំនួយបច្ចេកទេសពាក់ព័ន្ធនឹងជំនាញរបស់ខ្លួនក្នុងការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ សង្កាត់ ក្នុងការរៀបចំ និងអនុវត្តគម្រោងនានារបស់ក្រុមប្រឹក្សាឃុំ សង្កាត់។

**ឃ. អង្គការសង្គមស៊ីវិល**

អង្គការសង្គមស៊ីវិលអាចចូលរួមក្នុងការរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ សង្កាត់ដោយទទួលខុសត្រូវចូលរួមជាតំណាងឱ្យផលប្រយោជន៍របស់សហគមន៍មូលដ្ឋាន និងអ្នកពាក់ព័ន្ធណាមួយជាក់លាក់ដូចជាស្ត្រី កុមារ យុវជន ជនក្រីក្រ ជនជាតិដើមភាគតិច។ ចូលរួមចំណែកផ្តល់ចំណេះដឹងនិងគំនិតផ្សេងៗក្នុងការរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ សង្កាត់។[34]

**២.៣.៥. ការចូលរួមរបស់ប្រជាពលរដ្ឋ**

ក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ ប្រជាពលរដ្ឋក្នុងឃុំ សង្កាត់ត្រូវចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់ ដើម្បីកំណត់បញ្ហា និងតម្រូវការអាទិភាពនានាក្នុងសហគមន៍ និងមូលដ្ឋានខ្លួនទៅតាមស្ថានភាពជាក់ស្តែងរបស់សាមីខ្លួននីមួយៗ។

ម្យ៉ាងទៀតប្រជាពលរដ្ឋមានសិទ្ធិចូលរួមស្តាប់រាល់កិច្ចប្រជុំជាសាធារណៈរបស់ក្រុមប្រឹក្សាឃុំ សង្កាត់បាន ប៉ុន្តែមិនមានសិទ្ធិនៅក្នុងការអនុម័តបានទេ។ ប្រជាពលរដ្ឋអាចលើកសំនួរដល់មេឃុំ ចៅសង្កាត់ ឬសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់នៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ដោយអនុលោមទៅតាមបទបញ្ជាផ្ទៃក្នុង សម្រាប់កិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់។ ប្រជាពលរដ្ឋមានសិទ្ធិលើកសំណើ ឬការធ្វើការប្តឹងតវ៉ាជាលាយ

[34] ក្រសួងមហាផ្ទៃ, *ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការ* ឆ្នាំ២០១៧

លិខិតអក្សរ ឬផ្ទាល់មាត់ដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ហើយក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវឆ្លើយតបនឹងសំណើ ឬការប្តឹងតវ៉ានោះជាកំហិត។ ម្យ៉ាងចំពោះសំណើ ឬក៏ការប្តឹងតវ៉ាទាំងឡាយណាដែលមេឃុំ ចៅសង្កាត់អាចដោះស្រាយបានក្នុងសមត្ថកិច្ចរបស់ខ្លួន មេឃុំចៅសង្កាត់ត្រូវដោះស្រាយ និង ធ្វើសេចក្តីរាយការណ៍ជូនក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងកិច្ចប្រជុំបន្ទាប់។ ប៉ុន្តែចំពោះសំណើឬការប្តឹងតវ៉ាទាំងឡាយណាដែលមេឃុំ ចៅសង្កាត់មិនអាចដោះស្រាយបានក្នុងសមត្ថកិច្ចរបស់ខ្លួនមេឃុំ ចៅសង្កាត់ត្រូវដាក់នៅក្នុងរបៀបវារៈអង្គប្រជុំបន្តរបស់ក្រុមប្រឹក្សាឃុំ សង្កាត់។ មេឃុំ ចៅសង្កាត់ត្រូវជូនព័ត៌មានដល់ប្រជាពលរដ្ឋអំពីការដោះស្រាយទាំងឡាយរបស់ក្រុមប្រឹក្សាឃុំ សង្កាត់។[35]

### ២.៣.៦. ការត្រួតពិនិត្យ និងវាយតម្លៃ

ការត្រួតពិនិត្យ និងវាយតម្លៃត្រូវ គឺត្រូវធ្វើជាចាំបាច់ បន្ទាប់ពីមានការរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ សង្កាត់រួចមក។ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃរាល់ការអនុវត្តផែនការ កម្មវិធី គម្រោង និងការប្រើសេវានានាត្រូវប្រកបដោយតម្លាភាព និងមានការទទួលខុសត្រូវខ្ពស់។ ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវតាមដានការរីកចម្រើននៃការអនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ សង្កាត់ និងបណ្តាសកម្មភាពផ្សេងៗទៀត ដែលបានអនុវត្តនៅក្នុងដែនដីឃុំ សង្កាត់របស់ខ្លួន ដោយតាមរយៈ អង្គភាពរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល អង្គការអន្តរជាតិនានា និងផ្នែកឯកជន។

ការតាមដានអនុវត្តរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ មិនត្រូវបង្កការរាំងស្ទះដល់សិទ្ធិរបស់អង្គភាពពាក់ព័ន្ធដែលត្រូវធ្វើការតាមដាន និងវាយតម្លៃសកម្មភាពនានាទាក់ទងទៅនឹងគម្រោងដែលគេកំពុងគាំទ្រនៅក្នុងឃុំ សង្កាត់នោះឡើយ។ ការវាយតម្លៃគ្រប់ជ្រុងជ្រោយទៅលើលទ្ធផល និងផលប៉ះពាល់ពីការអនុវត្តផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ត្រូវធ្វើឡើងក្នុងរយៈពេល ៦ ខែចុងក្រោយនៃអាណត្តិរបស់ក្រុមប្រឹក្សាឃុំ សង្កាត់។ ក្រសួងមហាផ្ទៃត្រូវចេញសេចក្តីណែនាំស្តីពីបែបបទវាយតម្លៃដោយ ពិគ្រោះពិភាក្សាជាមួយក្រសួងផែនការ។[36]

## ២.៤. ការគ្រប់គ្រងបុគ្គលិក

ឃុំ សង្កាត់អាចជ្រើសរើសបុគ្គលិកក្រៅក្របខណ្ឌរដ្ឋ ដើម្បីជួយកិច្ចការរបស់ខ្លួនតាមសេចក្តីត្រូវការ និងការចាំបាច់នៃការងារ និងតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងអាណត្តិ ហើយអាចបន្តការងារតាមការសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិបន្ទាប់។ ក្នុងការគ្រប់គ្រងបុគ្គលិករដ្ឋបាលឃុំ សង្កាត់ត្រូវពិនិត្យ

[35] មាត្រា៣០,៣១ នៃអនុក្រឹត្យស្តីពីការផ្ទេរមជ្ឈការអំណាច តួនាទី និងភារកិច្ចទៅឲ្យក្រុមប្រឹក្សាឃុំសង្កាត់

[36] ប្រការ១៩, ២០, នៃប្រកាសអន្តរក្រសួងស្តីពីការកសាងផែនការអភិវឌ្ឍន៍ឃុំសង្កាត់និងកម្មវិធីវិនិយោគឃុំសង្កាត់

និងអនុម័តនូវការងារមួយចំនួនដូចជា ការរៀបចំបញ្ជីគ្រប់គ្រងបុគ្គលិកឃុំ សង្កាត់ និងការបរិយាយពីមុខងារលម្អិត គោលការណ៍ផ្តល់ការងារ និងការវាយតម្លៃការអនុវត្តការងាររបស់បុគ្គលិក។

### ២.៤.១. ការរៀបចំបញ្ជីគ្រប់គ្រងបុគ្គលិកឃុំ សង្កាត់ និងការបរិយាយពីមុខងារលម្អិត

ឃុំ សង្កាត់ចាំបាច់ត្រូវមានបញ្ជីរាយនាមបុគ្គលិកតាមផ្នែក គណៈកម្មាធិការ គណៈកម្មការ ជនបង្គោលដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួន ហើយត្រូវធ្វើការកែសំរួលឲ្យទាន់សភាពការណ៍ជាប្រចាំ គឺធ្វើបច្ចុប្បន្នភាព។ ម្យ៉ាងទៀតឃុំ សង្កាត់ត្រូវមានជាចាំបាច់នូវបញ្ជីវត្តមានសម្រាប់កត់ត្រាបុគ្គលិកដែលមកបម្រើការងារប្រចាំថ្ងៃ ហើយគួររៀបចំបញ្ជីរាយនាមមួយដោយឡែកសម្រាប់សមាជិកក្រុមប្រឹក្សា និងស្មៀនឃុំ សង្កាត់។ ដើម្បីធ្វើការបំពេញភារកិច្ចឲ្យបានល្អប្រសើរ។ បុគ្គលិកឃុំ សង្កាត់ទាំងអស់ត្រូវមានការបរិយាយពីមុខងារលម្អិតរបស់បុគ្គលម្នាក់ៗ ហើយនេះជាតួនាទីរបស់មេឃុំ ចៅសង្កាត់ដែលត្រូវរៀបចំសេចក្តីបរិយាយពីមុខងារលម្អិត ហើយដាក់ជូនក្រុមប្រឹក្សាឃុំ សង្កាត់ពិនិត្យ និងអនុម័តមុននឹងប្រកាសជ្រើសរើសបេក្ខជនចូលមកបំពេញការងារ។

### ២.៤.២. គោលការណ៍ផ្តល់ការងារ

ក្រុមប្រឹក្សាឃុំ សង្កាត់នឹងសំរេចអំពីតម្រូវការមុខតំណែងណាមួយ និងចំនួនបុគ្គលិកនៃមុខតំណែងនោះសម្រាប់ជួយការងារដល់ឃុំ សង្កាត់ដោយផ្អែកលើទំហំការងាររបស់ឃុំ សង្កាត់ និងធនធានដែលខ្លួនមាន។ ចំពោះនីតិវិធីជ្រើសរើសបុគ្គលិកមានពីររបៀប គឺការជ្រើសរើសតាមរយៈប្រវត្តិរូបសង្ខេប និងការប្រឡងជ្រើសរើស។ ការជ្រើសរើសត្រូវតែធ្វើឡើងដោយយុត្តិធម៌ និងតម្លាភាព ហើយបេក្ខជនជាស្ត្រីត្រូវបានផ្តល់អាទិភាព។ រាល់បុគ្គលិកទាំងអស់ដែលបំពេញការងារនៅក្នុងឃុំ សង្កាត់ ហើយត្រូវបានផ្តល់កម្រៃដោយឃុំ សង្កាត់ គួរមានកិច្ចសន្យាផ្តល់ការងារក្នុងមួយឆ្នាំម្តង ឬរយៈពេលមួយតិចជាងនេះទៅតាមទំហំការងារ។ បុគ្គលិកជ្រើសរើសចូលបម្រើការងារថ្មី គួរត្រូវបានផ្តល់កិច្ចសន្យាធ្វើការសាកល្បងការងាររយៈពេលមួយកំណត់ តែមិនត្រូវលើសពីបីខែឡើយ។ នៅចុងបញ្ចប់នៃរយៈពេលសាកល្បង ត្រូវធ្វើការវាយតម្លៃលើការងាររបស់បុគ្គលិកនោះ ថាតើត្រូវបន្ត ឬបញ្ចប់កិច្ចសន្យាអាស្រ័យទៅលើការអនុវត្តការងារក្នុងកំឡុងពេលសាកល្បងនោះ។

### ២.៤.៣. ការវាយតម្លៃការអនុវត្តការងាររបស់បុគ្គលិក

ការវាយតម្លៃការអនុវត្តការងារ មានតួនាទីយ៉ាងសំខាន់ក្នុងកិច្ចការគ្រប់គ្រងបុគ្គលិក និងធនធានមនុស្ស។ ការវាយតម្លៃនេះ នឹងពិនិត្យឡើងវិញនូវការបំពេញការងាររបស់បុគ្គលិក ដោយផ្ទៀងផ្ទាត់ជាមួយនឹងសេចក្តីបរិយាយមុខងារលម្អិត និងផែនការការងាររបស់បុគ្គលិកនោះ។ ការវាយតម្លៃការអនុវត្តការងាររបស់បុគ្គលិក គឺធ្វើឡើងក្នុងគោលបំណងពិនិត្យមើលឡើងវិញនូវការងាររបស់បុគ្គលិក ដែលបានធ្វើក្នុងអំឡុងពេលបំពេញការងារកន្លងមក។ ម្យ៉ាងទៀតវាអាចឆ្លុះបញ្ចាំងពីការងារពិតប្រាកដដែលបុគ្គលិកនោះបានអនុវត្តជាមួយនឹងសេចក្តីបរិយាយមុខងារលម្អិត ហើយអាចធ្វើការកំណត់បញ្ហានានាដែលកើតឡើងជុំវិញប្រព័ន្ធគ្រប់គ្រងបុគ្គលិកក្នុង

ឃុំ សង្កាត់ និងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងធនធានមនុស្សនៅក្នុងឃុំ សង្កាត់ផងដែរ។ ជាទូទៅការវាយតម្លៃការងារសម្រាប់បុគ្គលិកនីមួយៗត្រូវធ្វើឡើងនៅចុងបញ្ចប់នៃរយៈពេលសាកល្បង និងនៅចុងបញ្ចប់នៃកិច្ចសន្យា គឺមួយឆ្នាំ ឬមុនពេលបន្តកិច្ចសន្យាថ្មី។ ក្នុងការវាយតម្លៃការអនុវត្តការងាររបស់បុគ្គលិកមេឃុំ ចៅសង្កាត់ត្រូវរៀបចំគណៈកម្មការវាយតម្លៃមួយដែលមានសមាសភាពយ៉ាងតិច ៣ រូបហើយដាក់ជូនអង្គប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីពិនិត្យ និងអនុម័ត។ គណៈកម្មការវាយតម្លៃនេះត្រូវដឹកនាំដោយមេឃុំ ចៅសង្កាត់។ ចំណែកលក្ខណៈសម្បត្តិមួយចំនួនដែលគណៈកម្មការគួរធ្វើការវាយតម្លៃនោះមានដូចជា ជំនាញបច្ចេកទេស គំនិតផ្តួចផ្តើម ការប្រាស្រ័យទាក់ទងក្នុងការងារ និងការចាត់ចែង និងព្យាយាមយកចិត្តទុកដាក់របស់បុគ្គលិក។ [37]

## ២.៥. ទំនាក់ទំនងរដ្ឋបាលរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់

មិនថាស្ថាប័នណាក៏ដោយស្ថាប័នតូចឬស្ថាប័នធំគឺតែងតែមានដៃគូ ភាគី ដើម្បីធ្វើទំនាក់ទំនងជាមួយ មិនថាទំនាក់ទំនងផ្នែករដ្ឋបាល ឬផ្នែកដទៃទៀត។ ដូចដែលយើងបានដឹងហើយថារដ្ឋបាលឃុំ សង្កាត់ គឺត្រូវមានទំនាក់ទំនងជាមួយនឹងរាជរដ្ឋាភិបាលក្រសួងស្ថាប័នអាជ្ញាធរ និងភ្នាក់ងារនានារបស់រដ្ឋផ្សេងៗទៀត។

ក្រសួងមហាផ្ទៃអាចធ្វើប្រតិភូកម្មអំណាចដល់អភិបាលខេត្ត ក្រុងឲ្យជួយក្នុងកិច្ចការទំនាក់ទំនងនេះ និងសម្របសម្រួលក្នុងការអនុវត្តតួនាទីមុខងារអំណាចរបស់ឃុំ សង្កាត់ដូចដែលមានចែងនៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់គោលនយោបាយវិមជ្ឈការ និងអនុក្រឹត្យពាក់ព័ន្ធនានាស្របទៅតាមសភាពការណ៍ជាក់ស្តែងចំពោះការធ្វើប្រតិភូកម្មអំណាចនេះត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដែលបានអនុម័តយល់ព្រមដោយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់។ ក្រសួងមហាផ្ទៃត្រូវសម្របសម្រួលឲ្យបានឲ្យមានកិច្ចសហប្រតិបត្តិការរវាងឃុំសង្កាត់ពីរ រឺច្រើន និងធានាដោះស្រាយរាល់ទំនាស់និងជម្លោះ ដែលក្រុមប្រឹក្សាឃុំ សង្កាត់ទាំងនោះមិនអាចដោះស្រាយបាន។ ក្រសួងមហាផ្ទៃត្រូវធានាថាការសម្រុះសម្រួលការដោះស្រាយទំនាស់ និងជម្លោះរវាងឃុំសង្កាត់ និងក្រសួងស្ថាប័នរបស់រាជរដ្ឋាភិបាល ឬអង្គការជាតិ និងអន្តរជាតិមានភាពយុត្តិធម៌ត្រឹមត្រូវ និងរក្សាបាននូវផលប្រយោជន៍ទាំងសងខាង និងអនុវត្តបានត្រឹមត្រូវតាមល័ក្ខខ័ណ្ឌ ដែលមានចែងនៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងគោលនយោបាយវិមជ្ឈការ។

ក្រសួងស្ថាប័នរបស់រាជរដ្ឋាភិបាលអាចត្រួតពិនិត្យនូវសេចក្តីសម្រេច ឬសកម្មភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ឬធ្វើអន្តរាគមន៍លើសេចក្តីសម្រេច ឬសកម្មភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់នៅពេលដែលការត្រួតពិនិ

[37] ក្រសួងមហាផ្ទៃ, *រាជរដ្ឋាភិបាលកម្ពុជាគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ សៀវភៅណែនាំស្តីពីកិច្ចការរដ្ឋបាលឃុំ សង្កាត់* ឆ្នាំ ២០០៥

ត្យ ឬការធ្វើអន្តរាគមន៍ទាំងនោះត្រូវបានអនុញ្ញាតដោយច្បាប់ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាសនិងលិខិតបទដ្ឋានដទៃទៀតដែលបានពិនិត្យ ឬក៏បានសម្រេចយល់ព្រមដោយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់។[38]

## ២.៦. វិធានការវិន័យ និងការបញ្ឈប់មុខដំណែងចំពោះសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបាត់បង់សមាជិកភាពរបស់ខ្លួនទៅតាមករណីណាមួយក្នុងចំណោមករណីដូចខាងក្រោមៈ

- សាមីខ្លួនទទួលមរណៈភាព
- សាមីខ្លួនបាត់បង់សម្បទាវិជ្ជាជីវៈដោយមានលិខិតបញ្ជាក់ពីក្រសួងស្ថាប័នមានសមត្ថកិច្ច
- សាមីខ្លួនសុំលាលែងជាលាយលក្ខណ៍អក្សរពីសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់
- សាមីខ្លួនត្រូវតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬមជ្ឈិមណាមួយ
- សមាជិកត្រូវបានបណ្តេញចេញដែលប្រព្រឹត្តផ្ទុយនឹងបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាឃុំ សង្កាត់
- ក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូលត្រូវរំសាយ
- សាមីខ្លួនបាត់បង់សមាជិកភាពពីគណបក្សនយោបាយរបស់ខ្លួន

កាលបើសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ណាមួយត្រូវបាត់បង់សមាជិកភាពត្រូវជ្រើសរើសបេក្ខជនដែលមានឈ្មោះបន្ទាប់តាមលេខរៀងក្នុងបញ្ជីបេក្ខជនជាមួយមកជំនួសដោយមិនបាច់បោះឆ្នោតឡើងវិញ។[39]

រាល់ការចាត់វិធានការដាក់វិន័យចំពោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ណាមួយត្រូវធ្វើឡើងដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់តាមការបោះឆ្នោតយល់ព្រមដោយសំឡេងភាគច្រើនដាច់ខាតនៃចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូល។ ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវផ្តល់ព័ត៌មានដល់ក្រសួងមហាផ្ទៃ និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតអំពីការបញ្ឈប់ពីមុខតំណែងជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់។[40]

[38] មាត្រា៤៣,៤៦,៤៧ នៃអនុក្រឹត្យស្តីពីការផ្ទេរមុខងារអំណាច តួនាទី និងភារកិច្ចទៅឲ្យក្រុមប្រឹក្សាឃុំសង្កាត់

[39] មាត្រា១៦ នៃច្បាប់ស្តីការគ្រប់គ្រងរដ្ឋបាលឃុំ_សង្កាត់_២០០១

[40] មាត្រា៣៤,៣៥ នៃអនុក្រឹត្យស្តីពីការផ្ទេរមុខងារអំណាច តួនាទី និងភារកិច្ចទៅឲ្យក្រុមប្រឹក្សាឃុំសង្កាត់

# ជំពូកទី ៣
# របកគំហើញនៃការស្រាវជ្រាវ

# ជំពូកទី ៣
# របកគំហើញលើការស្រាវជ្រាវ

## ៣.១ សមិទ្ធផលនៃការអនុវត្តគោលនយោបាយគ្រប់គ្រងរដ្ឋបាលតាមបែបវិមជ្ឈការ

### ៣.១.១ ការធ្វើប្រតិភូកម្មមុខងារជាក្លាក់ងារនៅឃុំ សង្កាត់

នៅក្នុងការអនុវត្តវិមជ្ឈការ ឃុំ សង្កាត់នេះ មានមុខងារជាក់លាក់ចំនួនពីរដែលត្រូវបានធ្វើប្រតិភូកម្មអំណាចដោយច្បាប់ និងលិខិតបទដ្ឋានទៅអោយឃុំ សង្កាត់គឺៈ

ការចុះបញ្ជីអត្រានុកូលដ្ឋាន ការធ្វើសំបុត្រកំណើត សំបុត្រអាពាហ៍ពិពាហ៍ និងសំបុត្រមរណភាពដែលមុខងារទាំងនេះបានផ្ដល់ទៅអោយឃុំ សង្កាត់អនុវត្តចាប់ពីការបោះឆ្នោតនៅឆ្នាំ ២០០២ មកម្ល៉េះ។ ក្នុងការគ្រប់គ្រងមុខងារនេះថ្នាក់ជាតិបានធ្វើការគាំទ្រសមត្ថភាពដល់ឃុំ សង្កាត់បានមួយកម្រិតតាមរយៈការបណ្ដុះបណ្ដាលដល់ស្មៀនឃុំ សង្កាត់ ការផ្ដល់ការណែនាំ និងការគាំទ្រ ជាប្រចាំដោយថ្នាក់ខេត្ត ក្រុង ស្រុក និងខណ្ឌ។ ទន្ទឹមនឹងនេះចំណូលដែលទទួលបាន ពីអត្រានុកូលដ្ឋាននៅឃុំ សង្កាត់ ត្រូវបានផ្ទេរជាចំណូលប្រចាំរបស់ឃុំ សង្កាត់ ដើម្បីឲ្យឃុំ សង្កាត់ចំណាយសម្រាប់អនុវត្តមុខងារនេះ។ ប៉ុន្តែទោះជាយ៉ាងណាក្ដីមុខងារនេះទាមទារឲ្យមានការពង្រឹង និងកែលម្អជាបន្ថែមទៀតសំដៅលើកកម្ពស់ការទទួលខុសត្រូវ ការអនុវត្ត។

ការរៀបចំបញ្ជីឈ្មោះ និងចុះឈ្មោះអ្នកបោះឆ្នោត ដែលការងារនេះត្រូវបានផ្ដល់ទៅអោយឃុំ សង្កាត់អនុវត្តចាប់ពីការបោះឆ្នោតជាតិលើកទី ៣ ហើយមុខងារនេះ នឹងត្រូវអនុវត្តជារៀងរាល់ឆ្នាំដោយឃុំ សង្កាត់។ លើសពីនេះទៅទៀតគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប) ដែលជាស្ថាប័នធ្វើប្រតិភូកម្មអំណាចបានផ្ដល់ការបណ្ដុះបណ្ដាលជូនក្រុមប្រឹក្សាឃុំ សង្កាត់ និងស្មៀនឃុំ សង្កាត់សម្រាប់ជំហានចាប់ផ្ដើមការអនុវត្តតែប៉ុណ្ណោះ។ រីឯធនធានសម្រាប់ចំណាយមួយផ្នែកធំស្ថិតនៅក្នុងបន្ទុករបស់(គ.ជ.ប) ជាអ្នកចំណាយផ្ទាល់។ ឃុំ សង្កាត់គ្រាន់តែបានទទួលសាហ៊ុយសម្រាប់ឧបត្ថម្ភស្មៀនតែប៉ុណ្ណោះ។ សរុបមកមុខងារដែលបានផ្ដល់ឱ្យឃុំ សង្កាត់ គឺជាដំណើរការចាប់ផ្ដើមប៉ុណ្ណោះហើយដំណើរការ ចាំបាច់ធ្វើការពិនិត្យអោយបានល្អិតល្អន់ទាំង សមត្ថភាព ការទទួលខុសត្រូវ ធនធាននិងប្រសិទ្ធភាពដែលទទួលបាន ដើម្បីឱ្យថ្នាក់ជាតិអាចពិចារណា និងផ្ទេរការងារផ្សេងទៀតទៅអោយឃុំ សង្កាត់ធ្វើការងារជាភ្នាក់ងារ ក្នុងការឆ្លើយតបទៅនឹងភាពជាក់ស្ដែងនៅក្នុងសង្គម។

### ៣.១.២ ហិរញ្ញវត្ថុឃុំ សង្កាត់

ឃុំ សង្កាត់កន្លងមកបានទទួលធនធានហិរញ្ញវត្ថុពីថវិកាឃុំ សង្កាត់ការចូលរួមរបស់ប្រជាពលរដ្ឋនៅតាមរយៈគម្រោង និងកម្មវិធីរបស់ដៃគូអភិវឌ្ឍន៍។ ប្រភពចំណូលផ្ទាល់របស់ឃុំ សង្កាត់ដែលរួមមានដូចជាចំណូលដែលបានមកពីពន្ធ និងមិនមែនពន្ធ និងប្រភពចំណូលផ្សេងទៀត។ ឃុំ សង្កាត់បានចូលរួមអភិវឌ្ឍន៍

មូលដ្ឋាន បើទោះបីមិនមានមុខងារច្បាស់លាស់ និងធនធានមានកម្រិតក៏ដោយ។ ឃុំ សង្កាត់បានចូលរួមក្នុងការផ្តល់សេវាសង្គមរួមមានដូចជា ការថែរក្សាសន្តិសុខ និងសណ្តាប់ធ្នាប់ ការគ្រប់គ្រងធនធានធម្មជាតិ ការដោះស្រាយជម្លោះ ការគ្រប់គ្រងទីផ្សារ និងកាកសំណល់ (ជាពិសេសនៅទីប្រជុំជន) ការអប់រំសុខភាព និងកសិកម្ម តាមរយៈការផ្តួចផ្តើមរបស់ក្រុមប្រឹក្សា ជាពិសេស មេឃុំ និងដើម្បីឆ្លើយតបទៅនឹងតម្រូវការមូលដ្ឋាន។

តួនាទីឃុំ សង្កាត់ទាក់ទងមុខងារខាងលើនេះ មិនបានអនុវត្តដូចគ្នាទេ។ ក្រៅពីកត្តាភាពជាអ្នកដឹកនាំរបស់មេឃុំ ចៅសង្កាត់មានកត្តាផ្សេងទៀតដូចជា ការគាំទ្រពីគណបក្សនយោបាយ អង្គការក្រៅរដ្ឋាភិបាល និងកិច្ចសហការពីមន្ទីរជំនាញ។ ឃុំ សង្កាត់មានបញ្ហាលំបាកក្នុងការបំពេញការងាររបស់ខ្លួនដោយសារតែធនធានរបស់ខ្លួននៅមានកម្រិត ក្រុមប្រឹក្សាឃុំ សង្កាត់ស្នើសុំឲ្យមានការបង្កើត និងកំណត់ឱ្យបានច្បាស់លាស់ពីមុខងារដែលប្រគល់ឲ្យ និងធនធានអមជាមួយមុខងារនេះ។[41] វិមជ្ឈការហិរញ្ញវត្ថុ គឺជាបញ្ហាដ៏ស្មុគស្មាញបំផុតនៅប្រទេសកម្ពុជា ទោះបីជាកំណែទម្រង់មានសភាពពិបាកបន្តិចបន្តួចក៏ដោយ យើងសង្កេតឃើញមានលក្ខណៈពិសេសមួយចំនួនសម្រាប់រដ្ឋបាលឃុំ សង្កាត់ដូចជា

- មានថវិកាដោយឡែកសម្រាប់ក្រុមប្រឹក្សា
- ការកំណត់ភាគរយនៃប្រាក់ចំណូលជាតិ សម្រាប់ផ្តល់ឲ្យថវិកាឃុំ សង្កាត់នៅក្នុងរយៈពេលដែលបានកំណត់ជារៀងរាល់ឆ្នាំ
- ជាតំណាងរបស់ឃុំ សង្កាត់នៅក្នុងក្រុមប្រឹក្សាភិបាលបែងចែកថវិកា
- ការផ្តល់ទុនបដិភាគពីប្រភពខាងក្រុមដល់មូលនិធិឃុំ សង្កាត់
- ការផ្តល់ថវិកាទៅក្រុមប្រឹក្សាឃុំ សង្កាត់ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យ និងការអនុវត្តការងារ
- ការកំណត់ឲ្យមានការត្រួតពិនិត្យដោយអាជ្ញាធរនៅថ្នាក់លើទាក់ទងទៅនឹងថវិកាជំនួយវិភាជន៍និងការគ្រប់គ្រងហិរញ្ញវត្ថុ
- ការសម្របសម្រួលអន្តរក្រសួង នៅក្នុងចំណោមក្រសួងសំខាន់ៗដូចជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ
- ការកំណត់ឲ្យមានប្រភពចំណូលផ្ទាល់របស់ក្រុមប្រឹក្សា ដោយស្ថិតនៅក្រោមច្បាប់
- ការធ្វើប្រតិភូកម្មមុខងារជាភ្នាក់ងារទៅក្រុមប្រឹក្សាឃុំ សង្កាត់ អមទៅដោយធនធានហិរញ្ញវត្ថុចាំបាច់ និងប្រព័ន្ធធ្វើសវនកម្ម។

---

[41] ខុមព្រៀល, *ការសិក្សាវាយតម្លៃអាណត្តិទីពីរនៃកំណែទម្រង់វិមជ្ឈការនៅកម្ពុជា:ការអនុវត្តរបស់ក្រុមប្រឹក្សាឃុំនិងការចូលរួមរបស់ប្រជាពលរដ្ឋ ២០០៧-២០១២*, ឆ្នាំ ២០១៣

### ៣.១.៣ ការកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍក្នុងមូលដ្ឋាន

ការកាត់បន្ថយភាពក្រីក្រ គឺជាទិសដៅមួយនៃគោលនយោបាយវិមជ្ឈការនៅឃុំ សង្កាត់ ហើយរាជរដ្ឋាភិបាលបានកំណត់ចំនួនទឹកប្រាក់សម្រាប់ជំនួយវិភាជន៍អភិវឌ្ឍន៍ឃុំ សង្កាត់ ដោយផ្អែកទៅលើសន្ទស្សន៍នៃភាពក្រីក្រ ដែលនាំអោយមានការអនុវត្តប្រកបដោយប្រសិទ្ធភាព។ រាជរដ្ឋាភិបាលបានចាប់ផ្តើមអនុវត្តគោលនយោបាយ ដោយមានកត្តាជាច្រើនចូលរួមកាត់បន្ថយភាពក្រីក្រ ដូចជា ការយកចិត្តទុកដាក់ទៅលើការអភិវឌ្ឍនៃហេដ្ឋារចនាសម្ព័ន្ធ នៅក្នុងដំណើរការកសាងផែនការដែលមានការចូលរួមក្នុងការកំណត់តម្រូវការអភិវឌ្ឍនៅក្នុងមូលដ្ឋានការចូលរួមគាំទ្រគម្រោងអភិវឌ្ឍន៍របស់ឃុំសង្កាត់ ដោយសប្បុរសជន និង អង្គការមិនមែនរាជរដ្ឋាភិបាលនានាជាច្រើន។

ដូចនេះការកាត់បន្ថយភាពក្រីក្រស្តែងឡើងនៅក្នុងការអនុវត្តគម្រោងឃុំ សង្កាត់អភិវឌ្ឍន៍ឃុំ សង្កាត់នានា ដែលជាទូទៅគម្រោងទាំងនោះមានចរិតជាគម្រោងវិនិយោគខ្នាតតូច ដែលជាគម្រោងហេដ្ឋារចនាសម្ព័ន្ធ គម្រោងលើកកំពស់ជីវភាពរស់នៅ ឬគម្រោងបង្កើនប្រាក់ចំណូល និងគម្រោងសេវានានាក្នុងគោលដៅដោះស្រាយតម្រូវការជាបន្ទាន់នៅមូលដ្ឋាន និង លើកកំពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅមូលដ្ឋានឲ្យកាន់តែប្រសើរឡើង។

### ៣.១.៤.ការគាំទ្រនិងការតាមដានត្រួតពិនិត្យការអនុវត្តថវិកា ឬមូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិ

នៅក្នុងគម្រោងមូលនិធិឃុំ សង្កាត់ បើគិតត្រឹមខែកញ្ញា ឆ្នាំ ២០១៩ គម្រោងមូលនិធិឃុំ សង្កាត់ ដែលបានគ្រោងឡើងក្នុងឆ្នាំ ២០១៨ ចំនួន ១៧៥៣គម្រោង បានចុះកិច្ចសន្យាសាងសង់រួចចំនួន ១៧៣២គម្រោង (ក្នុងនោះបានបញ្ចប់ការសាងសង់ជាស្ថាពរចំនួន ១៥៧៨គម្រោង) កំពុងត្រៀមចុះកិច្ចសន្យាសាងសង់ចំនួន ៥ គម្រោង កំពុងត្រៀមរៀបចំធ្វើកិច្ចលទ្ធកម្មចំនួន ១០ គម្រោង និងកំពុងដំណើរការសិក្សាចំនួន ៦ គម្រោង។ ដោយឡែកគម្រោងមូលនិធិឃុំ សង្កាត់ដែលគ្រោងឡើងក្នុងឆ្នាំ ២០១៩ ចំនួន ១៧៩៨ គម្រោង បានចុះកិច្ចសន្យាសាងសង់រួចចំនួន ៨៥៩ គម្រោង (ក្នុងនោះបានបញ្ចប់ការសាងសង់ជាស្ថាពរចំនួន ១៥១ គម្រោង) កំពុងត្រៀមចុះកិច្ចសន្យាសាងសង់ចំនួន ១៩៣ គម្រោង កំពុងរៀបចំធ្វើកិច្ចលទ្ធកម្មចំនួន ៣៤៧ គម្រោង កំពុងដំណើរការសិក្សាចំនួន ៣៤១ ទម្រនិងមិនទាន់សិក្សាចំនួន ៥៨ គម្រោង។[42]

[42]ទីស្តីការគណៈរដ្ឋមន្ត្រី, *របាយការណ៍សង្ខេបស្តីពីសមិទ្ធផលខានសំខាន់មួយឆ្នាំនៃការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានីតិកាលទី ៦ នៃរដ្ឋសភាឆ្នាំ ២០១៨-២០១៩*, ឆ្នាំ ២០២០

## ៣.២ បញ្ហាប្រឈម

### ៣.២.១ ការផ្តល់សេវាសាធារណៈ

ការសម្រេចជាគន្លឹះរបស់ក្រុមប្រឹក្សាឃុំនៅក្នុងអាណត្តិទី២ គឺពាក់ព័ន្ធនឹងការរីកចម្រើននៃហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ជាពិសេសផ្លូវលំជនបទ។ ប្រការដែលផ្លូវលំជនបទក្លាយជាជម្រើសវិនិយោគដ៏មានប្រជាប្រិយខ្លាំងបំផុតនោះគឺ ពាក់ព័ន្ធនឹងហេតុផលជាច្រើន។ ក្រៅពីវាជាតម្រូវការមូលដ្ឋានការសម្រេចចិត្តក្នុងការជ្រើសរើសផ្លូវលំជនបទ គឺពាក់ព័ន្ធនឹងហេតុផលសេដ្ឋកិច្ចនយោបាយដែលផ្លូវលំអាចជួយលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន។ ជ្រើសរើសផ្លូវលំជនបទក៏អាចឆ្លើយតបនឹងតម្រូវការមូលដ្ឋាន និងសមស្របនឹងសមត្ថភាពបច្ចេកទេស និងធនធានមានកម្រិតរបស់ឃុំ។

ទោះបីជាក្រុមប្រឹក្សាឃុំ សង្កាត់ចាប់អារម្មណ៏តែទៅលើការសាងសង់ផ្លូវលំជនបទ ក្រុមប្រឹក្សាឃុំពុំសូវសម្តែងការចាប់អារម្មណ៍ទៅលើហេដ្ឋារចនាសម្ព័ន្ធផ្សេងទៀតដូចជាធារាសាស្ត្រទេ។ ក្រុមប្រឹក្សាឃុំធ្វើការវិនិយោគតិចតួចលើផ្នែកធារាសាស្ត្រ ដោយសារពួកគេព្រួយបារម្ភអំពីហានិភ័យដែលបង្កដោយគម្រោង។ ធារាសាស្ត្រគឺសមស្របសម្រាប់តែទីតាំងភូមិសាស្ត្រណាមួយ ហើយវិនិយោគក្នុងគម្រោងបែបនេះតម្រូវឱ្យក្រុមប្រឹក្សាឃុំ ត្រូវធ្វើផែនការសម្រាប់ធនធានមនុស្ស ដែលមានជំនាញក្នុងការគ្រប់គ្រង ត្រួតត្រា និងថែទាំធារាសាស្ត្រ។ ម្យ៉ាងទៀតក្រៅពីការផ្តល់សេវាអត្រានុកូលដ្ឋាន ក្រុមប្រឹក្សាឃុំក៏ខិតខំចុះអន្តរាគមន៍ក្នុងសេវាផ្សេងទៀតដូចជា ការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ ការជួលជុលសាលារៀន និងសេវាសុខភាពមាតា និងកុមារ អាហារូបត្ថម្ភ កិច្ចគាំពារកុមារ និងការគាំទ្រដល់គ្រួសារដែលងាយទទួលរងគ្រោះថ្នាក់។ ទោះជាយ៉ាងណាក៏ដោយសេវាទាំងអស់នេះ គឺមិនសូវពេញនិយមក្នុងចំណោមក្រុមប្រឹក្សាឃុំឡើយ ពីព្រោះវាទាមទារឲ្យមានការចុះពិនិត្យតាមដាន និងការសម្របសម្រួលជាមួយក្រសួងជំនាញ ដែលនេះអាចបណ្តាលឱ្យមានភាពយឺតយ៉ាវ ឬការខ្វះបុគ្គលិកជំនាញចុះមកអនុវត្តការងារ។

ការផ្តល់សេវារបស់ក្រុមប្រឹក្សាឃុំ គឺ ផ្អែកទៅលើចំណេះដឹងលើតម្រូវការប្រជាពលរដ្ឋ និងចំនួនថវិកាដែលមាន។ ដោយសារថវិកាក្រុមប្រឹក្សាឃុំ សង្កាត់មានកម្រិតតិចតួច ឃុំពុំអាចផ្តល់សេវាឲ្យមានប្រសិទ្ធភាពដល់ប្រជាពលរដ្ឋឡើយ ដូច្នេះឃុំត្រូវពឹងផ្អែកលើគណបក្សនយោបាយ និងសប្បុរសជន។ គេបានរកឃើញថាថវិការបស់គណបក្សនយោបាយកន្លងមកបានចូលរួមយ៉ាងច្រើន ដល់ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធនៅមូលដ្ឋាន ជាពិសេស សាលារៀន ធារាសាស្ត្រ និងផ្លូវលំជនបទ។ ហិរញ្ញវត្ថុរបស់គណបក្សនយោបាយមានលក្ខណៈមិនទៀងទាត់ វាអាស្រ័យទៅលើវដ្តនៃការបោះឆ្នោត និងភាគច្រើន គឺ ផ្តោតទៅលើហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដូច

ជាការសាងសង់សាលារៀន ប៉ុន្តែពុំបានផ្តោតទៅលើការលើកទឹកចិត្តគ្រូបង្រៀនឲ្យចុះ នឹងធ្វើការបង្រៀនទៀងទាត់នោះទេ។[43]

### ៣.២.២ ធនធានមនុស្ស និងការអភិវឌ្ឍសមត្ថភាព

សមត្ថភាពធនធានមនុស្ស និងស្ថាប័ន នៅមានកម្រិតក្នុងការឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ពលរដ្ឋពិសេសនៅរដ្ឋបាលថ្នាក់ក្រោមជាតិនេះឯង។ ចំណុចដែលជាបញ្ហាប្រឈមខ្លាំងនៅក្នុងការគ្រប់គ្រងធនធានមនុស្សមានដូចជា ការរៀបចំតួនាទីភារកិច្ច របៀបគ្រប់គ្រង និងការចាត់ចែងការងារមិនទាន់មានភាពច្បាស់លាស់នៅឡើយ។ ចំណែកការគ្រប់គ្រងធនធានជំនាញ និងចំនួនមន្ត្រីក៏មិនទាន់ឆ្លើយតបទៅនឹងសេចក្តីត្រូវការ។ ការលើកកម្ពស់គុណភាព និងការទទួលខុសត្រូវរបស់មន្ត្រីនៅមិនទាន់មានភាពល្អប្រសើរនៅឡើយ។ ជាពិសេសគឺ ការអភិវឌ្ឍសមត្ថភាពការងារ និងការពង្រឹងសីលធម៌ និងវិន័យរបស់មន្ត្រីនៅក្នុងថ្នាក់ឃុំ សង្កាត់នេះផ្ទាល់។[44]

### ៣.២.៣. ការចូលរួមរបស់ប្រជាពលរដ្ឋ

ការចូលរួមរបស់ប្រជាពលរដ្ឋនៅមានកម្រិតទាបនៅក្នុងអាណត្តិទី១នៃក្រុមប្រឹក្សាឃុំសង្កាត់។ ទោះបីជាប្រជាពលរដ្ឋហាក់បីដូចជា បានសម្តែងការយល់ដឹងកាន់តែប្រសើរស្តីអំពីសេរីភាពក្នុងការបញ្ចេញមតិ និងការចូលរួមជាសមាជិកនៅក្នុងអង្គការនានា ឬសហគមន៍ ក៏ដោយការចូលរួមរបស់ប្រជាពលរដ្ឋនៅមានកម្រិតទាបដែលជាពិសេសនៅក្នុងការរៀបចំថវិកា និងធ្វើផែនការរបស់ឃុំ សង្កាត់ ។ នៅក្នុងការប្រជុំនៅតាមភូមិ ឃុំ គឺមានការចូលរួមតិចតួចនៅឡើយទាំងគុណភាព និងបរិមាណ។ ការប្រជុំថ្នាក់ភូមិ ត្រូវបានគេចាត់ទុកថាជាព្រឹត្តិការណ៍មួយ ដែលអ្នកភូមិអាចចូលរួមចំណែកផ្តល់មតិយោបល់ និងលើកនូវតម្រូវការរបស់ពួកគាត់ក្នុងសកម្មភាពអភិវឌ្ឍនានានៅក្នុងភូមិ ឃុំរបស់ពួកគាត់។ នៅក្នុងការប្រជុំគណៈភូមិមួយ គឺតម្រូវឱ្យមានការចូលរួមយ៉ាងតិច ៥០% នៅភូមិស្រុកប៉ុន្តែតាមភាពជាក់ស្តែងនៅភូមិជា ឬមិនអាចរកបានតាមចំនួនប៉ុន្មានទេដែលនៅទីបញ្ចប់ការប្រជុំមានតែអ្នកភូមិតិចតួចប៉ុណ្ណោះដែលបានចូលរួម។ ការចូលរួមប្រជុំថ្នាក់ភូមិ គឺមិនសូវមានការបញ្ចេញមតិនោះទេនេះបើប្រៀបធៀបទៅនឹងការប្រជុំរៀបចំឡើងដោយអង្គការ និងគណបក្សនយោបាយនានា ។ មូលហេតុចម្បងពីបញ្ហានេះ គឺបណ្តាលមកពីកង្វះខាតនៃការលើកទឹកចិត្តក្នុងការចូលរួមចំណែកនូវជំនាញ និងការរៀបចំការប្រជុំ។ ការប្រជុំថ្នាក់ភូមិគឺត្រូវបានធ្វើឡើងក្នុងគោលបំណង ដើម្បីផ្តល់ព័ត៌មានជាមុនក្នុងការធ្វើសេ

[43] ខុមហ្វ្រេល,*ការសិក្សាវាយតម្លៃអាណត្តិទីពីរនៃកំណែទម្រង់វិមជ្ឈការនៅកម្ពុជា:ការអនុវត្តរបស់ក្រុមប្រឹក្សាឃុំនិងការចូលរួមរបស់ប្រជាពលរដ្ឋ ២០០៧-២០១២,* ឆ្នាំ ២០១៣

[44] រាជរដ្ឋាភិបាលកម្ពុជាគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ, *កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ២០១៥-២០១៨*, ឆ្នាំ ២០១៥

ចក្តីសម្រេចចិត្ត ។ អ្នកភូមិដែលបានចូលរួមការប្រជុំនេះគឺគ្រាន់តែស្តាប់តែប៉ុណ្ណោះ ប៉ុន្តែពួកគាត់ពុំបានធ្វើការទាមទារលើកឡើងពីបញ្ហាដែលពួកគាត់ជួបប្រទះនោះទេ។

បើទោះបីជាច្បាប់ឃុំ សង្កាត់បាននិយាយថា ការប្រជុំគណៈឃុំ សង្កាត់ត្រូវតែបើកចំហដល់សាធារណជនចូលរួមក៏ដោយតែបើតាមជាក់ស្តែងការប្រជុំនេះ គឺបើកចំហចំពោះតែអ្នកដែលត្រូវបានអញ្ជើញតែប៉ុណ្ណោះដូចជាមេភូមិ ឬមន្ត្រីគាំទ្របច្ចេកទេស ។ បើទោះបីជាអ្នកភូមិត្រូវបានគេអនុញ្ញាតឲ្យចូលរួមក្នុងការប្រជុំក្រុមប្រឹក្សានៅតាមឃុំ សង្កាត់មួយចំនួនក៏ដោយក៏ឱកាសសម្រាប់ពួកគាត់ និងការចូលរួមធ្វើសេចក្តីសម្រេចចិត្តនៅមានកម្រិតនៅឡើយ ។

គួរឲ្យចាប់អារម្មណ៍ផងដែរនោះ គឺគេក៏បានរកឃើញថាក្នុងកំឡុងពេលចាំបាច់កម្រិតនៃការចូលរួមមានការកើនឡើងដែលអ្នកភូមិបានប្រមូលផ្តុំ និងលើកឡើងពីតម្រូវការរបស់ពួកគាត់តទៅដល់ក្រុមប្រឹក្សាឃុំចំពោះបញ្ហាដែលពួកគាត់មាន ។[45]

## ៣.៣ ដំណោះស្រាយ

### ៣.៣.១ ពង្រឹងគុណភាពការផ្តល់សេវាសាធារណៈ

ដើម្បីពង្រឹងគុណភាព និងប្រសិទ្ធភាព ក្នុងការផ្តល់សេវាសាធារណៈ រាជរដ្ឋាភិបាលបានអនុម័តឯកសារស្តីពីស្តង់ដារសេវាសាធារណៈ ដែលមានសូចនាករគោលចំនួន ៥ ដើម្បីធ្វើឲ្យប្រសើរឡើងនូវកម្រិតនៃភាពឆ្លើយតប ជំនឿទុកចិត្ត ប្រសិទ្ធភាព និងប្រសិទ្ធផលនៃសេវាសាធារណៈ។ សូចនាករគោលទាំង ៥ នៃស្តង់ដារសេវាសាធារណៈរួមមាន គុណភាពព័ត៌មានដែលផ្តល់ជូនអ្នកប្រើប្រាស់សេវា ភាពងាយស្រួលក្នុងការទទួលយកសេវា ភាពយកចិត្តទុកដាក់ក្នុងការទទួលអ្នកប្រើប្រាស់សេវា សេវាប្រើតាមគោលការណ៍កំណត់ និងមានអភិបាលកិច្ចល្អ និងយន្តការព័ត៌មានត្រឡប់ និងបណ្តឹងតវ៉ារបស់អ្នកប្រើប្រាស់សេវា។

### ៣.៣.២ ពង្រឹងការគ្រប់គ្រងធនធានមនុស្ស និងការអភិវឌ្ឍសមត្ថភាព

ការអភិវឌ្ឍសមត្ថភាព ការកែលម្អ ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សតាមរយៈការជំរុញអនុវត្តគោលនយោបាយធនធានមនុស្សក្នុងន័យរដ្ឋបាលសាធារណៈ ដើម្បីលើកកម្ពស់គុណផលមន្ត្រី និងជំរុញការប្រកាន់ខ្ជាប់នូវវប្បធម៌សេវាសាធារណៈ ឆន្ទៈម្ចាស់ការ ភក្តីភាព និងមនសិការវិជ្ជាជីវៈ។

ដើម្បីអភិវឌ្ឍសមត្ថភាព កែលម្អការគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្ស រាជរដ្ឋាភិបាលបានអនុម័តគោលនយោបាយធនធានមនុស្សក្នុងរដ្ឋបាលសាធារណៈ ដើម្បីបង្កើនគុណផលនៅក្នុងរដ្ឋបាលសាធារណៈ និងផ្លាស់ប្តូរឥរិយាបថមន្ត្រីជាបណ្តើរៗសំដៅលើកកម្ពស់ទឹកដីថ្លៃថ្នូរ ការលើកទឹកចិត្ត ភក្តីភាព និងមនសិកាវិជ្ជា

[45] ខុមប្រែល, *ការសិក្សាវាយតម្លៃអាណត្តិទីពីរនៃកំណែទម្រង់វិមជ្ឈការនៅកម្ពុជា:ការអនុវត្តរបស់ក្រុមប្រឹក្សាឃុំនិងការចូលរួមរបស់ប្រជាពលរដ្ឋ ២០០៧-២០១២*, ឆ្នាំ ២០១៣

ជីវៈរបស់មន្ត្រីរាជការ និងគោលនយោបាយស្តីពីការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិគោលនយោបាយធនធានមនុស្សក្នុងរដ្ឋបាលសាធារណៈបានកំណត់នូវនៅយុទ្ធសាស្ត្រចំនួន ៥ រួមមានធ្វើឲ្យប្រសើរឡើងនូវប្រព័ន្ធការងារក្នុងអង្គភាព និងការគ្រប់គ្រងមន្ត្រីពង្រឹងប្រសិទ្ធភាពនៃដំណើរការអនុវត្តការគ្រប់គ្រងធនធានមនុស្ស អនុវត្តប្រព័ន្ធគ្រប់គ្រងគុណផល ប្រើប្រាស់ឲ្យកាន់តែប្រសើរឡើងនូវសមត្ថភាពការងារ ដែលមានស្រាប់ និងអភិវឌ្ឍសមត្ថភាពការងារថ្មី និងផ្តល់ការបណ្តុះបណ្តាល និងលើកកម្ពស់គុណភាពនៃការបណ្តុះបណ្តាល។

គោលនយោបាយស្តីពីការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិបានកំណត់នូវយុទ្ធសាស្ត្រចំនួន៣ បន្ថែមទៀតរួមមានការរៀបចំក្របខ័ណ្ឌគតិយុត្តអន្តរកាល និងការរៀបចំក្របខ័ណ្ឌគតិយុត្តអចិន្ត្រៃយ៍ ការអភិវឌ្ឍប្រព័ន្ធគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងការពង្រឹង និងពង្រីកសមត្ថភាពជំនាញចំណេះដឹងបទពិសោធន៍ ក្នុងការអនុវត្តប្រព័ន្ធអចិន្ត្រៃយ៍សម្រាប់គ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។[46]

### ៣.៣.៣. ពង្រឹងការចូលរួមរបស់ប្រជាពលរដ្ឋ

ចំពោះវត្តមាននៃការចូលរួមរបស់ប្រជាពលរដ្ឋ គឺជារឿងមួយដែលគួរតែមានការយកចិត្តទុកដាក់យ៉ាងខ្លាំង ដោយសារតែប្រជាពលរដ្ឋ គឺជាអ្នកប្រើប្រាស់សេវា ហើយយើងត្រូវដឹងពីតម្រូវការរបស់ពួកគាត់ ដើម្បីឲ្យសេវាដែលយើងផ្តល់ឲ្យនោះចំគោលដៅដែលពួកគាត់ចង់បាន។ ការផ្តល់មតិយោបល់ពីសំណាក់ប្រជាពលរដ្ឋពិតណាស់ គឺរឹតតែមានសារៈសំខាន់នៅក្នុងការប្រជុំម្តង ព្រោះថាបើប្រជាពលរដ្ឋចូលរួមគ្រាន់តែស្តាប់មិនបានបញ្ចេញមតិយោបល់ឬ ប្រាប់ពីបញ្ហាដែលពួកគាត់ជួបប្រទះកន្លងមកទេនោះ នោះក្រុមប្រឹក្សាក៏មិនអាចមានព័ត៌មានគ្រប់គ្រាន់ ដើម្បីធ្វើផែនការអភិវឌ្ឍន៍បន្តទៀតផងដែរ។ ដើម្បីជំរុញឲ្យមានការចូលរួមពីសំណាក់ប្រជាពលរដ្ឋ និងឲ្យមានការបញ្ចេញមតិយោបល់ផងដែរនោះ យើងគួរតែអនុវត្តឲ្យបានល្អទៅលើការបើកចំហឲ្យសាធារណជនឬ អ្នកភូមិបានចូលរួមនៅក្នុងការប្រជុំម្តងៗ។ ម្យ៉ាងទៀតចំពោះការបញ្ចេញមតិយោបល់ គឺគួរតែបើកឱកាសដល់មេភូមិដើម្បីពិភាក្សាពីការវិវត្តន៍នៃផែនការ បញ្ហាផ្សេងៗទៀតដែលទាក់ទិនទៅនឹងការអនុវត្តផែនការនៅក្នុងឃុំ សង្កាត់របស់ពួកគាត់ និងមានឱកាសក្នុងការបញ្ចេញមតិពីតម្រូវការរបស់អ្នកភូមិផងដែរ។ មួយវិញទៀតតាមរយៈការកត់សម្គាល់មួយចំនួនបានបង្ហាញឲ្យឃើញថាអ្នកភូមិភាគច្រើនហាក់ដូចជា ចូលចិត្តលើកពីតម្រូវការរបស់ពួកគេទៅកាន់មេភូមិ ឬចាស់ទុំនៅក្នុងភូមិដែលពួកគេគេអាចលើកពីបញ្ហានេះបន្តទៅក្រុម

[46] រាជរដ្ឋាភិបាលកម្ពុជាគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ, *កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ២០១៥-២០១៨*, ឆ្នាំ ២០១៥

ប្រឹក្សាឃុំវិញបាន។ ដូចនេះដើម្បីងាយស្រួលដល់ប្រជាពលរដ្ឋ យើងគួរតែមានការអញ្ជើញដល់ជនបង្គោល អ្នកពាក់ព័ន្ធផ្សេងៗនិងប្រជាពលរដ្ឋ ចាស់ព្រឹទ្ធាចារ្យនៅក្នុងភូមិបានចូលរួមស្តាប់ និងផ្តល់យោបល់ដល់អង្គប្រជុំដើម្បីដឹងច្បាស់ ហើយទទួលយកអនុសាសន៍ពីបញ្ហាប្រឈមនានាដែលបានកើតឡើងនៅក្នុងមូលដ្ឋានដើម្បីងាយស្រួលក្នុងការដោះស្រាយ ចាត់វិធានការទាន់ពេលវេលា និងចំគោលដៅច្បាស់លាស់។

# សេចក្តីសន្និដ្ឋាន

ការគ្រប់គ្រងរដ្ឋបាលតាមបែបវិមជ្ឈការ គឺជាការធ្វើកំណែទម្រង់ដឹកនាំឃុំ សង្កាត់តាមរបបប្រជាធិបតេយ្យ ដែលផ្តល់សេរីភាពពេញលេញក្នុងការឱ្យមានការចូលរួមពីសំណាក់ប្រជាពលរដ្ឋក្នុងការអភិវឌ្ឍន៍មូលដ្ឋាន ដើម្បីបម្រើផលប្រយោជន៍ក្នុងឃុំ សង្កាត់របស់ខ្លួន តាមរយៈការចាត់ចែង មើលថែ ប្រើប្រាស់ថវិកា និងការផ្តល់សេវាសាធារណៈអោយមានប្រសិទ្ធភាពពីមន្ត្រីក្នុងមូលដ្ឋាន ។ វិមជ្ឈការឃុំ សង្កាត់មានទិសដៅជម្រុញអោយប្រជាពលរដ្ឋបានចូលរួមយ៉ាងសកម្មនៅក្នុងសកម្មភាពក្នុងឃុំ សង្កាត់ និងដំណើរការនៃការអភិវឌ្ឍមូលដ្ឋាន និងការចូលរួមចំណែកតាមមធ្យោបាយផ្សេងៗ ។ វាជាមធ្យោបាយដែលផ្សារភ្ជាប់នៅគោលការណ៍វិមជ្ឈការរបស់រដ្ឋាភិបាលក្នុងការផ្តល់ជូនប្រជាពលរដ្ឋនៅអភិបាលកិច្ចល្អ ដោយការសម្រេចចិត្តតាមរយៈរដ្ឋបាលឃុំ សង្កាត់ ដែលជាអង្គការដែលនៅជិតបំផុតនឹងប្រជាពលរដ្ឋ ហើយអាចដឹងច្បាស់អំពីសេចក្តីត្រូវការរបស់ពួកគាត់។ ក្រុមប្រឹក្សាឃុំ សង្កាត់ បានខិតខំរៀបចំផែនការនិងកម្មវិធីធ្វើយ៉ាងណា ដើម្បីជួយលើកកម្ពស់និងកែលម្អជីវភាពរបស់ប្រជាពលរដ្ឋដែលរស់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងដើម្បីឲ្យការប្រើប្រាស់ធនធាននៅក្នុងឃុំ សង្កាត់របស់ខ្លួនមានប្រសិទ្ធិភាព ហើយឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ ។ លើសពីនេះវាជាការលើកកម្ពស់អោយឃុំ សង្កាត់មានអភិបាលកិច្ចល្អ និងគុណភាពនៃការរស់នៅរបស់ប្រជាពលរដ្ឋ ទាំងក្នុងការទទួលបាននូវសេវាសាធារណៈល្អ និងការរស់នៅប្រកបដោយសុខសុវត្ថិភាព តាមរយៈការខិតខំបំពេញកិច្ចការរបស់ខ្លួន ចាត់ចែងធនធានអោយបានសមស្រប ការផ្តល់ព័ត៌មាននៃការអភិវឌ្ឍន៍ និងការចូលរួមពិនិត្យតាមដានលើការងារ ថវិកា និងការបំពេញការងាររបស់តំណាងរបស់ខ្លួន ដើម្បីឱ្យដឹងថាការប្រើប្រាស់ធនធានមនុស្សពិតជាបានបម្រើដល់ផលប្រយោជន៍របស់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន ដូចជាការកសាងផែនការ និងគម្រោងនានា។ ការគ្រប់គ្រងរដ្ឋបាលតាមប្រព័ន្ធវិមជ្ឈការទាមទាមអោយមានការប្រាស្រ័យទាក់ទងរវាងប្រជាពលរដ្ឋក្នុងឃុំ សង្កាត់ និងរដ្ឋបាលឃុំ សង្កាត់ ដើម្បីអោយមានប្រសិទ្ធិភាពឆ្លើយតបទៅនឹងយន្តការវិមជ្ឈការ ដែលមានប្រជាពលរដ្ឋជាស្នូលសំខាន់ ។

ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការនេះ ជាកាតាលីករមួយនៅក្នុងការអភិវឌ្ឍន៍ និងជំរុញអោយឃុំ សង្កាត់នីមួយៗបោះជំហានទៅមុខដោយភាពរឹងមាំពោលគឺ ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានទទួលបាននៅផលប្រយោជន៍ដែលឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ខ្លួន ពីព្រោះប្រជាពលរដ្ឋម្នាក់ៗ គឺជាធនធានដ៏សំខាន់នៅក្នុងការជួយលើកកម្ពស់ទៅលើការរីកចម្រើនគ្រប់វិស័យទាំងអស់នៅក្នុងប្រទេសកម្ពុជា ។ ដូច្នេះរាជរដ្ឋាភិបាលបានខិតខំដាក់ចេញនូវគោលនយោបាយ និងកំណែទម្រង់ឲ្យកាន់តែមានភាពល្អប្រសើរធ្វើយ៉ាងណាធានានូវការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។ លើសពីនេះដើម្បីសម្រេចបាននូវគោលការណ៍ទាំងនេះទាមទារឲ្យមានការចូលរួមពីប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន និងក្នុងការបញ្ចេញមតិ

យោបល់ ការតាមដានត្រួតពិនិត្យ និងការចូលរួមផ្សេងៗទាំងតាមរយៈការចូលរួមដោយផ្ទាល់ និងការចូលរួមតាមរយៈអ្នកតំណាងរបស់ខ្លួន ព្រោះប្រជាជន គឺជាចលករដ៏សំខាន់នៅក្នុងការអភិវឌ្ឍ និងស្ថាបនាឃុំ សង្កាត់របស់ខ្លួន ព្រមទាំងប្រទេសជាតិទាំងមូលផងដែរ។

# អនុសាសន៍

ឆ្លងតាមការសិក្សាស្រាវជ្រាវ និងការធ្វើបទបង្ហាញស្តីពី ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការរួចមក បានបង្ហាញឲ្យឃើញថាការគ្រប់គ្រងប្រព័ន្ធរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការជាគោលការណ៍មួយដែលបានផ្តល់ផលប្រយោជន៍ទូលំទូលាយដល់ប្រជាពលរដ្ឋកម្ពុជា តាមរយៈមន្ត្រីរដ្ឋបាលនៅតាមមូលដ្ឋានឃុំ សង្កាត់ស្របតាមកំណែទម្រង់ និងទិសដៅវិមជ្ឈការរបស់រាជរដ្ឋាភិបាល ។ យ៉ាងណាមិញការអនុវត្តជាក់ស្តែងនូវគោលការណ៍វិមជ្ឈការនៅមានចំណុចខ្វះខាតមួយចំនួន ដែលទាមទារឲ្យមានការអភិវឌ្ឍន៍ និងពង្រឹងបន្ថែមដើម្បីឱ្យប្រជាជនទទួលបាននូវផលប្រយោជន៍ និងមានទំនុកចិត្តលើតំណាងរបស់ខ្លួន ថែមទាំងជម្រុញនូវការអនុវត្តជាក់ស្តែងឱ្យកាន់តែមានប្រសិទ្ធិភាព ការអភិវឌ្ឍ និងតម្លាភាព។ មានកត្តាមួយចំនួនដែលអាចជួយឲ្យការដំណើរអនុវត្តគោលការណ៍វិមជ្ឈការឃុំ សង្កាត់កាន់តែមានប្រសិទ្ធិភាពប្រសើរជាងមុនដូចខាងក្រោម ៖

១.ចំពោះអាជ្ញាធរមានសមត្ថកិច្ច

- ក្រុមប្រឹក្សាឃុំគួរតែបង្កើនការយកចិត្តទុកដាក់ទៅលើបញ្ហារបស់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន ក៏ដូចជាផ្តល់ឱកាសឲ្យប្រជាពលរដ្ឋទទួលបានក្នុងការចូលរួម និងផ្តល់មតិយោបល់ ឬក៏ចូលរួមស្តាប់នៅក្នុងការប្រជុំសម្រេចចិត្តអំពីបញ្ហា និងអំពីតម្រូវការនានានៅក្នុងមូលដ្ឋានរស់នៅ
- ក្រុមប្រឹក្សាឃុំ សង្កាត់គួរតែពង្រឹង និងធ្វើការត្រួតពិនិត្យអោយបានទៀងទាត់លើការបំពេញតួនាទីរបស់បុគ្គលិកម្នាក់ៗទៅតាមមុខជំនាញ ជាពិសេសត្រួតពិនិត្យទៅលើឥរិយាបទ សីលធម៌ និងវិន័យនៅក្នុងការបំពេញការងារជាប្រចាំដែលសំខាន់នោះ គឺការផ្តល់សេវាសាធារណៈឱ្យប្រជាពលរដ្ឋ
- ក្រុមប្រឹក្សាឃុំ សង្កាត់គួរតែចុះជួបប្រជាពលរដ្ឋឲ្យបានញឹកញាប់ ដើម្បីដឹងពីសុខទុក្ខ និងតម្រូវការពិតប្រាកដរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋានរបស់ខ្លួន ដើម្បីឲ្យការអនុវត្តគោលការណ៍ប្រកបដោយភាពជោគជ័យ និងឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋានដែលខ្លួនគ្រប់គ្រង។

២. ចំពោះប្រជាពលរដ្ឋក្នុងមូលដ្ឋាន

- ចូលរួមក្នុងការប្រជុំ ជាមួយនឹងអាជ្ញាធរដែនដីអោយបានច្រើន និងចូលរួមបញ្ចេញមតិយោបល់ដែលខ្លួនគិតថាអាចមានប្រយោជន៍នៅក្នុងការអភិវឌ្ឍន៍ឃុំ សង្កាត់របស់ខ្លួន ។
- ចូលរួមទាំងអស់គ្នានៅក្នុងការតាមដានត្រួតពិនិត្យនូវសកម្មភាពការងាររបស់មន្ត្រីឃុំ សង្កាត់ក្នុងការអនុវត្ត និងប្រើប្រាស់ថវិកា ដើម្បីជាប្រយោជន៍អភិវឌ្ឍន៍ក្នុងមូលដ្ឋាន ។

# ឯកសារពិគ្រោះ

## ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

- ព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ២០០១ ប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងឃុំសង្កាត់
- ព្រះរាជក្រមលេខ នស/រកម/១២១៥/០១៥ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់
- អនុក្រឹត្យលេខ ២២ អនក្រ.បក ចុះថ្ងៃទី ២៥ ខែមិនា ឆ្នាំ២០០២ ស្តីពីការផ្ទេរិមជ្ឈការអំណាច តួនាទី និងភារកិច្ចទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់
- ប្រកាសលេខ ១៣២៩ ប្រ.ក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០១ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០១ ស្តីពីតួនាទី-ភារកិច្ច-និងសិទ្ធិរបស់ស្មៀនឃុំ-សង្កាត់
- សេចក្តីណែនាំលេខ០០៤ សណន ចុះថ្ងៃទី ១៧ ខែមិនា ឆ្នាំ២០០៦ ស្តីពីបែបបទនីតិវិធីនៃការជ្រើសរើសមេភូមិ ការចូលតំណែង ការផ្លាស់ប្តូរមេភូមិ ការតែងតាំង ជំនួយការមេភូមិ និង តួនាទី ភារកិច្ចរបៀបរបបធ្វើការងាររបស់មេភូមិ

## ឯកសារផ្សេងៗ

- រាជរដ្ឋាភិបាលកម្ពុជា, គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ស្តីពី*កម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ ២០១៣-២០១៨*
- រាជរដ្ឋាភិបាលកម្ពុជា, គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ស្តីពី*កម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ ២០១៩-២០២៣*
- ទីស្តីការគណៈរដ្ឋមន្ត្រី, ២០២០ របាយការណ៍សង្ខេប *ស្តីពីសមិទ្ធផលសំខាន់ៗពេញ១នៃការអនុវត្តយុទ្ធសាស្ត្រចតុកោណទី៤ របស់រាជរដ្ឋាភិបាលកម្ពុជានីតិកាលទី៦នៃរដ្ឋសភាឆ្នាំ ២០១៨-២០១៩*
- *រាជរដ្ឋាភិបាលកម្ពុជា-ក្រសួងមុខងារសាធារណៈ ស្តីពីគោលនយោបាយស្តីពីការផ្តល់សេវាសាធារណៈ*
- ក្រសួងមហាផ្ទៃ, ២០១៧ *សៀវភៅការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការ*
- ក្រសួងមហាផ្ទៃ, ២០១៨ *សៀវភៅប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ-កំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ*
- ក្រសួងមហាផ្ទៃ, ២០០៥ *សៀវភៅណែនាំស្តីពីកិច្ចការរដ្ឋបាលឃុំសង្កាត់*
- ក្រុមការងារអន្តរក្រសួង, ២០០៧ *សៀវភៅណែនាំស្តីពីការកសាងផែនការអភិវឌ្ឍន៍ឃុំសង្កាត់និងកម្មវិធីវិនិយោគឃុំសង្កាត់*

- របាយការណ៍ស្តីពីការសិក្សាវាយតម្លៃអាណត្តិទី២នៃកំណែទម្រង់វិមជ្ឈការនៅកម្ពុជា

**សៀវភៅ**


- សម្តេចជួន ណាត-*វចនានុក្រមខ្មែរភាគ ១&២* បោះពុម្ពលើកទី៥ ឆ្នាំ ១៩៦៨
- ហៀង សៀង-*សៀវភៅនីតិរដ្ឋបាលទូទៅ* បោះពុម្ពលើកទី៤ រោងពុម្ពស៊ី ហេង ឆ្នាំ២០១៧
- សំ សារ៉ាក់-*សៀវភៅនីតិរដ្ឋបាល និងការងារលិខិតរដ្ឋបាល*
- ង៉ីយ ធឿន-*រដ្ឋបាលសាធារណៈ* ឆ្នាំ ២០២០
- ឡាញ់ ដា-*សៀវភៅសិក្សាសង្ខេបអំពីនីតិថវិកា និងពន្ធដារ និងនីតិមុខងារសាធារណៈ* ឆ្នាំ ២០១៦

# ឧបសម្ព័ន្ធ

នស / រកម / ០៣០១ / ០៥

# ព្រះរាជក្រម

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី០៨ ខែ មីនា ឆ្នាំ ១៩៩៩ដែលប្រកាសឱ្យប្រើជាផ្លូវការនូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤នៃរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម /០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំ ពីសម្តេចនាយករដ្ឋមន្ត្រី និង ពីសហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ។

## ប្រកាសអោយប្រើ

ច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គលើកទី ៥ នីតិកាលទី ២ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមលើទំរង់ និង គតិនៃច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី០១ខែ កុម្ភៈ ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គលើក ទី៤ នីតិកាលទី ១ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញ ប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ តាមសេចក្តីសម្រេចលេខ ០៤១/ ០០៣ / ២០០១ កបធ.ច ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖ ៕

# ច្បាប់

# ស្តីពី

# ការគ្រប់គ្រងរដ្ឋបាល

# ឃុំ សង្កាត់

# ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលដៅកំណត់ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជាតាមនយោបាយវិមជ្ឈការ ។

**មាត្រា ២.-**

ឃុំ សង្កាត់ជានីតិបុគ្គល ។

**មាត្រា ៣.-**

ប្រព័ន្ធនៃអភិបាលកិច្ចមូលដ្ឋានត្រូវអនុវត្តនៅថ្នាក់ឃុំ សង្កាត់ ។

**មាត្រា ៤.-**

អំណាចដឹកនាំនិងគ្រប់គ្រងឃុំ សង្កាត់បានមកដោយការបោះឆ្នោតជាទូទៅជាសកល ដោយសេរី ត្រឹមត្រូវនិងយុត្តិធម៌ ដោយស្មើភាព ដោយចំពោះ ដោយសម្ងាត់ក្នុងក្របខ័ណ្ឌនៃឃុំ សង្កាត់នីមួយៗ ។

**មាត្រា ៥.-**

ឃុំ សង្កាត់គ្រប់គ្រងកិច្ចការមូលដ្ឋានក្នុងដែនដីរបស់ខ្លួនដោយផ្អែកទៅតាមរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាសនិងលិខិតបទដ្ឋានពាក់ព័ន្ធ ។

អំណាចបញ្ញត្តិ អំណាចប្រតិបត្តិក្នុងការគ្រប់គ្រងមូលដ្ឋានត្រូវផ្តល់ឱ្យឃុំ សង្កាត់ ហើយអំណាចនេះត្រូវអនុវត្តស្របទៅតាមរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាសនិងលិខិតបទដ្ឋានពាក់ព័ន្ធ ។

**មាត្រា ៦.-**

ការបង្កើត ការលុបចោល ការកែប្រែព្រំប្រទល់និងការប្តូរឈ្មោះរបស់ឃុំ សង្កាត់ ក្នុងករណីមិនប៉ះពាល់ដល់ព្រំប្រទល់របស់ខេត្ត ក្រុងពាក់ព័ន្ធ ត្រូវសម្រេចដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

ក្នុងករណីដែលមានការប៉ះពាល់ដល់ព្រំប្រទល់របស់ខេត្ត ក្រុងពាក់ព័ន្ធ ការបង្កើត ការលុបចោល ការកែប្រែព្រំប្រទល់និងការប្តូរឈ្មោះរបស់ឃុំ សង្កាត់ ត្រូវ៖ / ...

សំរេចដោយព្រះរាជក្រឹត្យតាមសំណើរបស់នាយករដ្ឋមន្ត្រី ផ្អែកលើសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៧.-**

កាលបើមានផលវិបាកណាមួយកើតឡើង ក្រោយពេលដែលឃុំ សង្កាត់ ត្រូវបានបង្កើត លុបចោលឬកែសម្រួល រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញប្រកាសដើម្បីដោះស្រាយផលវិបាកនោះស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន ។

**មាត្រា ៨.-**

ឃុំ សង្កាត់ណាដែលមិនអាចដំណើរការរៀបចំបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់បានដោយករណីប្រធានសក្តិ រាជរដ្ឋាភិបាលត្រូវធ្វើសេចក្តីរាយការណ៍ជូនរដ្ឋសភា។

បន្ទាប់ពីបានរាយការណ៍ជូនរដ្ឋសភារួចហើយ រាជរដ្ឋាភិបាលត្រូវចាត់ឱ្យក្រសួងមហាផ្ទៃរៀបចំគ្រប់គ្រងឃុំ សង្កាត់ទាំងនោះជាបណ្តោះអាសន្ន ហើយការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ទាំងនោះនឹងត្រូវដំណើរការ នៅពេលស្ថានការណ៍ឃុំ សង្កាត់ទាំងនេះមានប្រក្រតីភាពឡើងវិញ ។

## ជំពូកទី ២
## ក្រុមប្រឹក្សាឃុំ សង្កាត់

**មាត្រា ៩.-**

ឃុំ សង្កាត់នីមួយៗត្រូវមានក្រុមប្រឹក្សាមួយហៅថាក្រុមប្រឹក្សាឃុំ សង្កាត់ ។

ក្រុមប្រឹក្សាឃុំ សង្កាត់ជាអង្គការតំណាងប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់ខ្លួន និងមានបេសកកម្មបំរើផលប្រយោជន៍ទូទៅក្នុងឃុំ សង្កាត់របស់ខ្លួន ។

**មាត្រា ១០.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវជ្រើសរើសឡើងតាមការបោះឆ្នោត ដោយប្រជាពលរដ្ឋនៃឃុំ សង្កាត់របស់ខ្លួនស្របទៅតាមនីតិវិធីដែលកំណត់ដោយច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។៚

**មាត្រា ១១.-**

ក្រុមប្រឹក្សាឃុំ សង្កាត់មានអាណត្តិ ៥ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលដែលមានក្រុមប្រឹក្សាឃុំ សង្កាត់ថ្មីចូលកាន់តំណែង ។

ក្នុងតំណាក់កាលអន្តរកាលនេះ ក្រុមប្រឹក្សាឃុំ សង្កាត់ដែលផុតអាណត្តិមានភារកិច្ចសំរួលកិច្ចការប្រចាំថ្ងៃតែប៉ុណ្ណោះ ។

**មាត្រា ១២.-**

ក្រុមប្រឹក្សាឃុំ សង្កាត់មានសមាជិកចំនួនពី ៥ ទៅ ១១រូប ផ្អែកតាមប្រជា-សាស្ត្រនិងភូមិសាស្ត្ររបស់ខ្លួន ។

ចំនួនជាក់ស្តែងនៃសមាជិកក្រុមប្រឹក្សាតាមឃុំ សង្កាត់នីមួយៗត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

ចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានកំណត់រួចហើយ អាចធ្វើការផ្លាស់ប្តូរបានដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អាស្រ័យដោយការផ្លាស់ប្តូរនៃប្រជាសាស្ត្រនិងភូមិសាស្ត្រ ។

សមាជិកបន្ថែមនៃក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវជ្រើសរើសតាមនីតិវិធីដូចសមា-ជិកដទៃទៀតដែរ ។

**មាត្រា ១៣.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវមានប្រធានម្នាក់ហៅថាប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ។

ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់មានភារកិច្ច :

- ធ្វើជាអធិបតីក្នុងសម័យប្រជុំនានារបស់ក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន
- ធានាឱ្យមានកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ យ៉ាងតិចឱ្យបានមួយដងក្នុងមួយខែ
- ធានាឱ្យសម័យប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួនដំណើរការបានត្រឹមត្រូវទៅតាមវិធាននិងបទបញ្ជាដូចបានចែងក្នុងបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាឃុំ សង្កាត់និងបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា២៣ នៃច្បាប់នេះ
- រក្សារបៀបរៀបរយនិងសណ្តាប់ធ្នាប់ក្នុងពេលប្រជុំ ។ល។

**មាត្រា ១៤.-**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានសិទ្ធិនិងមានបំណងឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបំពេញល័ក្ខខ័ណ្ឌសំខាន់ៗដូចខាងក្រោម :

- មានសញ្ជាតិខ្មែរពីកំណើត
- ចេះអាននិងសរសេរអក្សរខ្មែរ
- បានចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតក្នុងឃុំ សង្កាត់ដែលខ្លួនមានបំណងឈរឈ្មោះ
- មានអាយុយ៉ាងតិច ២៥ឆ្នាំ គិតមកទល់ថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- មានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមល័ក្ខខ័ណ្ឌដែលកំណត់ដោយច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។

**មាត្រា ១៥.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានបោះឆ្នោតជ្រើសរើសឡើងទៅតាមប្រព័ន្ធសមាមាត្រ ។

**មាត្រា ១៦.-**

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបាត់បង់សមាជិកភាពរបស់ខ្លួនទៅតាមករណីណាមួយក្នុងចំណោមករណីដូចខាងក្រោម :

- សាមីខ្លួនទទួលមរណភាព
- សាមីខ្លួនបាត់បង់សម្បទាវិជ្ជាជីវៈដោយមានលិខិតបញ្ជាក់ពីក្រសួងស្ថាប័នមានសមត្ថកិច្ច
- សាមីខ្លួនសុំលាលែងជាលាយលក្ខណ៍អក្សរពីសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់
- សាមីខ្លួនត្រូវតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬមជ្ឈិមណាមួយ
- សមាជិកត្រូវបានបណ្តេញចេញដោយប្រព្រឹត្តផ្ទុយនឹងបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាឃុំ សង្កាត់ តាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា ៨៤នៃច្បាប់នេះ ៸៸.

- ក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូលត្រូវរំលាយ

- សាមីខ្លួនបាត់បង់សមាជិកភាពពីគណបក្សនយោបាយរបស់ខ្លួន ។

កាលបើសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ណាមួយត្រូវបាត់បង់សមាជិកភាព ត្រូវជ្រើសរើសបេក្ខជនដែលមានឈ្មោះបន្ទាប់តាមលេខរៀងក្នុងបញ្ជីបេក្ខជនជាមួយមកជំនួសដោយមិនបាច់បោះឆ្នោតឡើងវិញឡើយ ។

**មាត្រា ១៧.-**

ត្រូវរៀបចំធ្វើការបោះឆ្នោតឡើងវិញក្នុងរយៈពេល ១២០ថ្ងៃយ៉ាងយូរ ដើម្បីធ្វើការជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងករណីណាមួយដូចខាងក្រោម :

- ឃុំ សង្កាត់ដែលបង្កើតថ្មីតាមល័ក្ខខ័ណ្ឌដែលបានចែងក្នុងមាត្រា ៦ នៃច្បាប់នេះ

- ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវរំលាយចោលតាមល័ក្ខខ័ណ្ឌដែលបានចែងក្នុងមាត្រា ៥៧ និងមាត្រា ៥៨ នៃច្បាប់នេះ ។

ការបោះឆ្នោតឡើងវិញដូចមានចែងខាងលើនេះត្រូវបាត់ចែងធ្វើឡើង អនុលោមទៅតាមបែបបទនិងនីតិវិធីដែលបានចែងក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។

ក្រុមប្រឹក្សាឃុំ សង្កាត់ដែលកើតឡើងដោយការបោះឆ្នោតឡើងវិញខាងលើនេះមានអាណត្តិស្មើនឹងអាណត្តិដែលនៅសល់របស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

ការបោះឆ្នោតឡើងវិញមិនត្រូវអនុញ្ញាតឱ្យធ្វើឡើយ ប្រសិនបើអាណត្តិដែលនៅសល់របស់ក្រុមប្រឹក្សាឃុំ សង្កាត់ មានរយៈពេលមិនលើសពី ១៨០ថ្ងៃ ។

ក្នុងរយៈពេលនេះ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវតែងតាំងសមាសភាពនិងកំណត់អំពីសមត្ថកិច្ច របៀបរបបដឹកនាំគ្រប់គ្រងឃុំ សង្កាត់នោះ រហូតដល់មានការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នាអាណត្តិបន្ទាប់ ។

**មាត្រា ១៨.-**

ការកែប្រែព្រំប្រទល់របស់ឃុំ សង្កាត់ណាមួយអាចប្រព្រឹត្តបានតែក្នុងករណីដែលការកែប្រែនោះ កុំបណ្តាលឱ្យផ្លាស់ប្តូរដល់ចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានជាប់ឆ្នោត ។ល។

ការបង្កើតឃុំ សង្កាត់ថ្មីណាមួយអាចប្រព្រឹត្តបានតែក្នុងករណីដែលការបង្កើតនោះពុំបណ្តាលឱ្យមានផ្លាស់ប្តូរដល់ចំនួនសមាជិកក្រុមប្រឹក្សានៃឃុំ សង្កាត់ដែលពាក់ព័ន្ធ ។

ក្នុងករណីឃុំ សង្កាត់ដែលត្រូវបង្កើតថ្មី ដែលត្រូវលុបចោល ដែលត្រូវកែប្រែព្រំប្រទល់ ហើយបណ្តាលឱ្យមានការផ្លាស់ប្តូរដល់ចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានជាប់ឆ្នោត ការបង្កើត ការលុបចោល ការកែប្រែព្រំប្រទល់ ត្រូវចូលជាធរមានសំរាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ នាអាណត្តិបន្ទាប់ ។

**មាត្រា ១៩.-**

ក្នុងរយៈពេល ១៥ថ្ងៃ ក្រោយពីការប្រកាសលទ្ធផលជាផ្លូវការនៃការបោះឆ្នោត ត្រូវចាត់ឱ្យមានការប្រជុំជាលើកដំបូងនៃក្រុមប្រឹក្សាឃុំ សង្កាត់ ក្រោមអធិបតីភាពមន្ត្រីម្នាក់ដែលចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីប្រកាសសុពលភាពសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់និងប្រកាសឈ្មោះប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ ជំទប់និងចៅសង្កាត់រង ។

**មាត្រា ២០.-**

មុនចាប់ផ្តើមការងារ ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗត្រូវរៀបចំនិងអនុម័តបទបញ្ជាផ្ទៃក្នុងដើម្បីកំណត់នូវវិធានទាំងឡាយសំរាប់អង្គប្រជុំនិងរបៀបរបបធ្វើការងាររបស់ខ្លួន ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញសេចក្តីណែនាំនិតិគោលការណ៍ខាងទាស់រាប់ជាមូលដ្ឋានដល់ការរៀបចំបទបញ្ជាផ្ទៃក្នុងខាងលើនេះ ។

**មាត្រា ២១.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើការប្រជុំយ៉ាងតិចណាស់ចំនួនមួយដងក្នុងមួយខែ ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវប្រជុំក្នុងសាលាឃុំ ឬសាលាសង្កាត់របស់ខ្លួន ឬក្នុងករណីចាំបាច់អធិបតីនៃអង្គប្រជុំអាចជ្រើសយកទីកន្លែងណាមួយក្នុងឃុំ សង្កាត់របស់ខ្លួនដើម្បីប្រជុំ ។ល។

**មាត្រា ២២.-**

ការប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ នឹងយកជាការបាន លុះត្រាតែមានចំនួនលើស ពីពាក់កណ្តាលនៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូលចូលរួម ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើការបោះឆ្នោតអនុម័តដោយសម្លេងភាគច្រើនដាច់ ខាតនៃសមាជិកក្រុមប្រឹក្សាទាំងមូល ដើម្បីសំរេចបញ្ហាណាមួយដូចខាងក្រោម :

- អនុម័តលើគំរោងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់
- អនុម័តលើគំរោងថវិកាឃុំ សង្កាត់
- កំណត់តម្លៃសារពើពន្ធមូលដ្ឋាន មិនមែនសារពើពន្ធមូលដ្ឋាននិង កំរៃសេវាផ្សេងៗ
- អនុម័តបទបញ្ជាផ្ទៃក្នុងនិងដីកាឃុំ សង្កាត់
- កិច្ចការផ្សេងៗទៀតដែលកំណត់ដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

ក្នុងពេលអនុម័ត ប្រសិនបើមានសំឡេងឆ្នោតស្មើគ្នា សម្លេងរបស់អធិបតីនៃ អង្គប្រជុំមានឧត្តមានុភាព ។

**មាត្រា ២៣.-**

ការប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវធ្វើជាសាធារណៈនិងមានលក្ខណៈប្រជា- ធិបតេយ្យ ។

ក្រុមប្រឹក្សាឃុំ សង្កាត់អាចប្រជុំជាសម្ងាត់បាន ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញសេចក្តីណែនាំអំពីរបៀបរបបប្រជុំខាងលើ នេះ ។

**មាត្រា ២៤.-**

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ មានសេរីភាពក្នុងការបញ្ចេញមតិក្នុងអង្គប្រជុំ ក្រុមប្រឹក្សាឃុំ សង្កាត់ ។

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់រូបណាក៏ដោយ មិនអាចត្រូវបានចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួនដោយហេតុពីបានសំដែងយោបល់ ឬបញ្ចេញមតិក្នុងអង្គប្រជុំក្រុម ប្រឹក្សាឃុំ សង្កាត់បានឡើយ ។ល។

## ជំពូកទី ៣
## ទេនាសម្ព័ន្ធរដ្ឋបាលឃុំ សង្កាត់

**មាត្រា ២៥.-**

រដ្ឋបាលឃុំ សង្កាត់ត្រូវដឹកនាំគ្រប់គ្រងដោយក្រុមប្រឹក្សាឃុំ សង្កាត់ ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវមានប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ។

ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ជាមេឃុំ ចៅសង្កាត់ ។

**មាត្រា ២៦.-**

មេឃុំ ចៅសង្កាត់មានអ្នកជំនួយការដូចខាងក្រោម :

ចំពោះមេឃុំ អ្នកជំនួយការមានពីររូប :

-ជំទប់ទី ១ មួយរូប

-ជំទប់ទី ២ មួយរូប ។

ចំពោះចៅសង្កាត់ អ្នកជំនួយការមានពីររូប :

-ចៅសង្កាត់រងទី ១ មួយរូប

-ចៅសង្កាត់រងទី ២ មួយរូប ។

**មាត្រា ២៧.-**

មេឃុំ ចៅសង្កាត់មានសិទ្ធិចាត់តាំងគណៈកម្មាធិការនានាដើម្បីផ្តល់យោបល់ និងជួយកិច្ចការនានាតាមការចាំបាច់ ។

គណៈកម្មាធិការខាងលើនេះអាចយកសមាជិកណាម្នាក់ក្នុងក្រុមប្រឹក្សាឃុំ សង្កាត់ឱ្យធ្វើជាប្រធានក៏បាន ឬអាចយកប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតណាម្នាក់ក្នុងឃុំ សង្កាត់របស់ខ្លួន ក្រៅពីសមាជិកក្រុមប្រឹក្សាឱ្យធ្វើជាប្រធានក៏បាន ។

**មាត្រា ២៨.-**

ឃុំ សង្កាត់ត្រូវមានបុគ្គលិកក្របខ័ណ្ឌរដ្ឋបាលនៃក្រសួងមហាផ្ទៃមួយរូបធ្វើជាស្មៀនឃុំ សង្កាត់ ។

ស្មៀនឃុំ សង្កាត់តែងតាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃដែលមានភារកិច្ចជួយកិច្ចការឃុំ សង្កាត់ និងធានានិរន្តរភាពកិច្ចការរដ្ឋបាលក្នុងឃុំ សង្កាត់ ។ល។

ស្មៀនឃុំ សង្កាត់ត្រូវផ្លាស់ប្តូរក្នុងករណីមានសំណើរបស់មេឃុំ ចៅសង្កាត់ អនុលោមតាមការសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

**មាត្រា ២៩.-**

ឃុំ សង្កាត់អាចជ្រើសរើសបុគ្គលិកក្រៅក្របខ័ណ្ឌរដ្ឋដើម្បីជួយកិច្ចការរបស់ខ្លួន តាមសេចក្តីត្រូវការនិងការចាំបាច់នៃការងារនិងតាមសេចក្តីសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងអាណត្តិ ហើយអាចបន្តការងារតាមការសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិបន្ទាប់ ។

**មាត្រា ៣០.-**

ក្នុងគោលដៅលើកកំពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗត្រូវរៀបចំជ្រើសរើសឱ្យមានមេភូមិម្នាក់ សំរាប់ភូមិនីមួយៗ ចំណុះឃុំ សង្កាត់របស់ខ្លួន ។

មេភូមិត្រូវរៀបចំចាត់តាំងឱ្យមានអនុប្រធានមួយរូបនិងសមាជិកមួយរូបជាជំនួយការ ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញសេចក្តីណែនាំអំពីបែបបទនីតិវិធីនៃការជ្រើសរើសមេភូមិ ការចូលកាន់តំណែង ការផ្លាស់ប្តូរមេភូមិនិងការតែងតាំងជំនួយការមេភូមិ ។

**មាត្រា ៣១.-**

មេភូមិមានភារកិច្ច :

- អនុវត្តនូវភារកិច្ចដែលក្រុមប្រឹក្សាឃុំ សង្កាត់ ឬមេឃុំ ចៅសង្កាត់ប្រគល់ឱ្យ ដើម្បីធានាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមក្នុងភូមិ
- ផ្តល់យោបល់ដល់ក្រុមប្រឹក្សាឃុំ សង្កាត់អំពីបញ្ហានានាដែលទាក់ទងដល់ផលប្រយោជន៍ក្នុងភូមិរបស់ខ្លួន
- ស្នើសុំយោបល់ទៅក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ដើម្បីចាត់ចែងនិងសម្របសម្រួលកិច្ចការនៅក្នុងភូមិរបស់ខ្លួន ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញសេចក្តីណែនាំបន្ថែមអំពីរបៀបរបបធ្វើការងារនិងភារកិច្ចរបស់ភូមិឱ្យបានសមស្រប ។៚

**មាត្រា ៣២.-**

ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់ត្រូវជ្រើសរើសចេញពីបេក្ខជនលេខរៀងលើគេបង្អស់នៃបញ្ជីបេក្ខជនដែលបានទទួលសម្លេងឆ្នោតច្រើនជាងគេបង្អស់ ។

ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់មានអាណត្តិស្មើនឹងអាណត្តិរបស់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ។

**មាត្រា ៣៣.-**

ជំទប់ទី ១ ចៅសង្កាត់រងទី ១ ត្រូវជ្រើសរើសចេញពីបេក្ខជនដែលមានឈ្មោះលេខរៀងលើគេនៃបញ្ជីបេក្ខជនដែលបានទទួលសម្លេងឆ្នោតលំដាប់ទី ២ ។

ជំទប់ទី ២ ចៅសង្កាត់រងទី ២ ត្រូវជ្រើសរើសចេញពីបេក្ខជនដែលមានឈ្មោះលេខរៀងលើគេនៃបញ្ជីបេក្ខជនដែលបានទទួលសម្លេងឆ្នោតលំដាប់ទី ៣ ។

**មាត្រា ៣៤.-**

ក្នុងករណីដែលលទ្ធផលជាផ្លូវការនៃការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ណាបានផ្តល់សម្លេងគាំទ្រដល់បញ្ជីបេក្ខជនតែមួយដែលមានលក្ខណៈសម្បត្តិទទួលបានអាសនៈទាំងអស់ក្នុងក្រុមប្រឹក្សា ត្រូវជ្រើសរើសសមាជិកក្រុមប្រឹក្សាពីក្នុងបញ្ជីតែមួយនោះឱ្យទទួលតំណែងជាមេឃុំ ឬចៅសង្កាត់ ជំទប់ទី ១ ឬចៅសង្កាត់រងទី ១ ជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ។

**មាត្រា ៣៥.-**

ក្នុងករណីដែលលទ្ធផលជាផ្លូវការនៃការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ណាបានផ្តល់សម្លេងគាំទ្រដល់បញ្ជីបេក្ខជនតែពីរដែលមានលក្ខណៈសម្បត្តិទទួលបានអាសនៈក្នុងក្រុមប្រឹក្សា ត្រូវជ្រើសរើសសមាជិកក្រុមប្រឹក្សាជាបេក្ខជន ដែលមានឈ្មោះលេខរៀងបន្ទាប់ពីបេក្ខជនដែលមានឈ្មោះលេខរៀងលំដាប់លើគេបង្អស់នៃបញ្ជីដែលបានទទួលសម្លេងឆ្នោតគាំទ្រលំដាប់ទីមួយ ឱ្យទទួលតំណែងជាជំទប់ទី ១ ឬចៅសង្កាត់រងទី ១ និងជ្រើសរើសយកសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ជាបេក្ខជនដែលមានឈ្មោះលេខរៀងលើគេបង្អស់ នៃបញ្ជីដែលបានទទួលសម្លេងគាំទ្រលំដាប់ទី ២ ឱ្យទទួលតំណែងជាជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ។ល។

**មាត្រា ៣៦.-**

តំណែងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់ត្រូវបាត់បង់ក្នុងករណីសាមីខ្លួនបាត់បង់សមាជិកភាពក្រុមប្រឹក្សាឃុំ សង្កាត់តាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងវាក្យ-ខ័ណ្ឌទី ១ មាត្រា ១៦នៃច្បាប់នេះ ។

**មាត្រា ៣៧.-**

មុខតំណែងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ មុខតំណែងមេឃុំ ចៅសង្កាត់និងមុខតំណែងជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ កាលបើមុខតំណែងណាមួយត្រូវបាត់បង់ មុខតំណែងទាំងអស់ខាងលើរបស់ជននោះក៏ត្រូវបានបាត់បង់ព្រមពេលជាមួយគ្នាដែរ ។

ក្នុងករណីខាងលើនេះ ត្រូវជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលមានឈ្មោះតាមលេខរៀងបន្ទាប់នៅក្នុងបញ្ជីរួមជាមួយអតីតប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់ ដែលបានបាត់បង់ពីមុខតំណែងនោះ ឱ្យទទួលបន្តតំណែងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់និងត្រូវជ្រើសរើសសមាជិកក្រុមប្រឹក្សាថ្មី ជំនួសកន្លែងដែលទំនេរតាមល័ក្ខខ័ណ្ឌដែលបានចែងក្នុងវាក្យខ័ណ្ឌទី ២ មាត្រា ១៦នៃច្បាប់នេះ ។

ក្នុងករណីដែលបញ្ជីបេក្ខជនត្រូវកាន់កាប់តំណែងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់អស់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ចេញពីក្នុងបញ្ជីបេក្ខជនជាមួយ ផ្អែកតាមល័ក្ខខ័ណ្ឌដែលបានចែងក្នុងវាក្យ-ខ័ណ្ឌទី ២ មាត្រា ១៦ នៃច្បាប់នេះនិងបាត់ឱ្យសមាជិកក្រុមប្រឹក្សារូបនេះទទួលបន្តតំណែងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់ជំនួសប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់ដែលបានបាត់បង់ពីមុខតំណែង ។

ផ្អែកតាមល័ក្ខខ័ណ្ឌខាងលើនេះ ការបាត់បង់ពីមុខតំណែងនិងការទទួលតំណែងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់ត្រូវធ្វើដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃក្នុងរយៈពេលយ៉ាងយូរ ១៥ថ្ងៃ ។

**មាត្រា ៣៨.-**

តំណែងជាជំទប់ទី ១ ឬចៅសង្កាត់រងទី ១ តំណែងជាជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ត្រូវបាត់បង់ពីមុខតំណែង ក្នុងករណីដែលសាមីខ្លួនបាត់បង់សមាជិកភាពក្រុមប្រឹក្សា ឃុំ សង្កាត់តាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងវាក្យខ័ណ្ឌទី ១ មាត្រា ១៦នៃច្បាប់នេះ ។ល។

ក្នុងករណីតំណែងជាជំទប់ទី ១ ឬចៅសង្កាត់រងទី ១ តំណែងជាជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ត្រូវបានបាត់បង់ មុនតំណែងជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់របស់ជននោះ ក៏ត្រូវបានបាត់បង់ព្រមពេលជាមួយគ្នាដែរ ។

ក្នុងករណីខាងលើនេះ ត្រូវជ្រើសរើសយកសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ជាបេក្ខជនដែលមានឈ្មោះតាមលេខរៀងបន្ទាប់នៃបញ្ជីបេក្ខជនរួមជាមួយជំទប់ទី ១ ឬចៅសង្កាត់រងទី ១ ជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ឱ្យទទួលតំណែងជំនួសជំទប់ ឬចៅសង្កាត់រងដែលបានបាត់បង់ពីមុខតំណែងនិងត្រូវជ្រើសរើសសមាជិកក្រុមប្រឹក្សាថ្មីជំនួសកន្លែងដែលទំនេរ តាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងវាក្យខ័ណ្ឌទី ២ មាត្រា ១៦នៃច្បាប់នេះ ។

ក្នុងករណីបញ្ជីបេក្ខជនដែលត្រូវកាន់កាប់តំណែងជាជំទប់ទី ១ ឬចៅសង្កាត់រងទី ១ ជំទប់ទី ២ ឬចៅសង្កាត់រងទី ២ អស់សមាជិកក្នុងក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវជ្រើសរើសបេក្ខជនពីក្នុងបញ្ជីនោះបញ្ចូលជាសមាជិកក្នុងក្រុមប្រឹក្សាឃុំ សង្កាត់ ទៅតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងវាក្យខ័ណ្ឌទី ២ មាត្រា ១៦នៃច្បាប់នេះ និងប្រគល់ឱ្យសមាជិកក្រុមប្រឹក្សារូបនោះទទួលតំណែងជាជំទប់ទី ១ ឬចៅសង្កាត់រងទី ១ ជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ជំនួសតំណែងជំទប់ទី ១ ឬចៅសង្កាត់រងទី ១ ជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ដែលបានបាត់បង់ពីមុខតំណែង ។

ផ្អែកតាមល័ក្ខខ័ណ្ឌខាងលើនេះនិងល័ក្ខខ័ណ្ឌដែលបានចែងក្នុងមាត្រា ៣៣ នៃច្បាប់នេះ ការបាត់បង់មុខតំណែងនិងការទទួលតំណែងជាជំទប់ទី ១ ឬចៅសង្កាត់រងទី ១ ជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ត្រូវធ្វើដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃក្នុងរយៈពេលយ៉ាងយូរ ១៤ថ្ងៃ ។

**មាត្រា ៣៩.-**

មេឃុំ ចៅសង្កាត់បំពេញតួនាទីភារកិច្ចដូចខាងក្រោម :

- អនុវត្តសេចក្ដីសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់
- អនុវត្តនូវបទបញ្ញត្តិនិងគោលការណ៍នានាដែលបានទទួលពីក្រុមប្រឹក្សាឃុំ សង្កាត់
- ធ្វើសេចក្ដីរាយការណ៍អំពីសកម្មភាពការងារជូនក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួនយ៉ាងតិចឱ្យបានមួយដងក្នុងមួយខែ
- ផ្ដល់យោបល់ផ្សេងៗនិងជួយដល់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការរៀបចំផែនការហិរញ្ញវត្ថុនិងក្នុងការចាត់ចែងអនុវត្តនូវតួនាទី មុខងារ សិទ្ធិអំណាចរបស់ក្រុម

ស.ក.

ប្រឹក្សាឃុំ សង្កាត់ ព្រមទាំងកិច្ចការផ្សេងទៀតដែលក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួនប្រគល់ឱ្យ ។

**មាត្រា ៤០.-**

ជំទប់ ឬចៅសង្កាត់រងជាជំនួយការរបស់មេឃុំ ចៅសង្កាត់ក្នុងការអនុវត្តភារកិច្ចដែលមេឃុំ ចៅសង្កាត់ប្រគល់ឱ្យនិងជំនួសមេឃុំ ចៅសង្កាត់ទៅតាមឋានានុក្រមនៃជំទប់ ចៅសង្កាត់រង នៅពេលដែលមេឃុំ ចៅសង្កាត់អវត្តមាន ។

ជំទប់ ឬចៅសង្កាត់រង ត្រូវធ្វើការបែងចែកភារកិច្ចដូចខាងក្រោម :

ជំទប់ទី ១ ឬចៅសង្កាត់រងទី ១ ទទួលជួយមេឃុំ ចៅសង្កាត់លើកិច្ចការសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

ជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ទទួលជួយមេឃុំ ចៅសង្កាត់លើកិច្ចការរដ្ឋបាល សង្គមកិច្ច សេវាសាធារណៈនិងសណ្ដាប់ធ្នាប់សាធារណៈ ។

មេឃុំ ចៅសង្កាត់អាចប្រគល់ភារកិច្ចបន្ថែមពីលើភារកិច្ចដែលបានបែងចែកខាងលើនេះដល់ជំទប់ ឬចៅសង្កាត់រងរបស់ខ្លួន ។

## ជំពូកទី ៤

## តួនាទី មុខងារនិងអំណាចនៃរដ្ឋបាលឃុំ សង្កាត់

**មាត្រា ៤១.-**

រដ្ឋបាលឃុំ សង្កាត់មានតួនាទីជំរុញនិងគាំពារអភិបាលកិច្ចល្អ ដោយចាត់ចែងប្រើប្រាស់ធនធាននានាដែលមានប្រកបដោយចីរភាព សំរាប់បំពេញសេចក្ដីត្រូវការជាមូលដ្ឋានក្នុងឃុំ សង្កាត់របស់ខ្លួន បំរើផលប្រយោជន៍រួមរបស់ប្រជាពលរដ្ឋនិងគោរពផលប្រយោជន៍របស់ជាតិស្របតាមនយោបាយទូទៅរបស់រដ្ឋ ។

**មាត្រា ៤២.-**

រដ្ឋបាលឃុំ សង្កាត់មានតួនាទីពីរប្រភេទគឺ :

- តួនាទីបំរើកិច្ចការមូលដ្ឋានសំរាប់បំរើផលប្រយោជន៍ឃុំ សង្កាត់និងប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់ខ្លួន ។

- តួនាទីជាភ្នាក់ងារតំណាងរដ្ឋ ក្រោមការចាត់តាំង ឬការប្រគល់អំណាចរបស់អាជ្ញាធររដ្ឋ ។៚

**មាត្រា ៤៣.-**

ក្នុងតួនាទីបំពីកិច្ចការមូលដ្ឋាន រដ្ឋបាលឃុំ សង្កាត់មានភារកិច្ច :

- ធានាសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ

- រៀបចំចាត់ចែងសេវាសាធារណៈចាំបាច់និងមើលការខុសត្រូវឱ្យកិច្ចការទាំងនោះដំណើរការបានល្អ

- លើកទឹកចិត្តឱ្យមានការបង្កើនផាសុកភាពនិងសុខុមាលភាពរបស់ប្រជាពលរដ្ឋ

- ជំរុញកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ចនិងលើកកំពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ

- ការពារ ថែរក្សាបរិស្ថាន ធនធានធម្មជាតិ វប្បធម៌ បេតិកភណ្ឌជាតិ

- សំរបសំរួលទស្សនៈរបស់ប្រជាពលរដ្ឋដើម្បីឱ្យមានការយោគយល់អធ្យាស្រ័យទៅវិញទៅមក

- បំពេញកិច្ចការជាទូទៅដើម្បីឆ្លើយតបសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ ។

**មាត្រា ៤៤.-**

ក្នុងតួនាទីជាភ្នាក់ងារតំណាងរដ្ឋ រដ្ឋបាលឃុំ សង្កាត់មានភារកិច្ចអនុវត្តទៅតាមច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាសនិងលិខិតបទដ្ឋានពាក់ព័ន្ធ ។

ក្នុងករណីនេះ អាជ្ញាធររដ្ឋអាចធ្វើប្រតិភូកម្មអំណាចដល់ឃុំ សង្កាត់ដោយភ្ជាប់ជាមួយនូវការបង្កើនសមត្ថភាពនិងផ្តត់ផ្គង់មធ្យោបាយ សម្ភារៈ ថវិកា សំរាប់អនុវត្ត ។

ប្រតិភូកម្មខាងលើនេះ ត្រូវផ្តល់ចំពោះតែសមូហភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់តែប៉ុណ្ណោះ ។

**មាត្រា ៤៥.-**

រដ្ឋបាលឃុំ សង្កាត់គ្មានអំណាចសំរេចលើវិស័យទាំងឡាយដូចខាងក្រោម :

- ព្រៃឈើ

- ប្រៃសណីយ៍និងទូរគមនាគមន៍

- ការពារប្រទេស ៣។.

- សន្តិសុខជាតិ
- រូបិយវត្ថុ
- នយោបាយក្រៅប្រទេស
- គោលនយោបាយសារពើពន្ធ
- និងវិស័យផ្សេងទៀតដែលមានចែងក្នុងច្បាប់ លិខិតបទដ្ឋានពាក់ព័ន្ធ។

**មាត្រា ៤៦.-**

តួនាទី មុខងារនិងអំណាចរបស់ឃុំ សង្កាត់ ដូចមានចែងក្នុងមាត្រា ៤២, ៤៣ និងមាត្រា ៤៤នៃច្បាប់នេះ អនុវត្តបានតែក្នុងវង្វង់ដែនដីឃុំ សង្កាត់របស់ខ្លួនតែប៉ុណ្ណោះ ។

ក្នុងករណីមានបញ្ហាកើតឡើងទាក់ទងសមត្ថកិច្ចរវាងឃុំ សង្កាត់ពីរឬច្រើន រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចាត់ការឱ្យមានការសំរុះសំរួលគ្នារវាងរដ្ឋបាលដែលពាក់ព័ន្ធទាំងនោះ ។

**មាត្រា ៤៧.-**

តួនាទី មុខងារនិងអំណាចរបស់រដ្ឋបាលឃុំ សង្កាត់ដូចមានចែងក្នុងមាត្រា ៤២, ៤៣, ៤៤ និងមាត្រា ៤៥នៃច្បាប់នេះ អាចកំណត់លំអិតជាក់ស្តែងបន្ថែមទៀតដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៤៨.-**

ឃុំ សង្កាត់មានអំណាចបញ្ញត្តិនិងអំណាចប្រតិបត្តិ ។

អំណាចបញ្ញត្តិរបស់ឃុំ សង្កាត់ត្រូវធ្វើឡើងតាមរយៈដីកាឃុំ សង្កាត់សំរាប់គ្រប់គ្រងកិច្ចការនានាក្នុងក្របខ័ណ្ឌ តួនាទី មុខងារនិងអំណាចរបស់ខ្លួន ។

ដីកាឃុំ សង្កាត់ត្រូវធ្វើឡើងតាមការសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ហើយត្រូវចុះហត្ថលេខាដោយមេឃុំ ចៅសង្កាត់ ។

រដ្ឋបាលឃុំ សង្កាត់ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈនិងជាបន្ទាន់ក្នុងឃុំ សង្កាត់របស់ខ្លួននូវដីកាដែលបានសំរេចរួចហើយ ។ល។

**មាត្រា ៤៩.-**

ដីកាឃុំ សង្កាត់មានប្រសិទ្ធភាពអនុវត្តតែក្នុងរង្វង់ដែនដីរបស់ខ្លួនប៉ុណ្ណោះ ។

ដីកាឃុំ សង្កាត់មិនត្រូវផ្ទុយនឹងសន្ធិសញ្ញា អនុសញ្ញាអន្តរជាតិ ដែលព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ ស្មារតីរដ្ឋធម្មនុញ្ញ ផ្ទុយនឹងច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានពាក់ព័ន្ធបានឡើយ ។

ដីកាដែលដាក់ចេញដោយរដ្ឋបាលឃុំ សង្កាត់ ហើយផ្ទុយនឹងសន្ធិសញ្ញា អនុសញ្ញាអន្តរជាតិ ដែលព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ ស្មារតីរដ្ឋធម្មនុញ្ញ ផ្ទុយនឹងច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាសនិងលិខិតបទដ្ឋានពាក់ព័ន្ធត្រូវចាត់ទុកជាមោឃៈដាច់ខាត ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវជូនដំណឹងអំពីមោឃភាពនេះជាលាយលក្ខណ៍អក្សរ ដល់ឃុំ សង្កាត់សាមីនិងត្រូវផ្សព្វផ្សាយជាសាធារណៈ ។

**មាត្រា ៥០.-**

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវណែនាំអំពីទំរង់និងបែបបទ ដើម្បីឱ្យឃុំ សង្កាត់រៀបចំដីកាស្របទៅតាមសភាពការណ៍ក្នុងឃុំ សង្កាត់របស់ខ្លួន ។

**មាត្រា ៥១.-**

ក្រុមប្រឹក្សាឃុំ សង្កាត់អាចធ្វើប្រតិភូកម្មអំណាចឱ្យដល់មេឃុំ ចៅសង្កាត់តាមសេចក្ដីណែនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ លើកលែងតែបញ្ហាទាំងឡាយដូចខាងក្រោម :

- ការអនុម័តលើគំរោងថវិកាឃុំ សង្កាត់
- ការកំណត់តម្លៃសារពើពន្ធមូលដ្ឋាន មិនមែនសារពើពន្ធមូលដ្ឋាន និងកំរៃសេវាផ្សេងៗ
- ការបោះឆ្នោតអនុម័តបទបញ្ជាផ្ទៃក្នុងនិងដីកាឃុំ សង្កាត់
- ការអនុម័តលើគំរោងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់
- បញ្ហាដទៃទៀតដែលកំណត់ដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

មេឃុំ ចៅសង្កាត់ដែលត្រូវបានក្រុមប្រឹក្សាឃុំ សង្កាត់ធ្វើប្រតិភូកម្មអំណាចឱ្យពុំអាចផ្ទេរអំណាចនេះបន្តទៅឱ្យបុគ្គលដទៃទៀតបានឡើយ ។ ល៖.

**មាត្រា ៥២.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានធ្វើប្រតិភូកម្មអំណាចឱ្យដល់មេឃុំ ចៅសង្កាត់ នៅតែទទួលខុសត្រូវលើកិច្ចការដែលបានធ្វើប្រតិភូកម្មនោះ ។

ការដកហូតនូវអំណាចដែលបានធ្វើប្រតិភូកម្ម មិនធ្វើឱ្យប៉ះពាល់ដល់សុពលភាពនៃកិច្ចការដែលបានធ្វើរួចហើយនោះទេ ។

## ជំពូកទី ៥
## ការតាមដាន ការត្រួតពិនិត្យនិងការធ្វើអន្តរាគមន៍

**មាត្រា ៥៣.-**

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវកំណត់ពីនីតិវិធីផ្សេងៗសំរាប់ធ្វើការតាមដាននិងត្រួតពិនិត្យអំពីសកម្មភាពទូទៅរបស់ឃុំ សង្កាត់ដើម្បី :

- ពិនិត្យមើលអំពីនីត្យានុកូលភាពនៃការគ្រប់គ្រងការងារ ការប្រើប្រាស់អំណាចនិងការបំពេញតួនាទី ភារកិច្ច របស់ឃុំ សង្កាត់នីមួយៗ
- ពិនិត្យមើលការវិវត្តន៍អំពីសមត្ថភាពរបស់ឃុំ សង្កាត់នានា
- វាយតំលៃប្រមាណអំពីការធ្វើអន្តរាគមន៍និងការជួយឧបត្ថម្ភគាំទ្រចំពោះឃុំ សង្កាត់ដើម្បីពង្រឹងសមត្ថភាពគ្រប់គ្រងការងារ ការប្រើប្រាស់អំណាចនិងការបំពេញតួនាទីភារកិច្ច ។

ក្នុងការតាមដាន ការត្រួតពិនិត្យនិងការធ្វើការអន្តរាគមន៍ចំពោះឃុំ សង្កាត់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អាចវិរលែកអំណាចដល់មន្ត្រីជាតំណាងរាជរដ្ឋាភិបាលតាមថ្នាក់រដ្ឋ-បាលដែនដីខេត្ត ក្រុង ស្រុក ខ័ណ្ឌ ឱ្យជួយកិច្ចការនេះទៅតាមសំណូមពរការងារ ។

**មាត្រា ៥៤.-**

ឃុំ សង្កាត់ណាដែលមិនបានបំពេញភារកិច្ចដែលច្បាប់បានតម្រូវ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវធ្វើអន្តរាគមន៍ដើម្បីឱ្យមានការបំពេញភារកិច្ចដែលច្បាប់បានតម្រូវនោះជាបន្ទាន់ ។ល។

ភារកិច្ចដែលច្បាប់បានតម្រូវ គឺជាភារកិច្ចមួយដែលក្រុមប្រឹក្សាឃុំ សង្កាត់ មានកាតព្វកិច្ចបំពេញតាមល័ក្ខខ័ណ្ឌទាំងឡាយនៃច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស លិខិតបទដ្ឋានពាក់ព័ន្ធ ឬបទបញ្ញាផ្ទៃក្នុងនិងដីកាឃុំ សង្កាត់ ។

**មាត្រា ៥៥.-**

ការតាមដាន ត្រួតពិនិត្យនិងធ្វើអន្តរាគមន៍រួមមានការងារ :

- ស៊ើបអង្កេតនិងវាយតំលៃ
- ធ្វើសេចក្តីណែនាំជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាឃុំ សង្កាត់ ឱ្យបំពេញភារកិច្ចដែលច្បាប់បានតម្រូវ
- ធ្វើជំនួសក្នុងការបន្តបំពេញភារកិច្ចដែលច្បាប់បានតម្រូវ ។

**មាត្រា ៥៦.-**

ការធ្វើអន្តរាគមន៍ដូចមានចែងក្នុងវាក្យខ័ណ្ឌទី ១ មាត្រា ៥៤ នៃច្បាប់នេះត្រូវមានលក្ខណៈសមហេតុផលនិងស្របទៅតាមទំហំនៃកិច្ចការដែលក្រុមប្រឹក្សាឃុំ សង្កាត់ មិនបានបំពេញភារកិច្ចដែលច្បាប់បានតម្រូវ ដោយភ្ជាប់ជាមួយនូវការណែនាំនិងការគាំទ្រសំខាន់ចាំបាច់ ដើម្បីឱ្យក្រុមប្រឹក្សាឃុំ សង្កាត់អាចបំពេញភារកិច្ចដែលច្បាប់បានតម្រូវជាធម្មតា ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានសិទ្ធិចុះកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរជាមួយបុគ្គល ឬអង្គការណាមួយ ឬធ្វើការណែនាំជាលាយលក្ខណ៍អក្សរដល់មន្ត្រីជាតំណាងរាជរដ្ឋាភិបាលតាមថ្នាក់រដ្ឋបាលដែនដីខេត្ត ក្រុង ស្រុក ខ័ណ្ឌឱ្យបំពេញការងារចាំបាច់ដើម្បីធ្វើអន្តរាគមន៍ក្នុងនាមខ្លួនចំពោះកិច្ចការណាមួយ ។

**មាត្រា ៥៧.-**

កាលបើការធ្វើអន្តរាគមន៍មិនទទួលបានលទ្ធផលចំពោះភារកិច្ចដែលច្បាប់បានតម្រូវណាមួយ ឬមួយចំនួនក្នុងអំឡុងពេល ៦ខែ ហើយភារកិច្ចដែលច្បាប់បានតម្រូវជាទូទៅក្រុមប្រឹក្សាឃុំ សង្កាត់ក៏មិនអាចបំពេញបាន រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវសំរេចរំសាយក្រុមប្រឹក្សាឃុំ សង្កាត់ ហើយធ្វើការបោះឆ្នោតឡើងវិញទៅតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងច្បាប់នេះ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។ល។

**មាត្រា ៥៨.-**

ក្នុងករណីក្រុមប្រឹក្សាឃុំ សង្កាត់ណាធ្វើសកម្មភាពផ្ទុយនឹងរដ្ឋធម្មនុញ្ញ ផ្ទុយនឹងនយោបាយរដ្ឋាភិបាល រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវសំរេចរំសាយក្រុមប្រឹក្សាឃុំ សង្កាត់ នោះជាបន្ទាន់ ហើយត្រូវធ្វើការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នោះឡើងវិញ ទៅតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងច្បាប់នេះនិងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។

**មាត្រា ៥៩.-**

ត្រូវបង្កើតឱ្យមានអង្គភាពមួយចំណុះក្រសួងមហាផ្ទៃដើម្បីធ្វើជាសេនាធិការអំពីការងាររដ្ឋបាលមូលដ្ឋាន ។

ការរៀបចំនិងការប្រព្រឹត្តទៅនៃអង្គភាពនេះត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

## ជំពូកទី ៦
## ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់

**មាត្រា ៦០.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវរៀបចំ អនុម័តនិងអនុវត្តនូវផែនការអភិវឌ្ឍន៍ឃុំសង្កាត់ក្នុងគោលបំណងកំណត់នូវទស្សនវិស័យ កម្មវិធីនិងកិច្ចអភិវឌ្ឍន៍ឃុំ សង្កាត់របស់ខ្លួន ។

**មាត្រា ៦១.-**

ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ត្រូវឱ្យស្របទៅនឹងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកិច្ចរបស់ជាតិ ។

**មាត្រា ៦២.-**

ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ត្រូវអនុម័តយល់ព្រមដោយក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងឆ្នាំទី ១ នៃអាណត្តិរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ហើយត្រូវពិនិត្យឡើងវិញដើម្បីផ្តល់ទិន្នន័យថ្មីៗជារៀងរាល់ឆ្នាំ ដោយក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន ។ ៚

**មាត្រា ៦៣.-**

ក្នុងការរៀបចំផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវចាត់វិធានការដូចតទៅ :

- វាយតំលៃអំពីកំរិតអត្ថិភាពនៃការអភិវឌ្ឍន៍និងសកម្មភាពអភិវឌ្ឍន៍នៅក្នុងឃុំ សង្កាត់របស់ខ្លួន

- ប្រមូលផ្តុំសេចក្តីត្រូវការក្នុងឃុំ សង្កាត់និងកំណត់អាទិភាពចំពោះសេចក្តីត្រូវការទាំងនោះ ដោយផ្អែកទៅលើធនធានទាំងឡាយដែលឃុំ សង្កាត់មាននិងធនធានដែលបានទទួល

- រៀបចំកម្មវិធីដែលអាចឆ្លើយតបនឹងសេចក្តីត្រូវការនានា តាមរយៈការផ្តល់សេវានិងការអភិវឌ្ឍន៍ ហើយកម្មវិធីទាំងនេះត្រូវបញ្ចូលក្នុងថវិកាប្រចាំឆ្នាំរបស់ឃុំ សង្កាត់

- ផ្តល់សេវានិងការអភិវឌ្ឍន៍ អនុលោមទៅតាមថវិការបស់ខ្លួន

- ពិនិត្យ តាមដាននិងវាយតំលៃចំពោះលទ្ធផលនៃការអនុវត្តផែនការអភិវឌ្ឍន៍

- ប្រើប្រាស់លទ្ធផលផ្សេងៗ ដើម្បីវាយតំលៃអំពីកំរិតនៃការអភិវឌ្ឍន៍ថ្មីៗក្នុងឃុំ សង្កាត់របស់ខ្លួន

- ធ្វើសេចក្តីរាយការណ៍អំពីលទ្ធផលនៃការអនុវត្តផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ជូនប្រជាពលរដ្ឋរបស់ខ្លួន ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវដឹកនាំការងារឱ្យស្របទៅនឹងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់របស់ខ្លួន ។

**មាត្រា ៦៤.-**

ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ត្រូវរៀបចំជាលាយលក្ខណ៍អក្សរដោយមានផែនទី ស្ថិតិនិងសំណុំឯកសារពាក់ព័ន្ធផ្សេងៗទៀតភ្ជាប់ជាមួយផង ។

ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ក៏ត្រូវកំណត់ផងដែរនូវវិធីសាស្ត្រនិងមធ្យោបាយនានាដើម្បីបង្កលទ្ធភាពឱ្យមានការចូលរួមពីប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់ខ្លួនក្នុងកិច្ចដំណើរការទាំងមូល ។ ស.ភ.

## មាត្រា ៦៥.-

ក្នុងករណីដែលផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ណាមួយធ្វើឡើងមិនស្របតាម លក្ខខណ្ឌដែលបានចែងក្នុងច្បាប់នេះ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវណែនាំឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ កែតម្រូវផែនការរបស់ខ្លួនឱ្យបានសមស្របក្នុងអំឡុងពេលយ៉ាងយូរ ៤៥ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួល ច្បាប់ចម្លងនៃផែនការនោះ ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើការកែសម្រួលផែនការអភិវឌ្ឍន៍ឃុំ សង្កាត់របស់ ខ្លួនឱ្យបានសមស្របតាមការណែនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

## មាត្រា ៦៦.-

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើការតាមដាន ត្រួតពិនិត្យនិងវាយតម្លៃរាល់ការ អនុវត្តផែនការ កម្មវិធី គំរោងនិងការផ្តល់សេវានានាប្រកបដោយតម្លាភាពនិងមានការទទួល ខុសត្រូវខ្ពស់ ។

## មាត្រា ៦៧.-

ក្រុមប្រឹក្សាឃុំ សង្កាត់នៅតែជាអ្នកទទួលខុសត្រូវក្នុងការតាមដាន ការត្រួត ពិនិត្យនិងការវាយតម្លៃចំពោះផែនការ កម្មវិធីនិងគំរោងនានា ទោះជាការងារនោះត្រូវបាន អនុវត្តដោយសមាសភាពណាក៏ដោយដែលខ្លួនបានជ្រើសយក ។

## មាត្រា ៦៨.-

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវណែនាំក្រុមប្រឹក្សាឃុំ សង្កាត់អំពីវិធីផ្សេងៗក្នុងការ អនុវត្តផែនការនិងក្នុងការត្រួតពិនិត្យ វាយតម្លៃចំពោះការប្រើប្រាស់មូលនិធិសំរាប់ផែនការ អភិវឌ្ឍន៍ឃុំ សង្កាត់ ។

## មាត្រា ៦៩.-

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើសេចក្តីរាយការណ៍ប្រចាំឆ្នាំអំពី :

- កិច្ចការជាអាទិភាព គោលដៅសំរាប់ផ្តល់សេវានិងគំរោងផែនការ អភិវឌ្ឍន៍របស់ឃុំ សង្កាត់នាឆ្នាំសារពើពន្ធកន្លងមក
- លទ្ធផលនៃការអនុវត្តចំពោះកិច្ចការជាអាទិភាព គោលដៅសំរាប់ ផ្តល់សេវានិងគំរោងផែនការអភិវឌ្ឍន៍ទាំងនោះរបស់ឃុំ សង្កាត់ ៕ល៕

- វិធានការធ្វើឱ្យបានល្អប្រសើរចំពោះវិស័យនានាដែលមានការខ្វះចន្លោះក្នុងការអនុវត្តកន្លងមក

- កិច្ចការជាអាទិភាព គោលដៅសំរាប់ផ្តល់សេវានិងគំរោងផែនការអភិវឌ្ឍន៍របស់ឃុំ សង្កាត់ក្នុងឆ្នាំសារពើពន្ធបច្ចុប្បន្ន ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវអនុម័តសេចក្តីរាយការណ៍នេះក្នុងអំឡុងពេលយ៉ាងយូរ ៤៥ថ្ងៃ បន្ទាប់ពីបំណាច់ឆ្នាំសារពើពន្ធនីមួយៗ ។

**មាត្រា ៧០.-**

សេចក្តីរាយការណ៍ប្រចាំឆ្នាំដូចមានចែងក្នុងមាត្រា ៦៩នៃច្បាប់នេះ ក្រោយពីបានអនុម័តយល់ព្រមដោយក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវ :

- ចម្លងជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- តម្កល់ទុកជាសាធារណៈ
- ចម្លងចែកជូនអង្គការ សមាគមនិងសាធារណជនសំខាន់ៗដោយគិតត្រឹមថ្លៃដើម ។

**មាត្រា ៧១.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវពិនិត្យពិចារណាទៅលើមតិយោបល់ផ្សេងៗដែលបានផ្តល់ចំពោះសេចក្តីរាយការណ៍ដូចមានចែងក្នុងមាត្រា ៦៩ និងមាត្រា ៧០នៃច្បាប់នេះ ហើយត្រូវទទួលយកនូវមតិយោបល់ល្អៗ ដើម្បីដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ។

**មាត្រា ៧២.-**

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវពិគ្រោះពិភាក្សាជាមួយក្រសួងស្ថាប័នពាក់ព័ន្ធដើម្បីចេញសេចក្តីណែនាំអនុវត្តជាក់ស្តែងនូវបទប្បញ្ញត្តិនានា ដែលបានចែងក្នុងជំពូកទី ៦ នៃច្បាប់នេះ ។

## ជំពូកទី ៧
## ហិរញ្ញវត្ថុឃុំ សង្កាត់

**មាត្រា ៧៣.-**

ឃុំ សង្កាត់មានធនធានហិរញ្ញវត្ថុ ថវិកានិងទ្រព្យសម្បត្តិផ្ទាល់ ។ ៚

**មាត្រា ៧៤.-**

ឃុំ សង្កាត់មានសិទ្ធិទទួលចំណូលផ្ទាល់ដែលបានមកពីចំណូលសារពើពន្ធ ចំណូលមិនមែនសារពើពន្ធនិងកំរៃសេវាផ្សេងៗ ។

ពន្ធខាងលើនេះរាប់បញ្ចូលនូវពន្ធលើដីធ្លី ពន្ធលើអចលនទ្រព្យនិងពន្ធនៃការជួល ។

ក្នុងករណីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុប្រមូលចំណូលផ្ទាល់របស់ឃុំ សង្កាត់ ការប្រមូលចំណូលនេះត្រូវធ្វើក្នុងនាមឃុំ សង្កាត់ ។

ប្រភេទ កំរិតនិងរបៀបរបបនៃការប្រមូលចំណូលសារពើពន្ធ ចំណូលមិនមែនសារពើពន្ធនិងកំរៃសេវាផ្សេងៗ ខាងលើនេះត្រូវកំណត់ដោយច្បាប់ ។

**មាត្រា ៧៥.-**

ឃុំ សង្កាត់មានសិទ្ធិទទួលបាននូវធនធានវិភាជន៍ពីចំណូលរដ្ឋ សំរាប់ថវិការបស់ខ្លួន ។

ធនធានវិភាជន៍នេះរួមមាន:

- ការផ្ទេរទាំងមូលឬមួយផ្នែកនូវប្រាក់ចំណូលសារពើពន្ធនិងចំណូលមិនមែនសារពើពន្ធដ៏ជាក់លាក់របស់រដ្ឋ
- ទាយជ្ជទាននិងធនធានវិភាជន៍ ឧបត្ថម្ភធន ឬអនុប្បទានដែលបានមកពីប្រាក់ចំណូលរដ្ឋ ។

ធនធានវិភាជន៍ខាងលើនេះត្រូវផ្តល់ទៅឱ្យឃុំ សង្កាត់តាមរតនាគារខេត្ត ក្រុង ។

ការរៀបចំនិងនីតិវិធីនៃការផ្ទេរប្រាក់វិភាជន៍ខាងលើនេះត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៧៦.-**

ឃុំ សង្កាត់នីមួយៗ មានសិទ្ធិទទួលបាននូវប្រាក់កំរៃ ចំពោះការអនុវត្តនូវតួនាទីជាភ្នាក់ងារតំណាងរដ្ឋដែលរាជរដ្ឋាភិបាល ឬក្រសួងស្ថាប័នណាមួយនៃរាជរដ្ឋាភិបាលបានប្រគល់ឱ្យអនុវត្ត ។

ប្រាក់កំរៃខាងលើនេះគឺជាប្រាក់បន្ថែមពីលើប្រាក់ចំណូលរបស់ឃុំ សង្កាត់ ឬប្រាក់វិភាជន៍ផ្សេងៗដែលឃុំ សង្កាត់ទទួលបានពីប្រាក់ចំណូលរដ្ឋ ។៚

រាជរដ្ឋាភិបាលឬក្រសួងស្ថាប័នណាមួយនៃរាជរដ្ឋាភិបាលត្រូវផ្តល់កំរៃសមស្របដល់ឃុំ សង្កាត់ ដែលបានអនុវត្តតួនាទីជាភ្នាក់ងារតំណាងរដ្ឋដូចបានចែងខាងលើ ។

ក្នុងករណីដែលការប្រគល់អំណាច មុខងាររបស់រដ្ឋមានលក្ខណៈជាអចិន្ត្រៃយ៍ទៅឱ្យឃុំ សង្កាត់រាជរដ្ឋាភិបាលត្រូវរៀបចំឱ្យមានធនធានហិរញ្ញវត្ថុរយៈពេលយូរអង្វែងសំរាប់ផ្តល់ឱ្យឃុំ សង្កាត់ ។

ការរៀបចំប្រាក់កំរៃខាងលើនេះត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៧៧.–**

រដ្ឋបង្កើតឱ្យមានមូលនិធិឃុំ សង្កាត់ ។

មូលនិធិឃុំ សង្កាត់បង្កើតឡើងក្នុងគោលដៅដើម្បីធ្វើការផ្ទេរនូវប្រាក់ចំណូលពីជាតិនិងប្រាក់ចំណូលផ្សេងៗទៀតទៅឱ្យថវិកាឃុំ សង្កាត់ ។

ការផ្ទេរប្រាក់ចំណូលពីជាតិទៅមូលនិធិខាងលើនេះត្រូវធ្វើឡើងទៅតាមរូបមន្តឬតាមអត្រាជាក់លាក់មួយសំរាប់ថេរៈវេលាយ៉ាងតិច ៣ឆ្នាំ និងមិនលើសពី ៥ឆ្នាំដែលកំណត់ដោយអនុក្រឹត្យ ។

នីតិវិធីអនុវត្តជាក់ស្តែងនៃមាត្រានេះត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៧៨.–**

មូលនិធិឃុំ សង្កាត់បានមកពី :

- ការធ្វើវិភាជន៍នូវចំណែកដ៏ជាក់លាក់នៃប្រាក់ចំណូលរដ្ឋ ពីថវិការដ្ឋប្រចាំឆ្នាំដែលកំណត់ដោយអនុក្រឹត្យ
- អនុប្បទាននិងការខ្ចីពីប្រភពក្នុងប្រទេសនិងក្រៅប្រទេស ។

ការធ្វើវិភាជន៍នូវធនធានប្រចាំឆ្នាំទៅឱ្យឃុំ សង្កាត់តាមមូលនិធិឃុំ សង្កាត់ត្រូវធ្វើឡើងទៅតាមរូបមន្តដែលកំណត់ដោយអនុក្រឹត្យ ។

របៀបរបបចាត់ចែង វិធាននៃការប្រើប្រាស់និងនីតិវិធីនៃការបើកប្រាក់ចំណាយពីមូលនិធិឃុំ សង្កាត់ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៧៩.–**

ឃុំ សង្កាត់ត្រូវរៀបចំនិងអនុម័តថវិការបស់ខ្លួនជារៀងរាល់ឆ្នាំ ។ល។

ថវិកាឃុំ សង្កាត់ត្រូវរៀបចំទៅតាមទំរង់មួយនិងអនុម័តនៅក្នុងកាលបរិច្ឆេទ ឬមុនកាលបរិច្ឆេទមួយអនុលោមទៅតាមប្រពន្ធ័ថវិកាជាតិ ។

ថវិកាឃុំ សង្កាត់ត្រូវមានតុល្យភាពរវាងចំណូលសរុបនិងចំណាយសរុប ។

ឃុំ សង្កាត់អាចបង្កើនចំណាយបាន តែត្រូវឱ្យស្របទៅតាមចំណូលរបស់ខ្លួន ។

ថវិកាឃុំ សង្កាត់ត្រូវឆ្លុះបញ្ចាំងអំពីអាទិភាពនិងសេចក្តីត្រូវការនៃផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគរបស់ឃុំ សង្កាត់ ។

នីតិវិធីនៃការរៀបចំនិងការអនុម័តថវិកាខាងលើត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៨០.-**

ឃុំ សង្កាត់គ្មានសិទ្ធិខ្ចីប្រាក់បានឡើយ ។

ឃុំ សង្កាត់មិនអាចធានារ៉ាប់រងចំពោះការខ្ចី ឬកាតព្វកិច្ចហិរញ្ញវត្ថុណាមួយបានឡើយ ។

**មាត្រា ៨១.-**

ឃុំ សង្កាត់មានសិទ្ធិទទួលបាននូវការផ្ទេរទ្រព្យសម្បត្តិមួយផ្នែករបស់រដ្ឋមកជាទ្រព្យសម្បត្តិរបស់ឃុំ សង្កាត់ ។

ឃុំ សង្កាត់ត្រូវគ្រប់គ្រងឱ្យបានល្អនូវទ្រព្យសម្បត្តិដែលរកបានដោយខ្លួនឯងនិងទ្រព្យសម្បត្តិដែលរដ្ឋបានប្រគល់ឱ្យ ។

ឃុំ សង្កាត់អាចប្រើប្រាស់និងទាញយកផលចំណូលពីទ្រព្យសម្បត្តិដែលរដ្ឋបានប្រគល់ឱ្យខ្លួនគ្រប់គ្រង ។

ឃុំ សង្កាត់ត្រូវថែរក្សាការពារទ្រព្យសម្បត្តិដែលរដ្ឋប្រគល់ឱ្យៗបានគង់វង្ស ហើយទ្រព្យសម្បត្តិទាំងនោះ ឃុំ សង្កាត់គ្មានសិទ្ធិលក់ដូរឬផ្ទេរកម្មសិទ្ធិ ឬផ្ទេរការប្រើប្រាស់ដោយគ្មានការយល់ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បន្ទាប់ពីមានយោបល់ឯកភាពរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃបានឡើយ ។

នីតិវិធីចាត់ចែងនិងប្រើប្រាស់ទ្រព្យសម្បត្តិខាងលើ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៨២.-**

ឃុំ សង្កាត់ត្រូវបង្កើតឱ្យមាននូវប្រព័ន្ធគ្រប់គ្រង តាមដាននិងត្រួតពិនិត្យហិរញ្ញវត្ថុរបស់ខ្លួនដែលរួមមាន : ល.ត.

- បទដ្ឋានហិរញ្ញវត្ថុនិងការអនុវត្តជាក់ស្តែងផ្នែកគណនេយ្យ
- ការចាត់ចែង គ្រប់គ្រងទ្រព្យសម្បត្តិ
- តំរូវការផ្សេងៗ ក្នុងការធ្វើសវនកម្ម
- ការគ្រប់គ្រងហិរញ្ញវត្ថុប្រកបដោយតម្លាភាព ប្រសិទ្ធិភាពនិងការទទួលខុសត្រូវ ។

ប្រព័ន្ធនៃការគ្រប់គ្រង ការតាមដាននិងការត្រួតពិនិត្យហិរញ្ញវត្ថុឃុំ សង្កាត់ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៨៣.–**

របបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់ឃុំ សង្កាត់ត្រូវស្ថិតក្រោមការត្រួតពិនិត្យរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បន្ទាប់ពីបានពិភាក្សាឯកភាពលើគោលការណ៍ជាមួយក្រសួងមហាផ្ទៃ ។

## ជំពូកទី ៨
## ទោសប្បញ្ញត្តិ

**មាត្រា ៨៤.–**

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលមិនគោរពតាមបទប្បញ្ញត្តិនៃច្បាប់នេះត្រូវទទួលវិន័យដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ។

វិន័យរួមមាន :

- ស្តីបន្ទោសក្នុងអង្គប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ដោយមានកំណត់ហេតុច្បាស់លាស់
- ករណីនៅតែបន្តប្រព្រឹត្តកំហុស ត្រូវកាត់មួយផ្នែកឬទាំងអស់នូវប្រាក់ឧបត្ថម្ភ ។

វិន័យដែលតម្រូវឱ្យកាត់មួយផ្នែកឬទាំងអស់នូវប្រាក់ឧបត្ថម្ភដូចចែងខាងលើអាចអនុវត្តបាន លុះត្រាតែមានការយល់ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ តាមសេចក្តីស្នើសុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

ប្រាក់ឧបត្ថម្ភដែលកាត់នេះត្រូវបានមកជាប្រយោជន៍នៃថវិកាឃុំ សង្កាត់ ។/.

ក្នុងករណីបានអនុវត្តបភាពវិន័យទាំងពីរខាងលើរួចហើយ តែសាមីខ្លួននៅតែមិនរាងចាល ក្រុមប្រឹក្សាឃុំ សង្កាត់អាចបញ្ឈប់ជននោះពីមុខតំណែងជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដោយការបោះឆ្នោតអនុម័តតាមសម្លេងភាគច្រើនដាច់ខាតនៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូល ហើយត្រូវធ្វើការជ្រើសរើសសមាជិកថ្មីមកជំនួសតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងវាក្យខ័ណ្ឌទី ២ មាត្រា ១៦នៃច្បាប់នេះ ។

ក្នុងករណីប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ជាមេឃុំ ចៅសង្កាត់ទទួលវិន័យ ត្រូវជ្រើសយកសមាជិកណាម្នាក់ក្នុងក្រុមប្រឹក្សាឬមន្ត្រីម្នាក់ដែលចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃឱ្យដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ដើម្បីអនុវត្តបភាពវិន័យខាងលើនេះ ។

មន្ត្រីដែលចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃឱ្យដឹកនាំកិច្ចប្រជុំខាងលើនេះពុំមានសិទ្ធិអនុម័តឡើយ ។

## ជំពូកទី ៩
## អន្តរប្បញ្ញត្តិ

**មាត្រា ៨៥.-**

ដើម្បីមានមូលដ្ឋានសំរាប់រៀបចំបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់និងគ្រប់គ្រងឃុំ សង្កាត់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញប្រកាសអំពីចំនួន ឈ្មោះនិងព្រំប្រទល់របស់ឃុំ សង្កាត់ ក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជាឱ្យបាន ៩ខែមុនកាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នាអាណត្តិដំបូងនេះ ។

**មាត្រា ៨៦.-**

ក្រោយការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នាអាណត្តិទី ១ នេះ ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗ ត្រូវរៀបចំឡើងវិញនូវមេភូមិនានាចំណុះឃុំ សង្កាត់របស់ខ្លួនទៅតាមបែបបទនីតិវិធីដូចមានចែងក្នុងមាត្រា ៣០នៃច្បាប់នេះ ។

**មាត្រា ៨៧.-**

ដើម្បីបង្កលក្ខណៈសម្បត្តិដល់ការគ្រប់គ្រងឃុំ សង្កាត់តាមប្រព័ន្ធវិមជ្ឈការ ត្រូវបង្កើតគណៈកម្មាធិការអន្តរក្រសួងមួយឈ្មោះថា "គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់" ដែលមានរដ្ឋមន្ត្រីក្រសួងមហាផ្ទៃជាប្រធាន ។ល។

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ត្រូវបង្កើតឡើងដោយព្រះរាជក្រឹត្យតាម សំណើរបស់នាយករដ្ឋមន្ត្រី ។

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ត្រូវបង្កើតបន្ទាប់ពីច្បាប់នេះបានចូលជាធរមាន ហើយត្រូវបញ្ចប់អាណត្តិរបស់ខ្លួនឱ្យបាន ៩ខែមុនកាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នាអាណត្តិបន្ទាប់ ។

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់អាចចែកចេញជាអនុគណៈកម្មការតាមការចាំបាច់ ។

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ត្រូវយកអង្គភាពដែលបានបង្កើតឡើងស្របតាមមាត្រា ៥៩នៃច្បាប់នេះធ្វើជាលេខាធិការដ្ឋាន ។

**មាត្រា ៨៨.-**

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់មានសមត្ថកិច្ចធ្វើសេចក្តីស្នើយោបល់ទៅក្រសួងមហាផ្ទៃនិងរាជរដ្ឋាភិបាលអំពីបញ្ហានានាដូចខាងក្រោម :

- សិក្សាស្រាវជ្រាវកំណត់ឡើងវិញនូវព្រំប្រទល់ឃុំ សង្កាត់ទាំងអស់ក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា
- បែងចែកមុខងារ សិទ្ធិអំណាចនិងភារកិច្ចផ្សេងៗ រវាងរាជរដ្ឋាភិបាលនិងឃុំ សង្កាត់ព្រមទាំងរៀបចំឱ្យមានកិច្ចសហការសំរបសំរួលរវាងឃុំ សង្កាត់ ពីរឬច្រើន ។
- បណ្តុះបណ្តាល បង្កើនសមត្ថភាពដល់ក្រុមប្រឹក្សាឃុំ សង្កាត់
- រៀបចំប្រាក់ចំណូលនិងសារពើពន្ធសំរាប់ឃុំ សង្កាត់
- គាំទ្រផ្នែកបច្ចេកទេសដល់ឃុំ សង្កាត់
- រិះរកមធ្យោបាយសំរាប់ផ្តល់ព័ត៌មាននិងតំរង់ទិសរដ្ឋបាលសាធារណៈអំពីកិច្ចដំណើរការនៃប្រព័ន្ធគ្រប់គ្រងឃុំ សង្កាត់តាមបែបប្រជាធិបតេយ្យនិងវិមជ្ឈការ
- ផ្តល់យោបល់ដល់រាជរដ្ឋាភិបាលអំពីការអនុវត្តនយោបាយវិមជ្ឈការក្រោមអំណាចនៃច្បាប់នេះនិងផ្តល់យោបល់លើការកែទម្រង់រដ្ឋបាលសាធារណៈ
- រៀបចំព្រាងលិខិតបទដ្ឋានសំរាប់អនុវត្តច្បាប់នេះ
- រួមយោបល់ទៅលើអនុក្រឹត្យដែលមានការពាក់ព័ន្ធដល់ការងារនៅថ្នាក់ឃុំ សង្កាត់ ។ល។

- កំណត់របបគ្រប់គ្រងរដ្ឋបាលអន្តរកាលចំពោះឃុំ សង្កាត់ដែលពុំមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីអនុវត្តនយោបាយវិមជ្ឈការ ។

**មាត្រា ៨៩.-**

ក្រោយការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នាអាណត្តិដំបូងនេះ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដោយផ្អែកតាមសេចក្តីស្នើយោបល់របស់គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់អាចស្នើបង្កើតឃុំ សង្កាត់ លុបចោលឃុំ សង្កាត់ កែប្រែព្រំប្រទល់ឃុំ សង្កាត់ ផ្លាស់ប្តូរឈ្មោះឃុំ សង្កាត់ តាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា ៦ និងមាត្រា ១៨នៃច្បាប់នេះ សំរាប់ដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នាអាណត្តិទី ២ ។

## ជំពូកទី ១០

## អវសានប្បញ្ញត្តិ

**មាត្រា ៩០.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍ ។៚

រាជធានីភ្នំពេញថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០១

ក្នុងព្រះបរមនាមនិងតាមព្រះរាជបង្គាប់

ប្រមុខរដ្ឋស្តីទី

**ហត្ថលេខា**

**ជា ស៊ីម**

បានបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី

សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

**ហត្ថលេខា**

**ស ខេង   យូ ហុកគ្រី**

លេខ : ៧០ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញថ្ងៃទី ២១ ខែ ៣ ឆ្នាំ ២០០១

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឈាវឌី សាន**

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤៤ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## ការផ្ទេរសិទ្ធិមជ្ឈការអំណាច តួនាទី និង ភារកិច្ច ទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃ ទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃ ទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ។
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ ។
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី ១៩ ខែ មិនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។
- បានឃើញព្រះរាជក្រិត្យលេខ នស/រកត/០៥០១/១៧៥ ចុះថ្ងៃ ទី ១៨ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ។
- យោងតាមស្មារតីនៃអង្គប្រជុំរបស់គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ កាលពីថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០០២ ។
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

### សំរេច

## ជំពូកទី១
## ការប្រគល់អំណាចដល់ក្រុមប្រឹក្សាឃុំ សង្កាត់ និងអភិបាលកិច្ចរបស់ឃុំ សង្កាត់

**មាត្រា ១.-**

ឃុំ សង្កាត់ជានីតិបុគ្គល ។

ឃុំ សង្កាត់នីមួយៗត្រូវមានក្រុមប្រឹក្សាឃុំ សង្កាត់មួយ ។

ឃុំ សង្កាត់មានមុខងារ អំណាច និងករណីយកិច្ចក្នុងការគ្រប់គ្រង និង ធ្វើអភិបាលកិច្ចក្នុងឃុំ សង្កាត់របស់ខ្លួនស្របនឹងរដ្ឋធម្មនុញ្ញ ច្បាប់ អនុក្រឹត្យ ប្រកាស ឬលិខិតបទដ្ឋាននានាជាធរមាន។

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានជ្រើសតាំងឡើង ដោយការបោះឆ្នោតស្របតាមលក្ខខ័ណ្ឌនៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។

ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវទទួលខុសត្រូវចំពោះមុខប្រជាពលរដ្ឋទាំងអស់នៅក្នុង ឃុំ សង្កាត់របស់ខ្លួន។

**មាត្រា ២.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវផ្ដល់លិខិតជាលាយល័ក្ខអក្សរដល់ក្រសួងមហាផ្ទៃ និង ចម្លងជូនអភិបាលខេត្ត ក្រុងនីមួយៗនូវ ÷

- បញ្ជីឈ្មោះបេក្ខជនរបស់គណបក្សនយោបាយដែលបានជាប់ឆ្នោតជាផ្លូវការតាមឃុំ សង្កាត់នីមួយៗ
- ឈ្មោះរបស់បេក្ខជនដែលត្រូវបានប្រកាសថាជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់
- ឈ្មោះរបស់ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ ជំទប់ទី១ ចៅសង្កាត់រងទី១ និង ជំទប់ទី២ ចៅសង្កាត់រងទី២ ដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានជ្រើសចេញពីបញ្ជីឈ្មោះបេក្ខជនដែលបានជាប់ឆ្នោតជាផ្លូវការ
- ឈ្មោះសមាជិកថ្មីដើម្បីជំនួសសមាជិកនៃក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានបោះបង់ចោលការងារ ឬ បានបញ្ឈប់ពីតំណែងក្នុងករណីដែលមានសមាជិកណាម្នាក់នៃក្រុមប្រឹក្សាឃុំ សង្កាត់បានបោះបង់ចោលការងារ ឬ បានបញ្ឈប់ពីតំណែង។

**មាត្រា ៣.-**

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវរៀបចំឱ្យមានកិច្ចប្រជុំដំបូងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងរយៈពេល ១៤ថ្ងៃ យ៉ាងយូរបន្ទាប់ពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានប្រកាសលទ្ធផលជាផ្លូវការនៃការបោះឆ្នោត ។

បែបបទ នីតិវិធី និង កិច្ចដំណើរការនៃការប្រជុំលើកដំបូងនេះត្រូវកំណត់ដោយសេចក្ដីណែនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ តាមការអនុម័តយល់ព្រមដោយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ។



ឬ

**មាត្រា ៤.–**

ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់មានងារជាផ្លូវការថា " ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ " ។

មេឃុំមានងារជាផ្លូវការថា "មេឃុំ" និង ចៅសង្កាត់មានងារជាផ្លូវការថា "ចៅសង្កាត់ " ។

ជំទប់មានងារជាផ្លូវការថា "ជំទប់" និង ចៅសង្កាត់រង មានងារជាផ្លូវការថា "ចៅសង្កាត់រង " ។

សមាជិកដែលបានជាប់ឆ្នោត ក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ មានងារជាផ្លូវការថា " សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ " ។

ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រងមានងារជាផ្លូវការតែក្នុងអំឡុងពេលដែលសាមីខ្លួនកាន់តំណែងនោះប៉ុណ្ណោះ ។

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់មានងារជាផ្លូវការតែក្នុងអំឡុងពេលដែលសាមីខ្លួននៅជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ប៉ុណ្ណោះ ។

**មាត្រា ៥.–**

ឃុំ សង្កាត់នីមួយៗត្រូវមានស្មៀនឃុំ សង្កាត់មួយរូប ។

ស្មៀនឃុំ សង្កាត់ត្រូវបានតែងតាំង និងត្រូវបានប្រើប្រាស់ក្នុងរចនាសម្ព័ន្ធរដ្ឋបាលរបស់ក្រសួងមហាផ្ទៃ ។

ស្មៀនឃុំ សង្កាត់ត្រូវជួយ និង ផ្តល់យោបល់ដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ដោយអនុលោមទៅតាមតួនាទី និងមុខងារដែលបានកំណត់ក្នុងប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ តាមការអនុម័តយល់ព្រមដោយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ។

**មាត្រា ៦.–**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវអនុម័តបទបញ្ជាផ្ទៃក្នុងសំរាប់ដំណើរការ និង ចាត់ចែងកិច្ចប្រជុំព្រមទាំងអនុវត្តភារកិច្ចរបស់ខ្លួន ។

បទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវរៀបចំផ្អែកលើមូលដ្ឋាននៃសេចក្តីណែនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ តាមការអនុម័តយល់ព្រមដោយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ។

**មាត្រា ៧.–**

សាលាឃុំ សង្កាត់ គឺជាការិយាល័យរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងជាទីចាត់ការរដ្ឋបាលរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

សាលាឃុំ សង្កាត់ត្រូវបើកធ្វើការឱ្យបានទៀងទាត់តាមពេលម៉ោងធ្វើការប្រចាំថ្ងៃស្របតាមម៉ោងធ្វើការរបស់ក្រសួងស្ថាប័ននានារបស់រាជរដ្ឋាភិបាល ។

ក្នុងកំឡុងពេលម៉ោងធ្វើការប្រជាពលរដ្ឋមានសិទ្ធិ ÷

- ធ្វើទំនាក់ទំនង និង ធ្វើកិច្ចការជាមួយក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន
- ទទួលពត៌មានអំពីសំណើ និង ការងារនានាពីក្រុមប្រឹក្សាឃុំ សង្កាត់

- មើល និង អានឯកសាររបស់ឃុំ សង្កាត់

- ចូលរួមយោបល់ ឬ តវ៉ាលើបញ្ហាណាមួយ ។

**មាត្រា ៨.-**

ឃុំ សង្កាត់គឺជាម្ចាស់លើលិខិត និង ឯកសារទាំងអស់ដែលបានប្រគល់ត្រឹមត្រូវដល់ ÷

-ការិយាល័យរបស់ក្រុមប្រឹក្សាឃុំ សង្កាត់

- គណៈកម្មាធិការណាមួយរបស់មេឃុំ ចៅសង្កាត់ ឬក្រុមប្រឹក្សាឃុំ សង្កាត់

- សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ឬមន្ត្រីនៅការិយាល័យក្រុមប្រឹក្សាឃុំ សង្កាត់ ។

**មាត្រា ៩.-**

ឃុំ សង្កាត់គឺជាម្ចាស់លើរាល់លិខិត និង ឯកសារដែលរៀបចំឡើងដោយក្រុមប្រឹក្សា ឃុំ សង្កាត់ ឬក្នុងនាមក្រុមប្រឹក្សាឃុំ សង្កាត់ និង ជាម្ចាស់កម្មសិទ្ធិលើតែមប្រ៊ី ត្រាឃុំ សង្កាត់ ព្រមទាំងឧបករណ៍ផ្សេងៗ ទៀតទាំងអស់របស់ឃុំ សង្កាត់ ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធានាទុកដាក់ឯកសារ លិខិតស្នាម តែមប្រ៊ី ត្រា អោយបានត្រឹមត្រូវ និង គង់វង្ស ។

**មាត្រា ១០.-**

ក្រុមប្រឹក្សាឃុំសង្កាត់ត្រូវរៀបចំឱ្យមានក្តារខៀនពត៌មានសាធារណៈនៅសាលាឃុំ សង្កាត់របស់ខ្លួន ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវជ្រើសរើសកន្លែងដែលសមស្របដើម្បីដាក់ក្តារខៀនពត៌មានសាធារណៈនៅតាមភូមិ ។

ទីកន្លែងដែលដាក់ក្តារខៀនពត៌មានសាធារណៈត្រូវមានការយល់ព្រមពីម្ចាស់កម្មសិទ្ធិ ប្រសិនបើកន្លែងនោះមានអ្នកកាន់កាប់រួចហើយ ។

ក្តារខៀនពត៌មានសាធារណៈត្រូវសរសេរ ឬ បិទប្រកាសជូនដំណឹងជាផ្លូវការ និង ពត៌មានដទៃទៀតរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

ការសរសេរ ឬ ការបិទប្រកាសពត៌មានជាសាធារណៈ ត្រូវរក្សាទុកអោយបានរយៈ យ៉ាងតិច១០ថ្ងៃ ។

**មាត្រា ១១.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ជាតំណាង និង ជាអ្នកបំរើអោយផលប្រយោជន៍ទូទៅរបស់ប្រជាពលរដ្ឋទាំងអស់នៅក្នុងឃុំសង្កាត់របស់ខ្លួន ។

ក្រុមប្រឹក្សាត្រូវលើកស្ទួយ និង សំរបសំរួលក្នុងការអភិវឌ្ឍន៍ឃុំ សង្កាត់ ដោយត្រូវរកប្រភពជំនួយឥតសំណង និង គៀងគរសមត្ថភាព និង ធនធានពី ÷

- ក្នុងឃុំ សង្កាត់របស់ខ្លួនផ្ទាល់

- រាជរដ្ឋាភិបាល និង ក្រសួង ស្ថាប័ននានានៃរាជរដ្ឋាភិបាល

- អង្គការជាតិ អន្តរជាតិ និង អង្គការនានានៅមូលដ្ឋាន
- ផ្នែកឯកជន និង សមាគមសជននានា ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវជ្រើសរើសវិធីសាស្ត្រសមស្រប និង មានប្រសិទ្ធភាព សំរាប់អនុវត្តន៍ក្នុងកិច្ចអភិវឌ្ឍន៍ឃុំ សង្កាត់របស់ខ្លួន ។

**មាត្រា ១២.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវសំរបសំរួល និង លើកស្ទួយយ៉ាងសកម្មនូវការអភិវឌ្ឍន៍លទ្ធិប្រជាធិបតេយ្យ ក្នុងឃុំ សង្កាត់ ដោយត្រូវបង្កើតឡើងនូវយន្តការដើម្បីពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ សង្គមស៊ីវិល និង សហគមន៍នៅក្នុងឃុំ សង្កាត់របស់ខ្លួន ។

កិច្ចពិភាក្សា និង ការអនុវត្តកិច្ចការរដ្ឋបាលរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវមានលក្ខណៈចំហរ និង មានតម្លាភាព ។

**មាត្រា ១៣.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធានាអោយឃុំ សង្កាត់នីមួយៗមានធនធានមនុស្ស និង ធនធានសំភារៈសមស្របដើម្បីដំណើរការការងាររបស់ខ្លួន ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធានាអោយសមាជិករបស់ខ្លួន និង មន្ត្រីដែលបានតែងតាំងនៅក្នុងឃុំ សង្កាត់ឱ្យមានការយល់ដឹង និង មានឥរិយាបថសមស្រប ដើម្បីអនុវត្តតួនាទី និង ភារកិច្ចរបស់ខ្លួនតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់ និង លិខិតបទដ្ឋាន នានាជាធរមាន ។

**មាត្រា ១៤.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវធ្វើការពិនិត្យ និង វាយតំលៃអំពីសកម្មភាពនានាក្នុងការកសាងសមត្ថភាពសាធារណជននៅក្នុងឃុំ សង្កាត់ តាមរយៈ ÷

- ការបណ្តុះបណ្តាល
- ឯកសារ អត្ថបទ ទស្សនាវដ្តី និង សៀវភៅពតិមានផ្សេងៗ
- ការអប់រំតាមរយៈ វិទ្យុ ទូរទស្សន៍ កាសែត និង ប្រព័ន្ធផ្សព្វផ្សាយដទៃទៀត..... ។

**មាត្រា ១៥.-**

ឃុំ សង្កាត់នីមួយៗត្រូវធ្វើសហការជាមួយឃុំ សង្កាត់ផ្សេងទៀតដើម្បីជួយឧបត្ថម្ភគាំទ្រគ្នាទៅវិញទៅមក ។

តាមការស្នើសុំរបស់ឃុំ សង្កាត់ផ្សេងទៀត ឃុំ សង្កាត់សាមីអាចផ្តល់យោបល់ និង ផ្តល់សេវាគាំទ្រខាងរដ្ឋបាល បច្ចេកទេស និង ហិរញ្ញវត្ថុដល់ឃុំ សង្កាត់នោះ ។

មាត្រា ១៦.-

ក្នុងកិច្ចសហប្រតិបត្តិការរវាងឃុំ សង្កាត់មួយ ជាមួយឃុំ សង្កាត់ដទៃទៀត ត្រូវអនុវត្តទៅតាមកិច្ចព្រមព្រៀង ឬ តាមការចាត់ចែងរួម ដែលនឹងជួយសំរបសំរួលដល់ការរៀបចំហេដ្ឋារចនាសម្ព័ន្ធ និង ការផ្តល់សេវាឱ្យកាន់តែមានប្រសិទ្ធភាព។

ក្រសួងមហាផ្ទៃត្រូវជួយដល់ឃុំ សង្កាត់ដើម្បីរៀបចំកិច្ចព្រមព្រៀង ឬ ការចាត់ចែងការងាររួមគ្នានេះ ។

## ជំពូកទី២
## មេឃុំ ចៅសង្កាត់ គណៈកម្មាធិការនានា និង អ្នកជំនួយការ

មាត្រា ១៧.-

មេឃុំ ចៅសង្កាត់មានសិទ្ធិតែងតាំងគណៈកម្មាធិការជំនួយការនានា តាមការចាំបាច់ដើម្បីផ្តល់យោបល់ឱ្យខ្លួន ។

មាត្រា ១៨.-

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវកំណត់តួនាទី ភារកិច្ច បទបញ្ជាផ្ទៃក្នុង និង នីតិវិធីធ្វើការងាររបស់គណៈកម្មាធិការទាំងនេះដោយអនុលោមទៅតាមស្មារតីនៃសេចក្តីណែនាំ និង លិខិតបទដ្ឋាននានារបស់ក្រសួងមហាផ្ទៃ ដែលបានអនុម័តយល់ព្រមដោយគណៈកម្មាធិការជាតិគាំទ្រ ឃុំ សង្កាត់ ។

មាត្រា ១៩.-

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវតែងតាំងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ម្នាក់ជានារីដើម្បីអោយទទួលបន្ទុកកិច្ចការនារី និង កុមារ ។

ក្នុងករណីគ្មាននារីជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវតែងតាំងនារីមួយរូបធ្វើជាជំនួយការទទួលបន្ទុកកិច្ចការនារី និង កុមារ ។

ជំនួយការទទួលបន្ទុកកិច្ចការនារី និង កុមារត្រូវបានផ្តល់សិទ្ធិអោយចូលរួមក្នុងរាល់កិច្ចពិភាក្សា ឬ កិច្ចប្រជុំរបស់គណៈកម្មាធិការនានារបស់ឃុំ សង្កាត់ និង កិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ប៉ុន្តែគ្មានសិទ្ធិបោះឆ្នោតអនុម័តឡើយ ។

មាត្រា ២០.-

មេឃុំ ចៅសង្កាត់ត្រូវ ÷

- ចូលរួមក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សា និង គណៈកម្មាធិការជំនួយការនានារបស់ឃុំ សង្កាត់
- លើកយោបល់ដល់ក្រុមប្រឹក្សាអំពីរបៀបបង្កើន និង កសាងសមត្ថភាពនៃធនធានរបស់ឃុំ សង្កាត់ និង ក្រុមប្រឹក្សាឃុំ សង្កាត់
- លើកយោបល់ដល់ក្រុមប្រឹក្សាឃុំ សង្កាត់ពីរបៀបគៀងគរធនធាន និង សមត្ថភាព ដើម្បីអភិវឌ្ឍន៍ឃុំ សង្កាត់

របស់ខ្លួនពីប្រភពនានាមានជាអាទិ៍ ÷

- ភូមិទាំងអស់ក្នុងឃុំ សង្កាត់របស់ខ្លួន
- ឃុំ សង្កាត់ផ្សេង១
- រាជរដ្ឋាភិបាល និង ក្រសួងស្ថាប័ននានានៃរាជរដ្ឋាភិបាល
- ជំនួយឥតសំណងពីអង្គការជាតិ អន្តរជាតិ និង អង្គការនានានៅមូលដ្ឋាន
- ផ្នែកឯកជន និង សម្បុរសជននានា

– ស្វែងរកការចូលរួមក្នុងភាពជាដៃគូពីក្រុមប្រឹក្សាឃុំ សង្កាត់ដែលនៅក្បែរគ្នា

– លើកយោបល់ដល់ក្រុមប្រឹក្សាឃុំ សង្កាត់ពីរបៀប ÷

- រៀបចំ និង អនុម័ត ផែនការអភិវឌ្ឍន៍ និង ថវិកាឃុំ សង្កាត់
- អនុវត្ត ផែនការអភិវឌ្ឍន៍ និង ថវិកាឃុំ សង្កាត់
- ត្រួតពិនិត្យ និង វាយតំលៃការអនុវត្តន៍ ផែនការអភិវឌ្ឍន៍ និង ថវិកាឃុំ សង្កាត់
- រៀបចំ និង អនុម័តរបាយការណ៍ប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់

– រាយការណ៍ជូនក្រុមប្រឹក្សាឃុំ សង្កាត់ នៅរៀងរាល់ខែអំពីសកម្មភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ខែកន្លងមក ព្រមទាំងការអនុវត្តន៍គោលនយោបាយ និង ការសំរេចចិត្តរបស់ក្រុមប្រឹក្សាឃុំ សង្កាត់

– ធានាអនុវត្តយ៉ាងត្រឹមត្រូវនូវរាល់សេចក្តីសំរេច និង ដីការបស់ឃុំ សង្កាត់

– ធានាគ្រប់គ្រង និង ត្រួតពិនិត្យយ៉ាងត្រឹមត្រូវកិច្ចការហិរញ្ញវត្ថុរបស់ក្រុមប្រឹក្សាឃុំ សង្កាត់

– អនុវត្តកិច្ចការប្រចាំថ្ងៃក្នុងឃុំ សង្កាត់

– ពិនិត្យមើលការងាររបស់ស្មៀនឃុំ សង្កាត់ ។

**មាត្រា ២១.–**

ជំទប់ទី១ ឬ ចៅសង្កាត់រងទី១ ត្រូវជួយមេឃុំចៅសង្កាត់ លើបញ្ហាសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ជំទប់ទី២ ឬ ចៅសង្កាត់រងទី២ ត្រូវជួយមេឃុំចៅសង្កាត់ លើបញ្ហាដែលពាក់ព័ន្ធនឹងកិច្ចការសង្គមកិច្ច រដ្ឋបាល សេវាសាធារណៈ និង សណ្តាប់ធ្នាប់សាធារណៈ ។

មេឃុំ ចៅសង្កាត់ អាចប្រគល់កិច្ចការបន្ថែមទៀតដល់ជំទប់ ឬ ចៅសង្កាត់រង របស់ខ្លួនតាមការចាំបាច់ ។

ក្នុងករណីមេឃុំ ឬ ចៅសង្កាត់អវត្តមានត្រូវធ្វើការផ្ទេរសិទ្ធិជាលាយលក្ខ័អក្សរទៅជំទប់ ឬ ចៅសង្កាត់រងតាមឋានានុក្រមដើម្បីធ្វើជាមេឃុំ ចៅសង្កាត់ស្តីទី ក្នុងរយៈពេលដែលមេឃុំ ចៅសង្កាត់នោះអវត្តមាន ។

ជំទប់ ឬ ចៅសង្កាត់រងមិនអាចចុះហត្ថលេខាលើឯកសារ លិខិតស្នាមនានា ដោយមិនមានការប្រគល់សិទ្ធិអំណាចពីមេឃុំ ចៅសង្កាត់ ឬ ក្រុមប្រឹក្សាឃុំ សង្កាត់ឡើយ ។

**មាត្រា ២២.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវជ្រើសរើសមេភូមិម្នាក់ នៅក្នុងភូមិនីមួយៗ ។

មេភូមិ ត្រូវតែងតាំង អនុប្រធានភូមិ និង សមាជិកភូមិ ដើម្បីធ្វើជាជំនួយការ ។

ប្រធានភូមិ អនុប្រធានភូមិ និង សមាជិកភូមិត្រូវតែជាប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតនៃភូមិនោះហើយត្រូវមាននារីយ៉ាងតិចមួយរូប ។

យោងតាមសភាពការណ៍ជាក់ស្តែងនៃភូមិនីមួយៗ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវខិតខំជ្រើសរើសនារីអោយទទួលតំណែងជាមេភូមិ ឬ អនុប្រធានភូមិ ។

បែបបទ នីតិវិធីនៃការជ្រើសរើសមេភូមិ ការតែងតាំងអនុប្រធានភូមិ សមាជិកភូមិ ការផ្លាស់ប្តូរមេភូមិ និងជំនួយការ មេភូមិត្រូវកំណត់ដោយសេចក្តីណែនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បន្ទាប់ពីមានការអនុម័តយល់ព្រមពីគណៈកម្មាធិការជាតិ គាំទ្រឃុំ សង្កាត់ ។

**មាត្រា ២៣.-**

មេភូមិជាតំណាងអោយប្រជាពលរដ្ឋទាំងអស់នៅក្នុងភូមិ និង ជាខ្សែរយៈចំបងសម្រាប់តភ្ជាប់ទំនាក់ទំនងរវាងភូមិ និង ក្រុមប្រឹក្សាឃុំ សង្កាត់ ។

មេភូមិ អនុប្រធានភូមិ និង សមាជិកភូមិ ជាតំណាងភូមិក្នុងការពិគ្រោះយោបល់ជាមួយគណៈកម្មាធិការផ្តល់យោបល់អំពីកិច្ចការភូមិ ។

ក្នុងការសំរេចបញ្ហាណាមួយដែលពាក់ព័ន្ធនឹងភូមិ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវពិគ្រោះយោបល់ជាមួយមេភូមិជាមុនសិន ។

**មាត្រា ២៤.-**

មេភូមិត្រូវ ÷

- បង្កើនការពិគ្រោះយោបល់ និងកិច្ចសហប្រតិបត្តិការជាមួយក្រុមប្រឹក្សា ឃុំ សង្កាត់របស់ខ្លួន
- ចូលរួមកិច្ចប្រជុំក្នុងគណកម្មាធិការនានារបស់ឃុំ សង្កាត់ ដើម្បីផ្តល់យោបល់អំពីកិច្ចការដែលពាក់ពន្ធ័ក្នុងភូមិរបស់ខ្លួននៅពេលដែលក្រុមប្រឹក្សាឃុំ សង្កាត់តំរូវ
- ផ្តល់យោបល់ដល់គណៈកម្មាធិការកិច្ចការភូមិ អំពីតំរូវការ និង ផលប្រយោជន៍របស់ភូមិ
- ផ្តល់យោបល់ដល់គណៈកម្មាធិការកិច្ចការភូមិ អំពីរបៀបបង្កើន និង កសាងសមត្ថភាពនៃធនធានរបស់ភូមិ
- ផ្តល់យោបល់ដល់គណៈកម្មាធិការផែនការអភិវឌ្ឍន៍ និង ថវិកាអំពី ÷

- **តម្រូវការ និង អាទិភាពរបស់ភូមិដើម្បីបញ្ចូលក្នុងថវិកា និង ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់**
- **អនុវត្តថវិកា និង ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ក្នុងភូមិរបស់ខ្លួន**
- **ត្រួតពិនិត្យ និង វាយតំលៃ ការអនុវត្តថវិកា និង ផែនការអភិវឌ្ឍន៍របស់ឃុំ សង្កាត់ក្នុងភូមិរបស់ខ្លួន**

- ធ្វើសេចក្តីរាយការណ៍រាល់បញ្ហាដែលពាក់ព័ន្ធនឹងភូមិ ដើម្បីបញ្ចូលក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់
- ទទួលខុសត្រូវអនុវត្តកិច្ចការដែលបានប្រគល់អោយដោយក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន
- ពិគ្រោះយ៉ាងទៀងទាត់ជាមួយប្រជាពលរដ្ឋក្នុងភូមិរបស់ខ្លួន
- ដោះស្រាយបញ្ហាដែលជាផលប្រយោជន៍រួមជាមួយភូមិកៀ្បរគ្នា
- ចូលរួមកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងករណីមានសំណូមពរពីក្រុមប្រឹក្សាឃុំ សង្កាត់ ។

**មាត្រា ២៥.–**

មេភូមិ មិនមានសិទ្ធិអំណាចចុះហត្ថលេខាលើកិច្ចសន្យា ឬ ការផ្ទេរអំណាច ឬ ការចាត់ចែងដទៃទៀតក្នុងនាមភូមិបានឡើយ ។

មេភូមិ អនុប្រធានភូមិ និង សមាជិកភូមិត្រូវជួបប្រជុំយ៉ាងតិចមួយដងក្នុងមួយខែ ។

**មាត្រា ២៦.–**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវពិភាក្សាជាមួយមេភូមិ ដើម្បីរៀបចំអោយមានទីកន្លែងសំរាប់មេភូមិជួបប្រាស្រ័យជាមួយមជ្ឈដ្ឋាននានាតាមភូមិនីមួយៗ ។

ទីកន្លែងនោះមានជាទីស្នាក់ការភូមិចំពោះកន្លែងដែលមានទីស្នាក់ការភូមិ ។ ចំពោះកន្លែងដែលគ្មានស្នាក់ការភូមិត្រូវពិគ្រោះពិភាក្សាគ្នាដើម្បីរកទីកន្លែងសមស្របណាមួយដែលអាចជាសាលារៀន វត្តអារាម វិហារសាសនា អាគារសាធារណៈ ឬ គេហដ្ឋានផ្ទាល់របស់មេភូមិ ។ ការជ្រើសរើសយកកន្លែងទាំងនេះត្រូវមានការពិគ្រោះពិភាក្សាអោយឯកភាពគ្នាពីក្រុមប្រឹក្សាឃុំ សង្កាត់ មេភូមិ អនុប្រធានភូមិ សមាជិកភូមិ នឹងត្រូវមានការយល់ព្រមជាមុនពីម្ចាស់ទីកន្លែងទាំងនោះ ។ មេភូមិ និង ក្រុមប្រឹក្សាឃុំ,សង្កាត់ត្រូវផ្សព្វផ្សាយទីកន្លែងនោះដល់សាធារណៈជន ។

ទីកន្លែងនេះត្រូវបើកទទួលប្រជាពលរដ្ឋយ៉ាងហោចណាស់មួយថ្ងៃក្នុងមួយសប្តាហ៍ ។

មេភូមិ ឬ អនុប្រធានភូមិ ឬ សមាជិកភូមិត្រូវមានវត្តមាននៅទីកន្លែងដែលបានកំណត់នោះនាថ្ងៃនោះ ដើម្បីជួបប្រជាពលរដ្ឋ ។

ក្រៅពីការជួបប្រាស្រ័យជាទៀងទាត់ជាមួយប្រជាពលរដ្ឋរបស់ខ្លួននៅទីកន្លែងដែលបានកំណត់នេះ មេភូមិ អនុប្រធានភូមិ និង សមាជិកភូមិអាចនឹងជួយប្រាស្រ័យផ្ទាល់ជាមួយប្រជាពលរដ្ឋក្នុងភូមិរបស់ខ្លួនជាប្រចាំតាមការចាំបាច់ ។

**មាត្រា ២៧.-**

មេភូមិត្រូវធានាផ្តល់ព័តមានឯកសារជាសាធារណៈដែលពាក់ព័ន្ធនឹងភូមិរបស់ខ្លួន ដល់ប្រជាពលរដ្ឋរបស់ខ្លួន ។ ឯកសារព័តមានទាំងនោះអាចរួមមាន ពតិមានស្តីពីការប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ផែនការអភិវឌ្ឍន៍ និង ថវិកាឃុំ សង្កាត់ ។

**មាត្រា ២៨.-**

មេភូមិពុំមានសិទ្ធិអំណាចសំរេចបញ្ហាណាមួយ ដែលស្ថិតក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ដោយគ្មានការផ្ទេរអំណាចពីក្រុមប្រឹក្សាឃុំ សង្កាត់ ស្របតាមប្រកាសរបស់ក្រសួងមហាផ្ទៃដែលបានអនុមត័យល់ព្រមដោយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់បានឡើយ ។

**មាត្រា ២៩.-**

ក្រុមប្រឹក្សាឃុំ សង្កាត់មិនអាចផ្ទេរអំណាចដល់បុគ្គល ឬ គណៈកម្មាធិការ ឬ អង្គការណាមួយនៅក្នុងភូមិបានឡើយ លើកលែងតែមានការអនុញ្ញាតដែលបានចែងក្នុងប្រកាសរបស់ក្រសួងមហាផ្ទៃ ដែលបានអនុម័តយល់ព្រមដោយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ។

## ជំពូកទី៣
## សិទ្ធិរបស់ប្រជាពលរដ្ឋក្នុងឃុំ សង្កាត់

**មាត្រា ៣០.-**

ប្រជាពលរដ្ឋមានសិទ្ធិចូលរួមស្តាប់រាល់កិច្ចប្រជុំជាសាធារណៈរបស់ក្រុមប្រឹក្សាឃុំ សង្កាត់បាន ប៉ុន្តែពុំមានសិទ្ធិអនុម័តបានទេ ។

ប្រជាពលរដ្ឋអាចលើកសំណួរដល់មេឃុំ ចៅសង្កាត់ ឬ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់នៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ដោយអនុលោម ទៅតាមបទបញ្ជាផ្ទៃក្នុងសំរាប់កិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ ។

**មាត្រា ៣១.-**

ប្រជាពលរដ្ឋមានសិទ្ធិលើកសំណើ ឬ ធ្វើការប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរ ឬ ផ្ទាល់មាត់ដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ហើយក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវឆ្លើយតបនឹងសំណើ ឬ ការប្តឹងតវ៉ានោះជាក់ហិត ។

ចំពោះសំណើ ឬ ការប្តឹងតវ៉ាទាំងឡាយណាដែលមេឃុំ ចៅសង្កាត់អាចដោះស្រាយបានក្នុងសមត្ថកិច្ចរបស់ខ្លួន មេឃុំ ចៅសង្កាត់ត្រូវដោះស្រាយ ហើយចាត់អោយជូនពតិមានអំពីការដោះស្រាយនោះដល់ប្រជាពលរដ្ឋវិញ រួចហើយត្រូវធ្វើសេចក្តីរាយការណ៍ជូនក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងកិច្ចប្រជុំបន្ទាប់ ។

ចំពោះសំណើ ឬ ការប្តឹងតវ៉ាទាំងឡាយណាដែលមេឃុំ ចៅសង្កាត់មិនអាចដោះស្រាយបានក្នុងសមត្ថកិច្ចរបស់ខ្លួន មេឃុំ ចៅសង្កាត់ត្រូវដាក់ក្នុងរបៀបវារៈអង្គប្រជុំបន្ទាប់របស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

មេឃុំ ចៅសង្កាត់ ត្រូវជូនពត៌មានដល់ប្រជាពលរដ្ឋអំពីការដោះស្រាយរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

**មាត្រា ៣២.-**

ចំពោះសំណើ ឬ ការប្តឹងតវ៉ា ដូចមានចែងក្នុងមាត្រា ៤៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ ត្រូវរាយការណ៍ជូនក្រសួង ស្ថាប័ន ឬ ភ្នាក់ងាររបស់រាជរដ្ឋាភិបាលដែលមានសមត្ថកិច្ច ។

**មាត្រា ៣៣.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធានាផ្សព្វផ្សាយពត៌មានអោយបានទៀងទាត់ដល់ប្រជាពលរដ្ឋក្នុងឃុំ សង្កាត់ អំពីបញ្ហាទាំងឡាយស្របតាមសមត្ថកិច្ចរបស់ខ្លួន និង អំពីសេចក្តីសំរេចនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

## ជំពូកទី៤

## វិធានការវិន័យ និង ការបញ្ឈប់មុខតំណែងចំពោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់

**មាត្រា ៣៤.-**

រាល់ការចាត់វិធានការដាក់វិន័យចំពោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ណាម្នាក់ ដូចមានចែងក្នុងមាត្រា ៨៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ត្រូវធ្វើឡើងដោយសេចក្តីសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ តាមការបោះឆ្នោតយល់ព្រមដោយសម្លេងភាគច្រើនដាច់ខាត នៃចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូល ។

**មាត្រា ៣៥.-**

ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវផ្តល់ពត៌មានដល់ក្រសួងមហាផ្ទៃ និង គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតអំពីការបញ្ឈប់ពីមុខតំណែងជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់តាមលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ១៦ និង មាត្រា ៨៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។

**មាត្រា ៣៦.-**

ក្រោយពិនិត្យឃើញថាក្រុមប្រឹក្សាឃុំ សង្កាត់ អនុវត្តត្រឹមត្រូវតាមសមត្ថកិច្ចរបស់ខ្លួនហើយ ក្រសួងមហាផ្ទៃត្រូវស្នើសុំទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតអំពីការបញ្ឈប់ពីមុខតំណែងជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ និង ស្នើអោយជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ថ្មីមកជំនួសស្របតាមបែបបទ នីតិវិធីដូចមានចែងក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។

**មាត្រា ៣៧.-**

បន្ទាប់ពីទទួលបានលិខិតសំណូមពររបស់ក្រសួងមហាផ្ទៃហើយ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវជ្រើសរើសបេក្ខជនថ្មីដាក់ជំនួសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានបញ្ឈប់ពីតំណែង ស្របតាមល័ក្ខខ័ណ្ឌ ដូចមានចែងក្នុងមាត្រា១៦ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។

**មាត្រា ៣៨.-**

ក្នុងករណីដែលក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវរំសាយ ដោយអនុលោមទៅតាមមាត្រា ៥៧ ឬ មាត្រា ៥៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ហើយអណត្តិដែលនៅសល់របស់ក្រុមប្រឹក្សាឃុំ សង្កាត់មានរយៈពេលមិនលើសពី ១៨០ថ្ងៃ គិតចាប់ពីថ្ងៃរំសាយ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចាត់អោយមានការគ្រប់គ្រងឃុំ សង្កាត់នោះស្របតាមមាត្រា ១៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។

**មាត្រា ៣៩.-**

ក្នុងករណីដែលក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវរំសាយ ដោយអនុលោមទៅតាមមាត្រា ៥៧ ឬ មាត្រា ៥៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ហើយអណត្តិដែលនៅសល់មានរយៈពេលលើសពី ១៨០ថ្ងៃ ក្រសួងមហាផ្ទៃ ត្រូវជូនដំណឹងដល់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និង ស្នើសុំអោយរៀបចំបោះឆ្នោតឡើងវិញ ដើម្បីជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ថ្មីមកជំនួស ។

ការបោះឆ្នោតឡើងវិញ ត្រូវរៀបចំឱ្យបានត្រឹមត្រូវតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និង ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។

**មាត្រា ៤០.-**

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវកំណត់កាលបរិច្ឆេទសំរាប់ការបោះឆ្នោតឡើងវិញក្នុងរយៈពេលយ៉ាងយូរ ៧ ថ្ងៃ បន្ទាប់ពីមានសំណើដែលតំរូវអោយមានការបោះឆ្នោតឡើងវិញ ។

**មាត្រា ៤១.-**

បន្ទាប់ពីបានទទួលបានលិខិតជូនដំណឹងរបស់ក្រសួងមហាផ្ទៃអំពីកាលបរិច្ឆេទសំរាប់ការបោះឆ្នោតឡើងវិញ គណៈ-កម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវរៀបចំការបោះឆ្នោតឡើងវិញដោយអនុលោមទៅតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និង ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។

## ជំពូកទី៥
## ទំនាក់ទំនងរវាងឃុំ សង្កាត់ជាមួយរាជរដ្ឋាភិបាល
## ក្រសួង ស្ថាប័ន អាជ្ញាធរ និង ភ្នាក់ងាររបស់រដ្ឋ

**មាត្រា ៤២.-**

រាល់ទំនាក់ទំនងជាផ្លូវការរវាងក្រុមប្រឹក្សាឃុំ សង្កាត់ ជាមួយរាជរដ្ឋាភិបាល ក្រសួង ស្ថាប័ន អាជ្ញាធរ ភ្នាក់ងារនានារបស់រាជរដ្ឋាភិបាល ព្រមទាំងអង្គការជាតិ និង អន្តរជាតិនានា ត្រូវប្រព្រឹត្តទៅតាមរយៈក្រសួងមហាផ្ទៃ ។

**មាត្រា ៤៣.-**

ក្រសួងមហាផ្ទៃអាចធ្វើប្រតិភូកម្មអំណាចដល់អភិបាលខេត្ត ក្រុង ឱ្យជួយក្នុងកិច្ចការទំនាក់ទំនងនេះ និង សំរបសំរួលការអនុវត្តតួនាទី មុខងារ អំណាចរបស់ឃុំ សង្កាត់ ដូចមានចែងក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ គោលនយោបាយ វិមជ្ឈការ និង អនុក្រឹត្យពាក់ព័ន្ធនានា ស្របទៅតាម សភាពការណ៍ជាក់ស្តែង ។

ការធ្វើប្រតិភូកម្មអំណាចនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដែលបានអនុម័តយល់ព្រមដោយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ។

**មាត្រា ៤៤.-**

ក្រសួងមហាផ្ទៃត្រូវសម្របសម្រួលឱ្យមានកិច្ចសហប្រតិបត្តិការរវាងឃុំ សង្កាត់ពីរ ឬ ច្រើន និងធានាដោះស្រាយរាល់ទំនាស់ និង ជំលោះដែលក្រុមប្រឹក្សាឃុំ សង្កាត់ទាំងនោះមិនអាចដោះស្រាយបាន។

**មាត្រា ៤៥.-**

ក្រសួងមហាផ្ទៃត្រូវសហ និង ពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាល ឬ អង្គការជាតិ និង អង្គការអន្តរជាតិនានាដើម្បីដោះស្រាយទំនាស់ ឬ ជំលោះដែលកើតមានឡើងរវាងក្រសួង ស្ថាប័ន ឬ អង្គការទាំងនោះ ជាមួយក្រុមប្រឹក្សា ឃុំ សង្កាត់ ។

**មាត្រា ៤៦.-**

ក្រសួងមហាផ្ទៃត្រូវធានាថាការសំរុះសំរួល ការដោះស្រាយទំនាស់ និង ជំលោះរវាងឃុំ សង្កាត់ និង ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ឬ អង្គការជាតិ និង អន្តរជាតិ មានភាពយុត្តិធម៌ ត្រឹមត្រូវ រក្សាបាននូវផលប្រយោជន៍ទាំងសងខាង និង អនុវត្តបានត្រឹមត្រូវតាមល័ក្ខខ័ណ្ឌដែលបានចែងក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និង គោលនយោបាយវិមជ្ឈការ ។

**មាត្រា ៤៧.-**

ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលអាចត្រួតពិនិត្យលើសេចក្តីសំរេច ឬ សកម្មភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ឬ

ធ្វើអន្តរាគមន៍លើសេចក្តីសំរេច ឬ សកម្មភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ នៅពេលដែលការត្រួតពិនិត្យ ឬ ការធ្វើអន្តរាគមន៍ទាំងនោះត្រូវបានអនុញ្ញាតដោយច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស ឬ លិខិតបទដ្ឋានដទៃទៀត ដែលបានពិនិត្យ ឬ បានសម្រេចយល់ព្រមដោយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ។

**មាត្រា ៤៨.-**

ក្រសួងមហាផ្ទៃអាចត្រួតពិនិត្យ ឬ ធ្វើអន្តរាគមន៍ផងដែរ ក្នុងករណីដែលក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល អង្គការជាតិ និង អង្គការអន្តរជាតិនានាបានធ្វើសេចក្តីរាយការណ៍ ឬ ប្តឹងតវ៉ាចំពោះក្រុមប្រឹក្សាឃុំ សង្កាត់ ។

**មាត្រា ៤៩.-**

ក្រសួង ឬ ស្ថាប័នដែលបានអនុញ្ញាតឱ្យធ្វើការត្រួតពិនិត្យលើសេចក្តីសម្រេច និង សកម្មភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធានាបង្កលក្ខណៈសម្បត្តិឱ្យក្រុមប្រឹក្សាឃុំ សង្កាត់អាចអនុវត្តមុខងារ និង អំណាចនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនបានត្រឹមត្រូវតាមនីតិវិធី ដែលបានតម្រូវដោយ ÷

- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- រាជក្រឹត្យ
- អនុក្រឹត្យ ប្រកាស ឬ លិខិតបទដ្ឋាននានាដែលបានពិនិត្យ ឬ បានសម្រេចយល់ព្រមដោយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់
- បទបញ្ជាផ្ទៃក្នុង ដីកា ឬ សេចក្តីសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

**មាត្រា ៥០ -**

ក្នុងករណីដែលក្រសួង ស្ថាប័នដែលបានអនុញ្ញាតឱ្យធ្វើការត្រួតពិនិត្យលើសេចក្តីសម្រេច និង សកម្មភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ពិនិត្យឃើញថាក្រុមប្រឹក្សាឃុំ សង្កាត់ អនុវត្តមុខងារ និង អំណាចមិនត្រឹមត្រូវតាមនីតិវិធី និង តំរូវការផ្នែកច្បាប់ ក្រសួង ស្ថាប័នទាំងនោះត្រូវ ÷

- ផ្តល់ដំណឹងជាលាយល័ក្ខអក្សរដល់ក្រសួងមហាផ្ទៃ អំពីនីតិវិធី និង តំរូវការផ្នែកច្បាប់ ដែលតម្រូវឱ្យក្រុមប្រឹក្សាឃុំ សង្កាត់អនុវត្ត
- ធ្វើសំណើជាលាយល័ក្ខអក្សរទៅក្រសួងមហាផ្ទៃនូវកំហុសឆ្គងដែលតម្រូវឱ្យកែប្រែ និង ពេលវេលាដែលត្រូវកែប្រែ និង ផ្តល់ពតិមានអំពីលទ្ធផលបញ្ចប់នៃការកែប្រែនោះ ។

**មាត្រា ៥១.-**

ក្រសួងមហាផ្ទៃត្រូវកំណត់ លក្ខណៈវិនិច្ឆ័យនៃការត្រួតពិនិត្យ និង ការធ្វើអន្តរាគមន៍ដូចតទៅ ÷

- ហេតុផលនៃកំហុសឆ្គង



ៗៃ

- ប្រភេទនៃវិធានការ ឬ សកម្មភាពអន្តរាគមន៍ដែលនឹងត្រូវធ្វើ

- ការគាំទ្រ និង ការបង្កើនសមត្ថភាពណាមួយដែលត្រូវផ្តល់ទៅអោយក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីពង្រឹងការគ្រប់គ្រង ការអនុវត្តន៍មុខងារ និង សិទ្ធិអំណាចឱ្យបានត្រឹមត្រូវ និងកាន់តែប្រសើរឡើង ។

**មាត្រា ៥២.-**

ក្នុងការត្រួតពិនិត្យលើសេចក្តីសម្រេច និង សកម្មភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ក្រសួងមហាផ្ទៃត្រូវ ÷

- ផ្តល់យោបល់ជាលាយល័ក្ខអក្សរដល់ក្រុមប្រឹក្សាឃុំ សង្កាត់អំពីនីតិវិធី និង តំរូវការផ្នែកច្បាប់ទាំងឡាយដែលត្រូវអនុវត្ត

- ណែនាំជាលាយល័ក្ខអក្សរឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ កែតំរូវកំហុសឆ្គងក្នុងកំឡុងពេលមួយសមស្រប និង ត្រូវរាយការណ៍នូវលទ្ធផលនៃការកែតម្រូវនោះមកក្រសួងមហាផ្ទៃវិញ ។

**មាត្រា ៥៣.-**

ពេលដែលក្រុមប្រឹក្សាឃុំ សង្កាត់គ្មានសមត្ថភាព ឬ គ្មានបំណងដើម្បីកែតំរូវកំហុសឆ្គង ក្រសួងមហាផ្ទៃត្រូវធ្វើកិច្ចការនោះជំនួសក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការអនុវត្តសេចក្តីសម្រេច និង កិច្ចការរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ហើយក៏ត្រូវចាត់វិធានការចាំបាច់ផងដែរដើម្បីអភិវឌ្ឍន៍នូវសមត្ថភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

**មាត្រា ៥៤.-**

ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល មិនអាចធ្វើសេចក្តីសម្រេចក្នុងនាមក្រុមប្រឹក្សាឃុំ សង្កាត់បានទេ លើកលែងតែនៅក្នុងករណីដែលបានអនុញ្ញាតដោយច្បាប់ ឬ ព្រះរាជក្រឹត្យ ឬ អនុក្រឹត្យ ឬ ប្រកាស ឬ លិខិតបទដ្ឋាននានាដែលបានពិនិត្យ និង បានសម្រេចយល់ព្រម ដោយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ។

សេចក្តីសំរេចដែលក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលបានធ្វើឡើងក្នុងនាមក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវតែធានាថាក្រុមប្រឹក្សាឃុំ សង្កាត់អាចអនុវត្តតាមនីតិវិធី និងតំរូវការផ្នែកច្បាប់ដែលបានចែងក្នុងករណីពិសេសនោះ ។

## ជំពូកទី៦

## មុខងារ និង អំណាចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និង ការផ្ទេរអំណាចរបស់រដ្ឋទៅអោយឃុំ សង្កាត់

**មាត្រា ៥៥.-**

ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលដែលមានបំណងធ្វើប្រតិភូកម្មអំណាច ឬ ការទទួលខុសត្រូវ ឬ ធ្វើកិច្ចព្រមព្រៀងណាមួយទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវតែស្នើសុំអនុញ្ញាតជាមុនពីគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ។

**មាត្រា ៥៦.-**

ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលដែលមានបំណងធ្វើប្រតិភូកម្មអំណាច ឬ ការទទួលខុសត្រូវ ឬ ធ្វើកិច្ចព្រមព្រៀងណាមួយទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវផ្ទេរធនធាន និង សមត្ថភាព ជាចាំបាច់ដើម្បីធានាឱ្យក្រុមប្រឹក្សាឃុំ សង្កាត់អនុវត្តបាននូវអំណាច ឬ ការទទួលខុសត្រូវ ឬ កិច្ចព្រមព្រៀងដែលបានធ្វើប្រតិភូកម្មនោះ ។

ក្រសួងមហាផ្ទៃត្រូវកំណត់នីតិវិធីជាក់ស្តែងថែមទៀតដើម្បីអនុវត្តនូវបទប្បញ្ញត្តិនេះ ។

**មាត្រា ៥៧.-**

ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលត្រូវរាយការណ៍អំពីការធ្វើប្រតិភូកម្មអំណាច ឬ ការផ្ទេរការទទួលខុសត្រូវ ឬ កិច្ចព្រមព្រៀងទាំងអស់ជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ជូនក្រសួងមហាផ្ទៃ និង អាជ្ញាធរខេត្ត ក្រុង ដែលពាក់ព័ន្ធ ។

**មាត្រា ៥៨.-**

ក្រុមប្រឹក្សាឃុំ សង្កាត់មិនអាចចុះកិច្ចព្រមព្រៀង ឬ ការចាត់ចែងការងារណាមួយជាមួយក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ឬ អង្គការជាតិ និង អន្តរជាតិ ឬ ផ្នែកឯកជនណាមួយ ដោយគ្មានការយល់ព្រមពីក្រសួងមហាផ្ទៃបានឡើយ ។

**មាត្រា ៥៩.-**

ក្រសួងមហាផ្ទៃត្រូវដាក់ជូនគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ពិភាក្សា និង អនុម័ត នូវកិច្ចព្រមព្រៀង ឬ ការចាត់ចែងណាមួយដែលបានស្នើឡើងដោយក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ដែលមានបំណងធ្វើប្រតិភូកម្មអំណាច ឬ ការទទួលខុសត្រូវ ឬ កិច្ចព្រមព្រៀងណាមួយទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ តែកិច្ចព្រមព្រៀង ឬ ការចាត់ចែងនោះមិនមានចែងក្នុងប្រកាស ឬ គោលការណ៍ណែនាំដែលបានសម្រេចដោយគណៈកម្មាធិការជាតិ គាំទ្រឃុំ សង្កាត់ ។

**មាត្រា ៦០.-**

ក្រសួងមហាផ្ទៃត្រូវត្រួតពិនិត្យការអនុវត្តកិច្ចព្រមព្រៀង និង ត្រូវធានាថាធនធាន សមត្ថភាព និង កំរៃដែលបានយល់ព្រមផ្ទេរទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបានប្រគល់ជូនយ៉ាងត្រឹមត្រូវ ។

**មាត្រា ៦១.-**

ឃុំ សង្កាត់មានតួនាទី និង មុខងារយ៉ាងទូលំទូលាយក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដែលក្នុងនោះមានមុខងារ និង តួនាទីជាមូលដ្ឋានគឺ ÷

- រក្សាសន្តិសុខ និង សណ្តាប់ធ្នាប់របៀបរៀបរយសាធារណៈ
- ចាត់ចែងសេវាកម្មសាធារណៈចាំបាច់ និង មើលការខុសត្រូវឱ្យកិច្ចការនោះដំណើរការបានល្អ
- លើកទឹកចិត្តអោយមានការបង្កើនជាសុខភាព និង សុខមាលភាពប្រជាពលរដ្ឋ
- ជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ច និង សង្គមកិច្ច ហើយលើកកំពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋអោយមានលក្ខណៈ



ហ.

ល្អប្រសើរឡើងជាលំដាប់

- ការពារ និង ថែរក្សាបរិស្ថាន ធនធានធម្មជាតិ វប្បធម៌ បេតិកភ័ណ្ឌជាតិ

- ជម្រុះជម្រាការខ្វែងមតិយោបល់គ្នា ហើយជំរុញអោយមានការយោគយល់ និង ការអត់ឱនទៅវិញទៅមករវាងប្រជាពលរដ្ឋ

- ទទួលរ៉ាប់រងលើកិច្ចការទូទៅបន្ថែមទៀត ដើម្បីបំពេញទៅតាមតំរូវការរបស់ប្រជាពលរដ្ឋ ។

**មាត្រា ៦២.-**

ឃុំ សង្កាត់ត្រូវអនុវត្តមុខងារមួយផ្នែក ឬ ទាំងអស់នៃមុខងារ និង ការទទួលខុសត្រូវដែលបានផ្ទេរប្រតិភូកម្មឱ្យបានសមស្របទៅនឹងធនធានដែលបានផ្តល់ ដើម្បីលើកស្ទួយ និង គាំទ្រដល់ការអនុវត្តន៍តួនាទី និង មុខងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់ប្រកបដោយចីរភាព និង បំពេញបានទៅតាមតំរូវការជាមូលដ្ឋាន។

**មាត្រា ៦៣.-**

ឃុំ សង្កាត់មានសិទ្ធិជ្រើសរើស និង អនុវត្តសកម្មភាពណាមួយ ដែលស្ថិតនៅក្នុងសមត្ថកិច្ចនៃមុខងារជាទូទៅ និងដែលស្ថិតនៅក្នុងកំរិតនៃធនធានដែលមាន។

**មាត្រា ៦៤.-**

កិច្ចការជាក់លាក់មួយចំនួនត្រូវបានហាមឃាត់ មិនឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ អនុវត្ត រួមមាន ÷

- វិស័យព្រៃឈើ

- វិស័យប្រៃសណីយ៍ និង ទូរគមនាគមន៍

- វិស័យការពារជាតិ

- វិស័យសន្តិសុខជាតិ

- វិស័យរូបិយវត្ថុ

- វិស័យនយោបាយក្រៅប្រទេស

- វិស័យគោលនយោបាយសារពើពន្ធ

- វិសយ័ផ្សេងទៀតដែលកំណត់ដោយក្រសួងមហាផ្ទៃ បន្ទាប់ពីមានការយល់ព្រមរបស់គណៈកម្មាធិការជាតិគាំទ្រ ឃុំ សង្កាត់ ។

**មាត្រា ៦៥.-**

ឃុំ សង្កាត់អាចមានសិទ្ធិអំណាចដើម្បីជ្រើសរើស និង អនុវត្តសកម្មភាពដែលស្ថិតក្នុងតួនាទី និង មុខងារដែលនៅក្រៅយុត្តាធិការរបស់ខ្លួន ក្នុងករណីមានការអនុញ្ញាតពិសេសណាមួយពីក្រសួង ស្ថាប័ននានារបស់រដ្ឋ ផ្អែកតាមការសំរបសំរួលដោយក្រសួងមហាផ្ទៃ និង ត្រូវរាយការណ៍ជូនដល់គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ។

**មាត្រា ៦៦.-**

ឃុំ សង្កាត់ត្រូវចាត់ចែងនិងប្រើប្រាស់ធនធានដែលមាន ដើម្បីជ្រើសរើសនិងអនុវត្តសកម្មភាពរបស់ខ្លួន ។

**មាត្រា ៦៧.-**

មុខងារ និង តួនាទីចំបងរបស់ឃុំ សង្កាត់គឺត្រូវសម្របសម្រួល និង ជំរុញឱ្យមានការអភិវឌ្ឍន៍ក្នុងឃុំ សង្កាត់របស់ខ្លួន ដោយត្រូវជ្រើសរើសវិធីសាស្ត្រសមស្រប និង មានប្រសិទ្ធិភាព ដើម្បីអនុវត្ត និង ផ្តល់សេវាកម្មអោយស្របតាមជំរើសដែលបានសំណូមពរដោយស្ថាប័នខាងលើ ។

**មាត្រា ៦៨.-**

ប្រសិនបើមុខងារ ឬ សេវាដែលឃុំ សង្កាត់ទទួលបានសិទ្ធិអំណាចដើម្បីអនុវត្ត កំពុងត្រូវបានផ្តល់អោយដោយភ្នាក់ងារ ឬ អង្គការដទៃទៀត ដោយមិនគិតក្នុងបន្ទុកចំណាយរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់គួរទទួលស្គាល់កិច្ចការទាំងនេះ ។

ក្រុមប្រឹក្សាឃុំ សង្កាត់អាចប្រើប្រាស់ធនធានរបស់ខ្លួន ដើម្បីធ្វើការអភិវឌ្ឍន៍នៅកន្លែងដែលមិនទាន់មានអ្នកជួយគាំទ្រ ។

**មាត្រា ៦៩.-**

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ត្រូវសិក្សា និង កំណត់ឱ្យបានជាក់លាក់ថែមទៀតអំពីការបែងចែកមុខងាររវាងរដ្ឋបាលថ្នាក់កណ្តាល និង ឃុំ សង្កាត់ ។

ការបែងចែកខាងលើត្រូវមានគោលដៅដើម្បីធានាប្រសិទ្ធិភាពនៃការអនុវត្តន៍។

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ត្រូវធ្វើការបែងចែករវាងសេវាកម្មដែលត្រូវផ្តល់ដោយរដ្ឋបាលថ្នាក់កណ្តាល ភ្នាក់ងារនានារបស់រដ្ឋ អង្គការជាតិ អន្តរជាតិ និង វិស័យឯកជន ជាមួយសេវាកម្មដែលត្រូវផ្តល់ដោយឃុំ សង្កាត់ ។

**មាត្រា ៧០.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវទទួលខុសត្រូវក្នុងការរៀបចំ ការអនុម័ត និង ការអនុវត្តន៍ផែនការអភិវឌ្ឍន៍ និង ផែនការថវិកាឃុំ សង្កាត់របស់ខ្លួន ។

ការរៀបចំ ការអនុម័ត និង ការអនុវត្តន៍ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ត្រូវអនុលោមទៅតាមបទប្បញ្ញត្តិនានាដែលបានសម្រេចដោយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ។

**មាត្រា ៧១.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវរៀបចំ និង ប្រើប្រាស់ថវិកាដោយអនុលោមទៅតាមបទប្បញ្ញត្តិពាក់ព័ន្ធនានាដែលបានសម្រេចដោយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ។

## ជំពូកទី៧

## អន្តរប្បញ្ញត្តិ

**មាត្រា ៧២.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវពិនិត្យឡើងវិញរាល់សកម្មភាពនៃការចាត់ចែង និង កិច្ចព្រមព្រៀងទាំងឡាយដែលបានរៀបចំឡើងក្នុងនាមឃុំ សង្កាត់ ឬ ដោយឃុំ សង្កាត់ផ្ទាល់ ឬ ភូមិមុនការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់លើកទីមួយនេះ ។

ការចាត់ចែង ឬ កិច្ចព្រមព្រៀងទាំងនោះរួមមានការផ្ទេរអំណាច ឬ សិទ្ធិពីក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ឬ ការធ្វើសហប្រតិបត្តិការ ឬ ការជួយគាំទ្រពីកម្មវិធី និង អង្គការនានា ។

ក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ត្រូវធ្វើការពិភាក្សាជាមួយគ្រប់ក្រសួង ស្ថាប័ន តំណាងកម្មវិធី និង អង្គការដែលពាក់ព័ន្ធដើម្បី ÷

- បញ្ជាក់ថាកិច្ចព្រមព្រៀង ឬ ការចាត់ចែងដែលកំពុងអនុវត្ត ពិតជាបានអនុវត្តនៅក្នុងឃុំ សង្កាត់ ឬភូមិ របស់ខ្លួន
- ពិនិត្យឡើងវិញនូវកិច្ចព្រមព្រៀង ឬ ការចាត់ចែងណា ដែលផ្ទុយនឹងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និង គោលនយោបាយវិមជ្ឈការ ឬ ផ្ទុយពីគោលការណ៍ណែនាំរបស់គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ដើម្បីស្នើសុំធ្វើការកែសម្រួលអោយបានសមស្រប ។

**មាត្រា ៧៣.-**

ក្នុងអាណត្តិរបស់ខ្លួន គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ត្រូវទទួលខុសត្រូវក្នុងការសម្របសម្រួលជាមួយក្រសួង ស្ថាប័ននានា របស់រាជរដ្ឋាភិបាល ដើម្បីកំណត់ និង បែងចែកភារកិច្ចជាក់លាក់រវាងរដ្ឋបាលថ្នាក់កណ្តាល ថ្នាក់ ខេត្ត ក្រុង ស្រុក ខណ្ឌ និង ឃុំ សង្កាត់ ។

**មាត្រា ៧៤.-**

គណកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ត្រូវពិនិត្យបញ្ជាក់ថា ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និង លិខិតបទដ្ឋានណាដែលមានភាពសមស្រប ឬ មិនសមស្របទៅនឹងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និង គោលនយោបាយវិមជ្ឈការ ។

ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និង លិខិតបទដ្ឋានណាដែលមិនសមស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និង គោលនយោបាយវិមជ្ឈការ គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ត្រូវរៀបចំបែបបទ និង នីតិវិធីធ្វើវិសោធនកម្ម ឬ កែសំរួលអោយបានសមស្រប ។

**មាត្រា ៧៥.-**

គ្រប់ក្រសួង និង ស្ថាប័ននានារបស់រដ្ឋាភិបាលត្រូវ ÷

– បញ្ជាក់ថាច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និង លិខិត បទដ្ឋាន ទាំងអស់ដែលពាក់ពន្ធ័នឹងក្រសួង និង ស្ថាប័នរបស់ខ្លួនកំពុង អនុវត្តនៅតាមឃុំ សង្កាត់ និង ភូមិ ត្រូវតែសមស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និង គោលនយោបាយវិមជ្ឈការ ។

– ពិនិត្យឡើងវិញនូវច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និង លិខិតបទដ្ឋានដែលផ្ទុយនឹងគោលការណ៍វិមជ្ឈការ និង វិសហមជ្ឈការ ដើម្បីដាក់ជូនគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ពិនិត្យ និង ស្នើសុំធ្វើ វិសោធនកម្មជាបន្ទាន់ ។

## ជំពូកទី៨
## អវសានប្បញ្ញត្តិ

**មាត្រា ៧៦.-**

រាល់បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៧៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នត្រូវអនុវត្តអនុក្រឹត្យនេះឱ្យ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែមីនា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចនាយករដ្ឋមន្ត្រី

សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ស ខេង យូ ហុកគ្រី